00836982

E1/110.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Aug-2012, 14:57
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៩៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ឃីត រេយន័រ
*(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោក គ្រីស្ទីន ម៉ាទីណូ
*(Mr. Chritine MARTINAU)*

លោកស្រី បេនី យេ *(Ms. Beini YE)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោកស្រី លី នីមល(មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ) | ខ្មែរ |
| លោក ស្បូង ស៊ីគឿន (TCW-694) | ខ្មែរ |
| លោកស្រី ស សៀក (TCW-609) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)

សួរបន្តដោយលោក ម៉ែខល កាណាវាស ផ្ដើមពី៖ .......................................................... ទំព័រ ៣

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ស សៀក ហៅ ស៊ីម** (TCW-609)

សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖.......................................................ទំព័រ ៥៧

សួរដោយលោកស្រី បេនី យេ ផ្ដើមពី៖........................................................................ ទំព័រ ៦៤

សួរដោយលោក ពេជ អង្គ ផ្ដើមពី៖ ............................................................................ទំព័រ ៧៧

សួរដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ....................................................... ទំព័រ ៨១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ កិច្ចដំណើរការសវនាការនៅថ្ងៃ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគៀន ដែលនឹងសួរដេញដោលដោយមេធាវីការពារក្តី ហើយជាយថាហេតុពេលនៅសេសសល់ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស សៀក តាមកាលបរិច្ឆេទដែលបានកំណត់ និងជម្រាបជជូនភាគីរួចហើយ។

ក្រឡាបញ្ជីលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក សុន អរុណ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ដោយសារមូលហេតុសុខភាព។ ចំណែកជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួន នៅខាងក្រោមសាលសវនាការ។

[០៩:០៣:៥០]

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេលពេញមួយថ្ងៃ នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំពោះសាក្សី ស សៀក មានវត្តមាននៅបន្ទប់រង់ចាំរង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។

បាទ ជាបន្តូនហ្នឹង មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី។ អង្គជំនុំជម្រះសម្រេចលើសំណើសុំចំនួនពីរ។

ទី១ គឺសំណើសុំរបស់លោក អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់លោក អៀង សារី ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:០៤]

លោកវេជ្ជបណ្ឌិត វ៉ាន់ មិច គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយបានកត់សម្គាល់ឃើញថាលោក អៀង សារី មានការៈហត់ ជាពិសេសនៅពេលធ្វើចលនាបន្តិចបន្តួច និងពេលនិយាយច្រើន គាត់វិលមុខពេលងើបដើរ ដោយយោងលើសភាពនៃរោគសញ្ញាដូចនេះ គាត់ពុំអាចដើរ ឬឡើងទីខ្ពស់ ឬអង្គុយយូរបានទេ និងបានផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។ អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយក្នុងបន្ទប់សវនាការនេះ ដោយគាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប គាត់អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្នុងសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ។

[០៩:០៦:១០]

អង្គជំនុំជម្រះសម្រេចយល់តាមសំណើសុំរបស់ជនជាប់ អៀង សារី ដែលបានសុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

សេចក្ដីសម្រេចទី២ គឺជាសេចក្ដីសម្រេចលើសំណើសុំប្រើប្រាស់ឯកសារក្នុងពេលសួរដេញដោលសាក្សី។ អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យមេធាវីការពារក្ដី នួន ជា ដកស្រង់នូវពាក្យសម្ដី ឬឃ្លា

ប្រយោគចេញពីឯកសារ D366/7.1.564 បានល្អីកណាតែមេធាវីមានសំណួរត្រូវសួរទៅកាន់សាក្សីបន្ថែមទៀតប៉ុណ្ណោះ។ សហមេធាវីមិនអាចដេញដោលលើប្រធានបទដែលបានពិភាក្សារួចហើយ ជាពិសេសសួរសំណួរដែលមានភាពច្រំដែល ឬមិនពាក់ព័ន្ធបានឡើយ។

[០៩:០៧:២៦]

សំណើសុំប្រើប្រាប់ឯកសារ D22/185.5 និង E3/1435 ត្រូវបានបដិសេធចោល។ ដោយអង្គជំនុំជម្រះសេចក្ដីសម្រេចនឹងចេញជាលាយលក្ខណ៍អក្សរនឹងចេញនៅពេលសមស្របខាងមុខនេះ។

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ហើយសូមគោរពដល់អស់លោក លោកស្រីទាំងអស់។ សូមជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមបន្តពីអ្វីដែលយើងបានបញ្ឈប់កាលពីថ្ងៃព្រហស្បតិ៍។ ខ្ញុំសូមរំឭកលោកឡើងវិញ ថា យើងបានពិភាក្សាអំពីសក្ខីកម្ម ពីខែ៨ ថ្ងៃទី០៦ ឆ្នាំ២០១២។ ហើយខ្ញុំនិយាយយោងទៅលើទំព័រ៦៤ ភាសាអង់គ្លេស ហើយភាសាគឺ 00832181 ដល់ 82, ភាសាបារាំង គឺមានលេខ 00833134 ដល់ 35,ហើយភាសាអង់គ្លេសគឺ 00833251។ ហើយខ្ញុំនឹងពិភាក្សាអំពីចំណុចនេះ លោកបានផ្ដល់នូវចម្លើយដែលលោកនិយាយថា លោក អៀង សារី គឺទទួលខុសត្រូវខាងការបរទេសនៃគណៈមជ្ឈិម -- នៃមជ្ឈិម។ ហើយបានស្នើឲ្យបញ្ញាជនដែលត្រឡប់មកពីប្រទេសបារាំងដែលជាក្រុមម៉ាក្ស-ឡេនីន ដែលជាវង្សម៉ាក្ស-ឡេនីន ហើយគាត់ទទួលខុសត្រូវទៅលើក្រុមនេះ។ ហើយនៅក្នុងក្រុមហ្នឹងគឺមានលោកសាក្សីផងដែរ។

ហើយលោកបានបន្តទៀតថា ដើម្បីឲ្យមានការបញ្ជាក់ច្បាស់លាស់ តើមានន័យយ៉ាងម៉េចដែរ ដែលប្រើពាក្យថា “ទទួលខុសត្រូវ” ឬក៏ “ទទួល -- ដែល ប៉ុល ពត ក៏បានធ្វើការសម្រេចចិត្តពាក់ព័ន្ធទៅនឹងការតែងតាំងយើង” ហើយលោក អៀង សារី ទទួលខុសត្រូវផ្ទាល់ក្នុងការអនុវត្តការងាររបស់លោក។ តើលោកចាំទេ ថាលោកបានផ្ដល់សក្ខីកម្មបែបនេះលោកសាក្សី?

[០៩:១០:១៧]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ជាបឋម សូមគោរពលោកប្រធាន សូមគោរពបងៗ សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំចាំថា ខ្ញុំបាននិយាយ ផ្តល់សក្ខីកម្មបែបនេះមែន។

**ស៖** សូមអរគុណ។ ប្រសិនបើយើងបន្តទៅមួយទំព័រមុខទៀត គឺទំព័រ៦៤ នៃប្រតិចារឹក ខ្មែរ ERN គឺមាន 00832183 ដល់ 84, ភាសាបារាំង គឺ 00833137 ដល់ 38 និងភាសាអង់គ្លេស គឺ 00833253 ដល់ 54។ ហើយលោកបានបន្តថា ក្នុងករណីមួយចំនួន គាត់គឺ ប៉ុល ពត នោះបានធ្វើការសម្រេចចិត្តដោយឆន្ទានុសិទ្ធិផ្ទាល់ខ្លួន។ ជាឧទាហរណ៍ពាក់ព័ន្ធទៅនឹងបញ្ញាជនដែលត្រឡប់មកពីប្រទេសបារាំង ហើយខ្ញុំដឹងច្បាស់ពីព្រោះថា គាត់ស្គាល់គេដោយផ្ទាល់ ហើយគាត់ដឹងអំពីគោលនយោបាយ។ ហើយលោកបាននិយាយទៀតថា នៅពេលដែលធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងពួកគាត់ហ្នឹង គឺប៉ុល ពត ធ្វើការសម្រេចដោយខ្លួនឯង។ គឺគាត់ធ្វើសេចក្តីសម្រេចដោយខ្លួនឯង។ ហើយលោកបានបញ្ជាក់បន្តទៀតថា គឺលោកនិយាយអំពី ប៉ុល ពត ថា គាត់ធ្វើសេចក្តីសម្រេចចិត្តចំពោះបញ្ញាជនដែលមកប្រទេសបារាំង។ តើលោកនៅរក្សាចម្លើយបែបនេះដែរឬទេ លោកសាក្សី?

[០៩:១២:២០]

**ស៖** ខ្ញុំសូមបញ្ជាក់ថា ហើយខ្ញុំធ្វើសក្ខីកម្មអ្វីដែលខ្ញុំដឹង។ គឺតាមខ្ញុំដឹងបញ្ញាជនមួយចំនួនដែលជាសមាជិកនៃវង់មាក្ស-ឡេនីន គឺតែងតែគោរពតាមការដឹកនាំរបស់បក្សនៅក្នុងប្រទេស ហើយគោលបំណងគេ គឺទាំងអស់គ្នា ពេលបានរំដោះហើយនៅថ្ងៃទី១៧ មេសា ១៩៧៥ គឺគេស្នោះស្ម័គ្រចូលមកក្នុងប្រទេស ដើម្បីមកបម្រើប្រទេសជាតិ។ ខ្ញុំ ដែលខ្ញុំនិយាយអំពីការសម្រេចលើវាសនារបស់អ្នកទាំងនោះដោយរួមទាំងរូបខ្ញុំផងនេះ គឺខ្ញុំនិយាយតែបញ្ញាជនដែលជាសមាជិករបស់វង់មាក្ស-ឡេនីន តែប៉ុណ្ណោះទេ។ អ្នកទាំងអស់នេះ គឺថា ប៉ុល ពត គាត់ស្គាល់អ្នកទាំងអស់នេះច្បាស់ ហើយស្គាល់ទាំងគោលជំហរ។ ហើយខ្ញុំសូមបញ្ជាក់ថា អ្នកទាំងអស់នេះស្តាប់តាមបង្គាប់ គោរពសេចក្តីសម្រេចចិត្តរបស់បក្សនៅក្នុងប្រទេស មិនមានន័យថា អ្នកទាំងអស់ហ្នឹង បើរៀបរាប់ជាបុគ្គលិកឯកភាពនឹងការសម្រេចរបស់បក្សទាំងស្រុងទេ។ ក៏ប៉ុន្តែ យោងតាមគោលការណ៍របស់បក្សខាងលើត្រូវគោរព -- អ៎! ខាងក្រោមត្រូវគោរពខាងលើ។ យើងខ្ញុំទាំងអស់គ្នា គឺស្នោះស្ម័គ្រ និងចូលមករួមចំណែកក្រោមការដឹកនាំរបស់បក្សដើម្បីកសាងប្រទេសឡើងវិញ ក្រោយសង្គ្រាមបាទ។

[០៩:១៤:៣៣]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមសួរនូវសំណួរដែលខ្លីដើម្បីបញ្ជាក់ទៅលើអ្វីដែលលោកបាននិយាយ។ ឥឡូវនេះ យើងនិយាយអំពី ប៉ុល ពត គឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានផ្តល់នៅថ្ងៃនេះ ខ្ញុំចង់និយាយយោងទៅលើថ្ងៃ១៥ ខែ៨ ឆ្នាំ២០១២ គឺសក្ខីកម្មរបស់លោកដែលអាចមាននៅទំព័រ១៨ ជាភាសាអង់គ្លេស ហើយភាសាខ្មែរ គឺមានលេខ១៣ ទៅ១៤ គឺជាពង្រាងប្រតិចារឹក ហើយចំណែកភាសាបារាំង គឺទំព័រទី១៩។ យើងសូមចាប់ផ្តើមនៅទំព័រទាំងអស់នេះ៖ នៅពេលដែលគេសួរលោកអំពី ហ្វីលីព ស្សូត ហើយនិងសៀវភៅរបស់គាត់គឺ "ប្រវត្តិនៃសុបិនអាក្រក់មួយ"។ នៅចំណុចមួយនោះ គឺលោកលោកបានដកស្រង់នូវសេចក្តីនិយាយដែលបាននិយាយទាក់ទងទៅដល់លោក ហើយនៅទំព័រ -- ហើយមាននៅទំព័រ២០ជាភាសាអង់គ្លេស និងទំព័រ២១ជាភាសាបារាំង ដែលលោកនិយាយអំពី ប៉ុល ពត ដែលគ្រប់គ្រងជា -- ដែលគ្រប់គ្រងល្អិតៗ គឺជាការគ្រប់គ្រងទម្រង់តូចៗដែលជាផ្នែកមួយនៃការដឹកនាំរបស់ ប៉ុល ពត គឺមិនមានការចែករំលែកអំណាចនោះឡើយ គឺគាត់ចង់ធ្វើការផ្តាច់មុខទៅលើសិទ្ធិអំណាចរបស់គាត់។ ថាតើផ្អែកទៅលើអ្វីដែលលោកបានសង្កេតឃើញនៅពេលនោះ គឺថា ប៉ុល ពត ធ្វើការគ្រប់គ្រងយ៉ាងលម្អិតទៅលើអ្វីៗទាំងអស់នោះ។ តើបែបនេះដែរឬទេ?

[០៩:១៦:២៧]

**ឆ៖** បាទ គឺដូច្នេះមែន គឺថារបៀបគ្រប់គ្រងរបស់គាត់ គឺគាត់គ្រប់គ្រងលម្អិតបាទ។ មិនទុកចន្លោះឲ្យ -- គឺថាតឹងរ៉ឹង ចូលដល់លម្អិតមែនទែនបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមលើកឧទាហរណ៍មួយ ហើយសង្ឃឹមថា លោកអាចជួយបញ្ជាក់បានថាតើនេះជាឧទាហរណ៍នៃការគ្រប់គ្រងលម្អិតនេះដែរទេ។ ខ្ញុំសូមនិយាយពីឯកសារ E3/42 ហើយភាសាខ្មែរគឺមានលេខ 00327206 ដល់ 07, ភាសាបារាំងគឺមានលេខ 00327226 ដល់27 និងភាសាអង់គ្លេសគឺមានលេខ 00327217 ហើយឯកសារនេះ គឺចម្លើយរបស់លោកនៅថ្ងៃ០៦ ខែ៥ ឆ្នាំ២០០៩ ហើយខ្ញុំគិតថា យើងបានពិភាក្សាចំណុចខ្លះហើយនៃឯកសារនេះ ដែលគេសួរលោកថា "តើលោកមានការទាក់ទងជាមួយ នួន ជា ទេ ពីឆ្នាំ៧៥ ដល់៧៩?" ហើយយើងឃើញថាចម្លើយរបស់លោកមួយចំនួន "ខ្ញុំមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយគាត់នោះទេ គឺពីឆ្នាំ៧៥ដល់៧៩ ពីព្រោះគាត់មិនទាក់ទងជាមួយគោលការណ៍បរទេស ព្រោះ ប៉ុល ពត គឺជាអ្នកទទួលខុសត្រូវលើផ្នែកនេះ"។ អ្វីដែលខ្ញុំអាចនិយាយបាន តើលោកនៅរក្សាចម្លើយដដែលដែរឬទេ ដែលថា ប៉ុល ពត គឺជាអ្នកទទួលខុស

ត្រូវទៅលើគោលការណ៍ការបរទេសៗ -- គោលនយោបាយបរទេសនោះ?

[០៩:១៨:២៨]

**ឆ៖** អាហ្នឹងច្បាស់ហើយបាទ ព្រោះគោលការណ៍របស់បក្សគឺ បក្សជាអគ្គបញ្ជាការ បក្សដឹកនាំផ្តាច់មុខ គឺអត់មាននេះទេ ដូច្នេះក្នុងឋានៈគាត់ជាលេខារបស់បក្ស គាត់មានសិទ្ធិជាស្វ័យប្រវត្តិ ដើម្បីនឹងដឹកនាំ ហើយត្រួតត្រាលើកិច្ចការទាំងអស់របស់បក្ស ក៏ដូចជារបស់រដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមលើកឧទាហរណ៍មួយទៀត ដើម្បីឲ្យលោកជួយបញ្ជាក់មកយើង គឺនិយាយអំពីសៀវភៅខ្មៅ លោកបានផ្តល់សក្ខីកម្មថា "ពាក់ព័ន្ធទៅនឹងបញ្ហាសៀវភៅខ្មៅនេះគឺខ្ញុំចង់និយាយអំពីសក្ខីកម្មថ្ងៃទី០៦ ខែ៨ របស់លោក ដែលលោកបានបញ្ជាក់ថា "គឺ ប៉ុល ពត ជាអ្នកទទួលខុសត្រូវទៅលើការពង្រាងសៀវភៅខ្មៅ គឺជាគំនិតរបស់គាត់ក្នុងការតែងសៀវភៅខ្មៅ"។ តើលោកចាំថា លោកបានជម្រាបបែបនេះមកយើងដែរឬទេ?

[០៩:២០:០១]

**ឆ៖** បាទ គឺខ្ញុំបានជម្រាបអង្គសវនាការដូច្នោះមែន គឺគាត់បានហៅកម្មាភិបាលមួយចំនួនទៅជួបគាត់ ហើយតាមខ្ញុំដឹង គឺថាពេលនុំងគឺមានវត្តមានរបស់លោក អៀង សារី ផងដែរ។ រួចទៅគាត់ធ្វើបទឧទ្ទេសនាម យើងចាំតែកត់ទៅ។ ដល់ចប់ទៅ គឺថាយើងត្រឡប់មកក្រសួងការបរទេសវិញ។ តាមខ្ញុំចាំពេលនោះគឺថាមានខ្លួនខ្ញុំផ្ទាល់ មានលោក គាត ឈន់, លោក ជួន ប្រាសិទ្ធ ហើយនិងលោក នី កន ដែលខ្ញុំចាំ ហើយអ្នកស្រី សួរ សែ អាចអ៊ីចឹងដែរ។ បាទជាកម្មាភិបាលខ្លះមិនទាំងអស់ទេរបស់ក្រសួងការបរទេស។ រួចហើយយើង គឺរៀបរៀងឲ្យបានស្រួលបួលអ្វីដែលគាត់បានឧទ្ទេសនាមហ្នឹង យកទៅឲ្យគាត់មិនពិនិត្យម្តងទៀត។ រួចហើយបានគាត់បញ្ចុះ គាត់ផ្ញើឯកសារហ្នឹងមកខាងផ្នែករបស់ខ្ញុំហ្នឹង គឺផ្នែកឃោសនាការ និងព័ត៌មាននៃក្រសួងការបរទេសដើម្បីបោះពុម្ពផ្សាយជាបីភាសា ជាភាសាខ្មែរ ជាភាសាបារាំង និងជាភាសាអង់គ្លេសបាទ។ កិច្ចដំណើរការជាក់ស្តែង គឺយ៉ាងដូច្នេះ គឺយើងខ្ញុំមិនមានសិទ្ធិកែប្រែអ្វីដែលគាត់បានឧទ្ទេសនាមនោះទេ គ្រាន់តែមកសម្រួលឃ្លាឃ្លោងតែប៉ុណ្ណោះបាទ។

[០៩:២១:៥៣]

**សៈ** សូមអរគុណលោកសាក្សី។ ហើយដើម្បីជាកំណត់ត្រា យើងអាចរកឃើញនូវសក្ខីកម្មរបស់លោកទាក់ទងទៅនឹងបញ្ហានេះនៅទំព័រ៧៩ ដល់៨០ ភាសាអង់គ្លេស និងភាសាខ្មែរ គឺមានលេខ

00832192 ដល់ 94, ភាសាបារាំងគឺ 00833151 ដល់ 57 ហើយភាសាអង់គ្លេសគឺមានលេខ 00833266 ដល់ 67។ ហើយឥឡូវនេះ ថាតើអាចថាជាឧទាហរណ៍ដែរឬទេ ដែលថាការគ្រប់គ្រងជាលម្អិត ថាតើលោកអាចនិយាយពាក់ព័ន្ធទៅនឹងលោក -- តើលោកនិយាយយោងដូចគ្នានឹងអ្វីដែល ហ្វីលីព ស្បត និយាយអ៊ីចឹងដែរឬទេ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** ការគ្រប់គ្រងលម្អិតគ្រប់ជ្រុងជ្រោយរបស់គាត់នេះ គឺមានឧទាហរណ៍ច្រើនណាស់ គឺថាខ្ញុំបានលើកខ្លះទេ។ ប៉ុន្តែបើសិនជាលោកប្រធានអនុញ្ញាត គឺខ្ញុំសូមលើឧទាហរណ៍មួយទៀត គឺច្បាស់។ ក្នុងពេលនោះគឺនៅឆ្នាំ១៩៧៦ តាមខ្ញុំចាំ គឺក្នុងដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីការបរទេសថៃ គឺលោក ពិចៃ រដ្ឋគុណ។ ពេលនោះគឺថា ការទាក់ទងរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសថៃមិនទាន់មានការដូចថា ការទាក់ទងធម្មតាទេ យើងមិនទាន់ផ្លាស់ប្តូរឯកអគ្គរដ្ឋទូតទេ គឺលោក ពិចៃ រដ្ឋគុណ អាចអញ្ជើញមកទស្សនៈតែនៅស៊ីសុផុន នៅស្វាយស៊ីសុផុនសព្វថ្ងៃហ្នឹង។

[០៩:២៤:០០]

ពេលនោះគឺខ្ញុំក៏ៗ នៅទីនោះដែរ ហើយរៀបចំកន្លែងទទួលភ្ញៀវអីហ្នឹងគឺថា ប៉ុល ពត គាត់បានផ្ញើមកឲ្យយើងខ្ញុំហ្នឹងតាំងពីសាប៊ូ សាប៊ូក្រអូប តាំងពីកន្សែង តាំងពីទ្រនាប់ជើង ដើម្បីឲ្យភ្ញៀវ។ ខ្ញុំចង់បញ្ជាក់ហ្នឹង បាទ។ ហើយពេលនោះក៏ អតីតនាយករដ្ឋមន្ត្រីថៃ លោក អាណន់ បញ្ញារ៉ាជុន (Anand Panyarachun) ហ្នឹងគាត់ធ្វើជាអគ្គលេខាធិការរបស់ក្រសួងការបរទេសថៃ បាទ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**សៈ** សូមអរគុណលោកសាក្សី។ យើងនឹងពិភាក្សាបន្ថែមទៀតនៅពេលក្រោយបន្តិចទៀត។ ឥឡូវនេះខ្ញុំចង់និយាយអំពីចម្លើយរបស់លោក នៅថ្ងៃ១២ មីនា ឆ្នាំ២០០៩ ហើយចម្លើយនេះគឺមានលេខ E3/371 ហើយខ្ញុំនិយាយយោងទៅលើទំព័រ២ ភាសាអង់គ្លេស ហើយភាសាខ្មែរ មានលេខERN គឺ 00288234 ដល់ 35, ភាសាបារាំង គឺមានលេខ 00288241 ដល់ 42 និងភាសាអង់គ្លេសគឺមានលេខ 00290413 ដល់ 16។ នៅត្រង់ចម្លើយនេះ លោកបាននិយាយថា “កម្ពុជាប្រជាធិបតេយ្យគឺជាប្រទេសកុម្មុយនីស្ត ដូច្នេះបក្សជាអ្នកសម្រេចទាំងអស់រួមទាំងកិច្ចការបរទេសផងដែរ។ នយោបាយនេះត្រូវបានកំណត់ដោយប្រធានបក្ស គឺ ប៉ុល ពត។ ហើយវាសនារបស់ខ្ញុំផ្ទាល់ក៏សម្រេចដោយ ប៉ុល ពត ដែរ។ ក្នុងន័យនេះ គឺ ប៉ុល ពត ជាអ្នកតែងតាំងខ្ញុំឲ្យធ្វើការនៅក្រសួងការបរទេស និងតែងតាំងខ្ញុំជាប្រធានទីភ្នាក់ងារព័ត៌មានកម្ពុជា”។ ខ្ញុំសូមបញ្ចប់នៅត្រង់ចំណុចនេះ។ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានជម្រាប

យើង ថាតើបក្សជាសមូហភាពដែលជាអ្នកកំណត់គោលនយោបាយបរទេស ឬមួយក៏ ប៉ុល ពត ដែលជាអ្នកទទួលខុសត្រូវទៅលើការកំណត់គោលនយោបាយបរទេស គឺថាជាអ្នកសម្រេចទៅលើបញ្ហាទាំងនេះ?

[០៩:២៦:៥១]

**ឆ៖** ក្នុងឋានៈជាសមាជិកធម្មតានៅខាងក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំមិនអាចដឹងបានថា តើសេចក្តីសម្រេចអ្វីៗនៅកម្រិតថ្នាក់ដឹកនាំធ្វើដោយសមូហភាពតាមប្រជាធិបតេយ្យប្រមូលផ្តុំស្របតាមគោលការណ៍របស់បក្សយ៉ាងណានោះទេ ខ្ញុំមិនអាចដឹងបានទេ។ ប៉ុន្តែអ្វីដែលចេញពី ជាសម្រេចរបស់បក្ស ជាធម្មតាទេគឺថា ក្នុងឋានៈគាត់ជាលេខារបស់បក្ស គាត់ត្រូវតែទទួលខុសត្រូវចំពោះសេចក្តីសម្រេចរបស់បក្ស ដែលណែនាំឲ្យសមាជិកធម្មតារបស់បក្សអនុវត្តបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងពិភាក្សាអំពីបញ្ហា"សៀវភៅខ្មៅ" តាមអ្វីដែលលោកបានដឹងតាមអ្វីដែលលោកបានជម្រាបយើង ប៉ុល ពត ជាអ្នកដឹកនាំ ហើយជាអ្នកបញ្ជា ហើយជាអ្នកអនុម័ត គឺថាគ្មាននរណាម្នាក់អាចសម្រេច ឬក៏កែប្រែអ្វីបាននោះឡើយ។ តាមអ្វីដែលលោកបានឃើញ តើបក្សដែលធ្វើ -- ថាតើបក្សជាអ្នកធ្វើពង្រាងសៀវភៅខ្មៅ ឬក៏ ប៉ុល ពត គឺខ្លួនគាត់ផ្ទាល់តែម្នាក់ឯងនោះដែលជាអ្នកធ្វើពង្រាងសៀវភៅខ្មៅនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហភាគា ជម្រាបសួរលោកសាក្សី។ សំណួរនោះ -- សំណួរនេះត្រូវបានលោក កាណាវាស សួរពីមុនរួចមកហើយ ឥឡូវគាត់សួរឡើងម្តងទៀត ពីព្រោះគាត់ទើបតែទទួលបានចម្លើយដែលគាត់មិនចង់បាន។ ហើយដល់អ៊ីចឹងគាត់សួរសំណួរហ្នឹងដដែល។ សូមអរគុណលោកប្រធាន។

[០៩:២៨:៥៤]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន គឺយើងទទួលបានចម្លើយមួយទាក់ទងទៅនឹងចំណុចនេះ ហើយយើងទទួលបានចម្លើយមួយទៀតទៅនឹងចម្លើយដដែលនេះ។ ដូច្នេះវាហាក់ដូចជាមានការមិនស្របគ្នា ហេតុដូច្នេះហើយ

ដំណើការនេះ អ្វីដែលខ្ញុំធ្វើនេះគឺគ្រាន់តែចង់បញ្ជាក់ឲ្យមានការលម្អិតបន្ថែមទៅលើអ្វីដែលមិនស៊ីសង្វាក់គ្នានេះ។ ដូច្នេះ ខ្ញុំទុកសិទ្ធិសម្រេចដល់អង្គជំនុំជម្រះ ថាតើខ្ញុំអាចសួរសំណួរបែបនេះ ឬក៏បន្តទៅមុខទៀត?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៩:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មានមូលដ្ឋានត្រឹមត្រូវ។ សំណួរនេះពិតជាច្រំដែល ដូច្នេះសេចក្ដីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីការពារក្ដីអម្បាញ់មិញទេ។ ហើយទន្ទឹមនេះដែរ អង្គជំនុំសូមរំឭកមេធាវីថា គប្បីរៀបចំនូវសំណួរដែលនៅសេសសល់ ចៀសវាងឲ្យបានជាអតិបរមានូវសំណួរដែលច្រំដែល។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណចំពោះការរំឭក។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងបន្តទៅទំព័របន្ទាប់នៃឯកសារដដែលនេះ គឺលោកបានបញ្ជាក់ថា គេសួរនូវសំណួររបស់លោកអំពីលោក អៀង សារី ហើយលោកបាននិយាយថា "បាទ ពិតមែនហើយ គាត់ក៏ជាប្រធាននៃគណៈកម្មាធិការបរទេសនៃគណៈមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា។ ប៉ុន្តែ ចំពោះសកម្មភាពការងាររបស់គណៈកម្មាធិការនោះ ខ្ញុំមិនដឹងទេ។ ខ្ញុំសូមបន្ថែមថា នៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកុម្មុយនីស្ត វាជាការញើកញាប់ដែលស្ថាប័ននីមួយៗគ្រាន់តែជារូបភាពខាងក្រៅប៉ុណ្ណោះ ហើយមិនមានសមាជិកនោះទេក្រៅតែពីប្រធាន។ ដូចជាករណីនៃគណៈកម្មាធិការទំនាក់ទំនងកិច្ចការបរទេសដែលមានតែ អៀង សារី ម្នាក់នាក់ប៉ុណ្ណោះ ហើយដែលរាយការណ៍ដោយផ្ទាល់តែម្តងទៅ ប៉ុល ពត"។

តើលោកបានឃើញចម្លើយនេះដែរឬទេ លោកសាក្សី?

[០៩:៣១:៣៤]

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំបានឃើញចម្លើយនេះ ហើយខ្ញុំបាននិយាយដូច្នេះមែនបាទ។

**ស៖** នៅពេលដែលលោកនិយាយថា វាជាការសាមញ្ញទេដែលបក្សកុម្មុយនីស្ត ប្រទេសកុម្មុយនីស្ត គឺវាមានស្ថាប័នហ្នឹងគ្រាន់ជារូបភាពខាងក្រៅប៉ុណ្ណោះនោះ។ តើលោកអាចជម្រាបដែរឬទេថា នរណាគេជាអ្នកទទួលខុសត្រូវក្នុងការបង្កើតរូបភាពនេះ? ដោយសារតែលោកបាននិយាយថា អៀង សារី ជាអ្នករាយការណ៍ផ្ទាល់ទៅ ប៉ុល ពត។

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់អីទេបាទ។ ប៉ុន្តែបើតាមខ្ញុំចំណាំមើល គឺវាមានខ្សែ ក្នុងការចាត់តាំង វាមានខ្សែរយៈយ៉ាងដូច្នេះ។ គឺមាន ប៉ុល ពត គាត់ជាលេខារបស់បក្ស ហើយបន្ទាប់មកក្នុងការងារបរទេសមានលោក អៀង សារី ហើយក្រោមមកមានពួកខ្ញុំអីហ្នឹង គឺថានៅក្រោមបង្គាប់គាត់ជាកម្មាភិបាលនៅក្រសួងការបរទេសជាអ្នកអនុវត្តន។ យើងជាអ្នកអនុវត្ត មិនមែនជាអ្នកស្រេចទេបាទ។

[០៩:៣៣:១៩]

**ស៖** ក៏ប៉ុន្តែយើងបាននិយាយ និងពិភាក្សាចម្លើយរបស់លោកដែលនិយាយអំពីរូបភាពនេះ ដែលបានបង្កើតឡើង។ ដែលក្នុងនោះមានគណៈកម្មាធិការៗទំនាក់ទំនងកិច្ចការបរទេស ហើយលោកនិយាយថា វាជាគណៈកម្មាធិការមួយ។ តើនរណាគេជាអ្នកបង្កើតរូបភាពហ្នឹង? ឬក៏បង្កើតគណៈកម្មាធិការនេះដែលមាន អៀង សារី ជាប្រធាន ហើយត្រូវរាយការណ៍ដោយផ្ទាល់ទៅ ប៉ុល ពត។ តើលោកដឹងដែរឬទេ? បើសិនជាលោកដឹងមិនជាបញ្ហាអ្វីនោះទេ ក៏ប៉ុន្តែមិនដឹង -- បើលោកមិនដឹងនោះ មិនក៏ជាបញ្ហាអ្វីដែរ?

**ឆ៖** ខ្ញុំការចាត់តាំងយ៉ាងណាៗ ខ្ញុំមិនដឹងទេ ប៉ុន្តែថានៅកម្ពុជាប្រជាធិបតេយ្យក៏ដូចនៅប្រទេសសង្គមនិយមផ្សេងទៀត ក៏ក្រោមគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយនៅប្រទេសខ្លះ ដូចនៅប្រទេសចិន នៅវៀតណាមនោះ គេហៅការិយាល័យនយោបាយហ្នឹង ហើយនៅពីលើការិយាល័យនយោបាយហ្នឹងមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយតូច មានគ្នាបួនប្រាំនាក់ទៀត ដែលជាស្នូលនៃការដឹកនាំនៅៗក្នុងប្រទេសសង្គមនិយម ប្រទេសកុម្មុយនីស្តហ្នឹង។ ហើយនៅក្នុងបរិវេណមជ្ឈិមបក្សហ្នឹង វាមានគណៈកម្មាធិការតូចៗទៀត មានគណៈកម្មាធិការការបរទេស មានគណៈកម្មាធិការយោធា មានគណៈកម្មាធិការសេដ្ឋកិច្ចអីចឹង។ អាហ្នឹងវាតាមមើលទៅការចាត់តាំងហ្នឹង ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែថាជាការចាត់តាំងធម្មតាក្នុងបក្សកុម្មុយនីស្តនីមួយៗបាទ។ ប៉ុន្តែខ្ញុំបន្ថែម ខ្ញុំគ្រាន់តែដឹងថា គណៈកម្មការទាក់ទងបរទេស ខ្ញុំដឹងថា មានតែលោក អៀង សារី ជាប្រធានមួយ សមាជិកឯទៀត ដូចមិនដឹងទេ មិនដឹងមាន ឬក៏មិនមានទេ ប៉ុន្តែអត់មានដើរតួអីទេបាទ។

**ស៖** សូមអរគុណលោក។ ក៏ប៉ុន្តែខ្ញុំចង់សួរត្រង់ចំណុច នៅពេលនេះ លោកនិយាយចំណុចមួយផ្សេងមួយទៀត។ នៅក្នុងចម្លើយរបស់លោក លោកបានបញ្ជាក់ថា "វាគឺជារូបភាពមួយតែប៉ុណ្ណោះគ្មានសមាជិកណាក្រៅពីលោក អៀង សារី នោះទេ"។ នៅពេលនេះ លោកបាននិយាយថា លោកមិនស្គាល់ទេ សមាជិកផ្សេងទៀត នៅក្នុងគណៈកម្មាធិការនោះ មានអ្នកណាខ្លះ?

[០៩:៣៥:៥៧]

ដូច្នេះ នៅក្នុងឆ្នាំ៧៥ ដល់៧៩ តើលោកពិតជាបានដឹងថា មានគណៈកម្មាធិការទំនាក់ទំនងកិច្ចការបរទេសនេះ មានដែរឬ កើតឡើងដែរឬទេ? ហើយមានដំណើរការប្រតិបត្តិការយ៉ាងម៉េច? តើលោកដឹងច្បាស់ដែរឬទេ ដែលលោកថា វាជារូបភាពនោះ? បើសិនលោកដឹង លោកនិយាយឱ្យបានជាក់លាក់ សូមកុំឱ្យលោកធ្វើការទាយស្មាន?

**ឆ៖** ខ្ញុំថា មិនដឹងជាលោកមេធាវីយល់អំពីចាត់តាំងនៅប្រទេសកុម្មុយនីស្តយ៉ាងម៉េចទេ។ ប៉ុន្តែបើលោកមិនដឹង ខ្ញុំសូមប្រាប់លោកបន្តិចចុះ។ មិនមែនថាប្រទេសកម្ពុជាទេ នៅប្រទេសខ្លះ រណសិរ្សហ្នឹង មានឈ្មោះគណៈកម្មការនេះ គណៈកម្មការនោះ មែនទែនមានតែ១ប្រធានទេ ដែលសកម្ម បាទ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ ខ្ញុំសូមកាត់សម្តីសាក្សី ដោយសារតែលោកសាក្សីមិនឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ។ គាត់ព្យាយាមចំណាយពេលវេលារបស់ខ្ញុំ។ ដូច្នេះហើយ សាក្សីគួរតែឆ្លើយសំណួររបស់ខ្ញុំហើយសូមឱ្យធ្វើការឆ្លើយទៅនឹងសំណួរផ្ទាល់ដែលខ្ញុំបានសួរនេះ។

[០៩:៣៧:១៥]

**ប្រធានអង្គជំនុំ៖**

សាក្សី ឆ្លើយតបទៅនឹងសំណួរ ដែលសួរ ហើយខ្ញុំបានជម្រាបជូនលោករួចហើយ នៅក្នុងកិច្ចដំណើរការនេះ អ្វីដែលលោកដឹង គឺលោកឆ្លើយថា ដឹង។ អ្វីដែលមិនដឹង ឆ្លើយថាមិនដឹងទៅ។ ខ្លីទៅចប់ហើយ កាលណាអត្ថាធិប្បាយច្រើន នាំឱ្យមានបញ្ហាកាន់តែច្រើនឡើង កាន់តែស្មុគស្មាញ សម្ពាធលើអារម្មណ៍របស់លោក។

[០៩:៣៧:៣៨]

ទី២ សូមលោកមេធាវីរំឭកម្តងទៀត កត់សម្គាល់ឃើញថាសំណួរច្រំដែលច្រើន កើតឡើងនៅព្រឹកនេះ។ យើងកំពុងតែពិនិត្យពិចារណាលើបញ្ហានេះ ថាតើគួរតែប្រព្រឹត្តទៅយ៉ាងដូចម្តេច របៀបនៃ

វិធីសាស្ត្រក្នុងការតាំងសំណួរផ្តញ់នេះ? ធៀបជាមួយនឹងសំណួរច្រំដែល ហើយនិងសំណួរក្រៅអង្គហេតុផ្សេងៗដែលកើតមានក្នុងអំឡុងពេលនៃបទពិសោធន៍នៅក្នុងដំណើរការកន្លងមកនេះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គួរតែត្រូវបានពិនិត្យ និងចៀសវាងឲ្យបាន ដើម្បីបង្កើនល្បឿនកិច្ចដំណើរការនីតិវិធីសវនាការឲ្យប្រព្រឹត្តទៅ ដោយឆាប់រហ័ស និងមានប្រសិទ្ធភាព រួមវិភាគទានយ៉ាងជាក់ច្បាស់ យ៉ាងពិតប្រាកដក្នុងការស្វែងរកការពិត។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្តាយណាស់ដែលកាត់ផ្តាច់នៅពេលនេះ។ ប៉ុន្តែខាងមេធាវីការពារក្តីនោះ គាត់សួរសំណួរពាក់ព័ន្ធទៅនឹងគណៈកម្មាធិការកិច្ចការបរទេស ដែលពាក់ព័ន្ធទៅនឹងឯកសារដែលលេខ D143 ឬក៏ E3/371។ ក៏ប៉ុន្តែសាក្សីបាននិយាយនៅចំណុចផ្សេង នៅកន្លែងផ្សេងទៀត ឧទាហរណ៍ ដូចជាឯកសារលេខ E3/377 ឬ D166 ដូចថាមានការបញ្ជាក់ជាច្រើននៅក្នុងឯកសារនោះ។ ដូច្នេះ មេធាវីការពារក្តីសួរសំណួរនេះ គឺនាំឲ្យសាក្សីយល់ខុសហើយ ដោយមិនយល់ -- ដោយមិនគិតទៅដល់ចំណុចទាំងស្រុងនៃអ្វីដែលសាក្សីលោកបានឆ្លើយពាក់ព័ន្ធទៅនឹងគណៈកម្មការកិច្ចការបរទេសនេះ។

[០៩:៣៩:៣៧]

គឺដូចជានៅក្នុងឯកសារ E3/377 នៅទំព័រទី៤ ជាភាសាបារាំង--

**លោក ម៉ៃខល កាណាវ៉ាស៖**

*(គ្មានការបកប្រែ)*

[០៩:៣៩:៤៤]

**ប្រធានអង្គជំនុំ៖**

ឲ្យគេនិយាយសិន។ ឥឡូវឲ្យតំណាងសហព្រះរាជអាជ្ញានិយាយសិន!

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

ឥឡូវ ឲ្យនិយាយហ្នឹងសិន! តំណាងសហព្រះរាជអាជ្ញាអញ្ជើញ! អញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សាក្សីគាត់បានឆ្លើយដូចតទៅនេះ៖ ពាក់ព័ន្ធទៅនឹងគណៈកម្មាធិ-

ការកិច្ចការបរទេសគឺគាត់ទទួលបន្ទុកបក្សនិងបក្ស ដូច្នេះគាត់មានទំនាក់ទំនងសំខាន់ជាមួយនឹងប្រទេសកុម្មុយនីស្ត។ ចំណុចនេះវាផ្ទុយទៅនឹងចម្លើយផ្សេងទៀត។ ដូច្នេះដើម្បីឲ្យវាមានលក្ខណៈពេញលេញនោះ មេធាវីការពារក្តីត្រូវតែបង្ហាញនូវសម្រង់មួយនេះ ដើម្បីឲ្យសាក្សីគាត់អាចឆ្លើយបាន។ សូមអរគុណលោកប្រធាន។

**លោក ម៉ៃខល កាណាវាស៖**

ចំណុចនេះ គឺលើកឡើងដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាធ្វើអ៊ីចឹងរាល់តែពេលហើយគាត់លើកឡើងថា គួរតែយើងធ្វើដូច្នេះ។ ដូច្នេះសហព្រះរាជអាជ្ញាគួរតែធ្វើ និងលើកឡើងចំណុចនេះទៅ។ លោកប្រធានគួរតែណែនាំទៅដល់សហព្រះរាជអាជ្ញានៅក្នុងការតាំងសំណួររបស់គាត់ ដែលវាពាក់ព័ន្ធទៅនឹងនីតិវិធីតទល់នៅទីនេះ។ សហព្រះរាជអាជ្ញាជាអ្នកសួរសំណួរ។ ដូច្នេះហើយ វាជារឿងក្តី របស់គាត់ គាត់មិនអាចសួរសំណួរអស់នោះទេសម្រាប់ភាគីទាំងសងខាង។ ដូច្នេះហើយទើបភាគីម្ខាងទៀតសួរបន្ថែម។ ខ្ញុំធ្វើការដេញដោលផ្អែកទៅលើការសួររបស់សហព្រះរាជអាជ្ញា និងការឆ្លើយរបស់សាក្សី។

[០៩:៤២:០១]

ខ្ញុំមិនចាំបាច់ធ្វើការងារលើកឡើងតាមការណែនាំរបស់សហព្រះរាជអាជ្ញានោះទេ។ ដូច្នេះហើយប្រសិនបើចង់ឲ្យមានការសួរតទល់ម្តងទៀតនោះ គឺថាយើងខ្ញុំសូមថា យើងគួរតែធ្វើដូច្នេះ ក៏ប៉ុន្តែប្រសិនមិនចង់ យើងដឹងហើយនៅទីនេះគឺជាប្រព័ន្ធច្បាប់ស៊ីវិលឡូ ជាប្រព័ន្ធតទល់។ សហព្រះរាជអាជ្ញាជាអ្នកបង្ហាញរឿងក្តី ត្រូវបង្ហាញឯកសារ។ សំណួររបស់គាត់ផ្អែកទៅលើផ្នែកដែលពាក់ព័ន្ធ។ ដូច្នេះ បើសិនជាគាត់លើឡើងដូច្នេះ ហេតុអ្វីនៅពេលដែលគាត់សួរ គាត់មិនសួរសំណួរទាំងអស់នោះទៅ។ សហព្រះរាជអាជ្ញាអាចធ្វើការសួរបាននៅពេលវេលាដែលគាត់មាន។

[០៩:៤២:៤២]

ដូច្នេះហើយបានខ្ញុំចង់លើកសំណួរសួរសំណួរទាំងអស់នេះដែលវាពាក់ព័ន្ធនឹងចម្លើយដែលសាក្សីឆ្លើយក្នុងថ្ងៃនេះ។ គ្មាននរណាម្នាក់ចង់ឲ្យសាក្សីនេះយល់ខុសទៅលើចម្លើយរបស់គាត់នោះទេ យើងគ្រាន់តែសួរថា តើនរណាគេជាអ្នកបង្កើតគណៈកម្មាធិការនេះ? នេះជាសំណួរដែលខ្ញុំចង់សួរ។ ការតែងតាំងនោះយ៉ាងម៉េច? អ្នកណាជាអ្នកបង្កើត? ប្រសិនបើសាក្សីមិនដឹងនោះ ក៏មិនអីដែរ ប្រសិនជាដឹងនោះគឺជាការល្អ។ តែបើសិនមិនដឹងទេ ខ្ញុំនឹងតទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរ។

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំរៀបនឹងឆ្លើយហើយ ហើយមេធាវីមកកាត់ខ្ញុំទៅអស់ប៉ុន្មាននាទីលោកប្រធាន មើល៍ ១០ នាទី។ ថាខ្ញុំមិនវាដឹងទេ ក៏ប៉ុន្តែនៅរបបកុម្មុយនីស្តមានតែម្នាក់ទេ។ នេះអ្នកឯណាអត់មានទាំងអស់។ នេះបើតាមខ្ញុំដឹង អ្នកណាចាត់តាំងខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនមែននៅក្នុងគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ទេបាទ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណ។ នៅពេលនេះ ពាក់ព័ន្ធទៅនឹងសៀវភៅខ្មៅ តើមានដែលចែកជូនទៅដល់ភាគី និងបុគ្គលផ្សេងៗដែរឬទេនៅទូទាំងប្រទេសនោះ ក្រោយពេលបោះពុម្ពផ្សាយ? ហើយប្រសិនបើមានចែកចាយទូទាំងប្រទេសនោះ តើគេចែកចាយជាភាសាអ្វីដែរ?

**ឆ៖** ចំពោះខាងខ្ញុំៗ ដឹងថាសៀវភៅខ្មៅ ចែកចាយទៅបរទេស ទៅអន្តរជាតិ។ ត្រង់នៅក្នុងប្រទេសចែកចាយឲ្យអ្នកណា ហើយជាភាសាអ្នកណា អាហ្នឹងខ្ញុំមិនបានដឹងទេ ព្រោះមិនមែនជាមុខព្រួញរបស់ខ្ញុំបាទ។

[០៩:៤៤:៤៤]

**ស៖** សូមអរគុណ។ ហេតុផលដែលខ្ញុំសួរនេះ អុង ថុងហឿង នៅថ្ងៃទី៩ ខែសីហា បានលើកឡើងថា "ហោ ណាំហុង និង ពេជ ប៊ុនហុង បានចំណាយពេលយ៉ាងច្រើននៅក្នុងការបកប្រែសៀវភៅនេះជាភាសាខ្មែរ"។ ដូច្នេះ តាមការឆ្លើយរបស់លោក តើលោកដឹងទេ ថាតើគេចាត់ចែងទៅលើឯកសារនោះយ៉ាងម៉េចដើម្បីបកប្រែទៅជាភាសាផ្សេងនោះ?

**ឆ៖** ទេ។ លោកប្រធាន ខ្ញុំដូចជាអត់ស្វែយល់។ សៀវភៅនោះវាជាភាសាខ្មែរ ម៉េចបានបកមកជាខ្មែរវិញ? ហើយខ្ញុំមិនដឹងអ្នកណាបក? ចាំបាច់បកអី បើវាសៀវភៅដើម ច្បាប់ដើមជាខ្មែរ។

**ស៖** ចំណុចនេះហើយ ទើបខ្ញុំចង់សួរ វាជាចំណុចមួយគួរឲ្យយើងឆ្ងល់។ សូមអរគុណលោក។ នៅពេលពេលនេះ យើងចូលទៅដល់ប្រធានបទមួយទៀត ខ្ញុំចង់ត្រឡប់ការសួរសំណួរមួយចំនួនដែលខ្ញុំមិនទទួលបានចម្លើយពេញលេញ។ លោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោក ខ្ញុំយោងឯកសារ E3/372 ជាពិសេសខ្មែរ ERN 00290420 ដល់ 21, បារាំង គឺ 00294331 ដល់ 32, អង់គ្លេស គឺ

00290426។ ក្នុងនេះលោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោកថា "ជាការគោលការណ៍គឺដូច្នោះមែនក៏ប៉ុន្តែការអនុវត្តដោយសារក្មួយ ប៉ុល ពត គឺជាប្រធានការិយាល័យប្រធានមន្ទីរនោះ គឺគាត់ ក្មួយរបស់គាត់នោះ គឺអាចសម្រេចដោយមិនចាំបាច់ធ្វើការប្រឹក្សាជាមួយនឹង អៀង សារី នោះទេ។ កិច្ចការបរទេស ផ្នែកបរទេសក៏អ៊ីចឹងដែរ។

[០៩:៤៧:២៣]

បន្ទាប់មកបានលើកឡើងឧទាហរណ៍។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ៧៧ មានការសម្រេចផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងវៀតណាម លោកបាននិយាយដូច្នេះផងដែរ "តាមធម្មតាសេចក្តីប្រកាសនេះត្រូវធ្វើដោយនាយកដ្ឋានរបស់ខ្ញុំ។ គឺការពិតជាក់ស្តែង គឺខ្ញុំដឹងថានេះនៅពេលដែលគេបានប្រកាសរួចទៅហើយ គឺ គាត ឈន់ និង ជួន ប្រាសិទ្ធ ដែលជាអ្នកទទួលខុសត្រូវសរសេរសេចក្តីប្រកាសនេះក្រោមការដឹកនាំដោយផ្ទាល់ពី ប៉ុល ពត"។ ខ្ញុំចង់ផ្តោតទៅលើចំណុចនេះបន្តិចពាក់ព័ន្ធទៅនឹង សួរ ហុង។ ជាក់ស្តែងតាមចម្លើយរបស់លោក វាបង្ហាញឲ្យឃើញថា នៅពេលនោះ គឺលោកស្គាល់ថា សួរ ហុង នេះគឺជាក្មួយរបស់ ប៉ុល ពត ឬក៏គាត់ -- ឬក៏គាត់ដឹងថា គាត់ជាក្មួយ ប៉ុល ពត ក្រោយឆ្នាំ៧៩វិញទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំស្គាល់គាត់ថាជាក្មួយរបស់ ប៉ុល ពត បាទ។

[០៩:៤៨:៣២]

**ស៖** ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់គាត់ជាមួយនឹង ប៉ុល ពត ដោយផ្អែកចម្លើយដែលលោកបានឆ្លើយជូនយើងខ្ញុំ។ តើមានការខុសគ្នាយ៉ាងម៉េចជាមួយនឹង សួរ ហុង ដែលវាមានទំនាក់ទំនងជាមួយបុគ្គលមួយនៅក្នុងហ្នឹង? តើមានភាពខុសគ្នាដែរឬទេ?

**ឆ៖** តាមខ្ញុំដឹង ខ្ញុំស្គាល់គឺចំណងទាក់ទងជាកូនចៅ ជាក្មួយ ជាបងប្អូនអី មិនមានដើរតួនាទីក្នុងការគ្រប់គ្រង និងក្នុងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។ គឺដូច្នោះ ខ្ញុំថាមិនមានការទាក់ទងពិសេសរវាង សួរ ហុង -- អ៎!រវាង ប៉ុល ពត និង សួរ ហុង ក្នុងឋានៈជាមានិងក្មួយនោះទេ។ ក៏ប៉ុន្តែបើមានការទាក់ទងគឺថា ទាក់ទង គឺថា សួរ ហុង ជាអគ្គលេខាធិការក្រសួងការបរទេស ហើយទទួលបន្ទុកជាប្រធានមន្ទីរនៃក្រសួង។ ដូច្នោះបញ្ហាមួយចំនួន គឺថាគាត់មិនចាំបាច់ការ -- មិនចាំបាច់ឆ្លងតាមលោកអៀង សារី ទេ។ សេចក្តីសម្រេចរបស់ ប៉ុល ពត កន្លែងខ្លះមិនចាំបាច់ឆ្លងតាមលោក អៀង សារី គឺថាគាត់អាចបញ្ជាផ្ទាល់តាមរយៈ សួរ ហុង លោក សួរ ហុង តែម្តងបាទ។ អានេះជាការសង្កេតទេ ជាការសង្កេត ហើយជារបៀបគ្រប់គ្រងដឹកនាំនៅក្នុងពេលនោះបាទ។

**សៈ** សូមអរគុណ។ ដោយសារតែយើងកំពុងតែនិយាយអំពី សួរ ហុង នៅពេលនេះ យើងចង់ -- យើងខ្ញុំចង់បញ្ជាក់ទៅលើចំណុចមួយដែលពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់ កុយ ធួន។ វាទំនងជាបង្ហាញឱ្យយើងឃើញថា វាមានភាពពុំស៊ីសង្វាក់គ្នានៅក្នុងចម្លើយ ឬសក្ខីកម្មរបស់លោកដែលឆ្លើយពាក់ព័ន្ធទៅនឹង សួរ ហុង។ លោក សួរ ហុង បានបញ្ជាក់ថា “លោកនេះជាអ្នកផ្តល់ចម្លើយសារភាពរបស់ កុយ ធួន ទៅឱ្យគាត់”។ គឺយើងឃើញចំណុចនេះនៅក្នុងឯកសារ E3/413 ជាពិសេសត្រង់ចំណុចដែលយើងឃើញនៅក្នុងខ្មែរ ERN 00357530 ដល់ 31, អង់គ្លេស គឺ 00361014, បារាំងគឺ 00405456។

[០៩:៥១:៥០]

លោកបានជម្រាបយើងខ្ញុំថា នៅថ្ងៃទី០៧ ខែសីហា នោះលោកបានបញ្ជាក់ ឆ្លើយថា គឺ សួរ ហុង ជាអ្នកផ្តល់ចម្លើយសារភាព កុយ ធួន មកឱ្យលោក។ ចំណុចនេះនៅត្រង់ខ្មែរ លេខ 00832518, បារាំងគឺ 00833626 បារាំងគឺ (ស៊ីក) 00833510។ ខ្ញុំចង់សួរលោក ថាតើចម្លើយមួយណាដែលត្រឹមត្រូវ? អ្នកណាដែលជាអ្នកឆ្លើយត្រូវ ហើយអ្នកណាជាអ្នកឆ្លើយខុសនោះ? តើលោកជាអ្នកផ្តល់ចម្លើយសារភាព កុយ ធួន ទៅឱ្យ សួរ ហុង ឬក៏ សួរ ហុង ជាអ្នកផ្តល់ចម្លើយសារភាព កុយ ធួន មកឱ្យលោក?

**ធៈ** ទេ គឺនៅព្រឹកថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ ពេលខ្ញុំរៀបចាកចេញពីក្រសួងការបរទេស ពីប-១ មកក្រសួងឃោសនាការ ពេលនោះក្រសួងឃោសនាការមានឈ្មោះថា ក-៣៣ គឺលោក សួរ ហុង បានប្រគល់ចម្លើយសារភាពរបស់ កុយ ធួន មកឱ្យខ្ញុំ ហើយគាត់បានទាំងនិយាយថា ៥ថ្ងៃទៀតចាំជួបគ្នា។ នេះខ្ញុំតាមមើល គឺគាត់៥ថ្ងៃជួបគ្នាវា -- គាត់និយាយ មិនដឹងជាគាត់និយាយពិត ឬក៏និយាយលេងទេ។ ហើយខ្ញុំមិនដែលមានចម្លើយសារភាពអីទេ ព្រោះក្នុងឋានៈរបស់ខ្ញុំ ខ្ញុំមិនដែលបានទទួលចម្លើយសារភាពអីអីចឹងទេបាទ។ ដូច្នោះ ខ្ញុំមិនអាច គឺថាឱ្យចម្លើយសារភាពហ្នឹងទៅលោក សួរ ហុង បានទេបាទ។

[០៩:៥៤:០០]

**សៈ** សូមអរគុណ។ សូមអរគុណលោកដែលបានបញ្ជាក់ត្រង់ចំណុចនេះ។ នៅពេលនេះ ប្រសិនបើយើងចូលទៅដល់ប្រធានបទមួយទៀត ដែលយើងនៅតែនិយាយអំពីបញ្ហា -- និយាយអំពី ប៉ុល ពត ដដែល។ លោកបានបញ្ជាក់ជូនយើងខ្ញុំកាលពីមុនថា ប៉ុល ពត ជាអ្នកធ្វើសេចក្តីសម្រេច និង

ធ្វើការតែងតាំង ជាពិសេសគាត់គឺជាបុគ្គលមួយរូប ដែលពាក់ព័ន្ធទៅនឹងបញ្ហាជនដែលត្រឡប់មកចូលប្រទេសវិញ។ នៅពេលនេះ ខ្ញុំមានសំណួរមួយសួរទៅលោកពាក់ព័ន្ធទៅនឹងចម្លើយរបស់លោក ឆេនដ័ល័រ ហើយលោកអាចជួយផ្តល់ចម្លើយឲ្យយើងខ្ញុំត្រង់ចំណុចនេះបាទ។

លោក ឆេនដ័ល័រ គឺខ្ញុំយោងលើឯកសារ D108/50/1.75។ ERN ជាភាសាអង់គ្លេស 00193374 មិនមានការបកប្រែជាភាសាផ្សេងនោះទេ។ ហើយនេះគឺជាឯកសារដែលបានបង្ហាញជូនសាក្សីមួយទៀតផងដែរ។ នេះគឺជាអត្ថបទខ្លីមួយ ដែលពាក់ព័ន្ធទៅនឹង អុង ថុងហឿង ដែលលើកឡើងថា "ហុង ពាក់ព័ន្ធទៅនឹងមន្ទីរមួយ។ គាត់គឺពាក់ព័ន្ធជាមួយនឹង យូ.អ៊ិន.អ៊ី.ខេ អង្គការម៉ៅអ៊ិស្ត ដែលកូនរបស់ កុល ទូច ស្ថិតនៅក្នុងហ្នឹង។ សមាជិក៣០នាក់របស់ យូ.អ៊ិន.អ៊ី.ខេ រួមទាំងកូនប្រុសរបស់ ទូច ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ចូលប្រទេសកម្ពុជានៅក្នុងឆ្នាំ៧៣ ក្រោយពេលពិនិត្យដោយជនកម្ពុជានៅប៉េកាំង។ និស្សិតដូច ហឿង ដែលមានចំណងពាក់ព័ន្ធជាមួយនឹង យូ.អ៊ី.ខេ នោះត្រូវបានគេប្រាប់ឲ្យរង់ចាំ ហើយមិនបានវិលត្រឡប់មកផ្ទះរហូតទៅដល់ក្រោយខែមេសា ឆ្នាំ៧៥"។

[០៩:៥៦:៣២]

លោកបាននិយាយថា លោកនៅប៉េកាំងនៅក្នុងអំឡុងកាលបរិច្ឆេទនុំង។ តើលោកអាចបញ្ជាក់បំភ្លឺជូនយើងខ្ញុំបានដែរឬទេ តើ ដេវីដ ឆេនដ័ល័រ និយាយត្រឹមត្រូវដែរឬទេ ថានៅក្នុងឆ្នាំ៧៣នោះ គឺមានការពិនិត្យពិច័យដោយជនកម្ពុជា ដែលនៅឯប៉េកាំងនោះ? គឺមានការពិនិត្យពិច័យ ថាតើអ្នកណាខ្លះគួរវិលត្រឡប់មកកម្ពុជា? តើលោកគិតថាចំណុចនេះ គឺសរសេរត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺថាពេលនុំង គឺមាននិស្សិតច្រើន ហើយក្នុងនោះក៏មានទាំងកូនរបស់លោក កុល ទូច ឈ្មោះ កុល ដូរាធី បាទខ្ញុំស្គាល់ហើយ។ ហើយជាអ្នកដែលត្រៀមលក្ខណៈសម្បត្តិនៅប៉េកាំងត្រៀមចូលក្នុងប្រទេស នៅពេលនុំងប្រទេសមិនទាន់បានរំដោះទេ។ ហើយពួកនេះ គឺថារៀនហាត់ប្រាណ ហាត់រត់ ហាត់ដូចថា ដើរ ហាត់ជាកម្លាំងកាយ នេះដើម្បីទ្រាំទ្រការលំបាកពេលដែលចូលមកក្នុងប្រទេសវិញ។ ហ្នឹងមានដូច្នេះមែនបាទ។

[០៩:៥៨:០៥]

**ស៖** សំណួររបស់ខ្ញុំ ចង់សួរអំពីការពិនិត្យពិច័យនៅក្នុងពេលនោះ ថានរណាអាចវិលត្រឡប់មកប្រទេសកម្ពុជា នរណាមិនអាច? លោក ឆេនដ័ល័រ បានបញ្ជាក់ថានៅពេលនុំងនោះ មានការពិនិត្យជ្រើសរើសនូវទូតឯប៉េកាំងនោះ ទៅលើបុគ្គលណាដែលអាចវិលត្រឡប់មកប្រទេសកម្ពុជា។ តើ ដេវីដ

ឆេនដ៍ល័រ និយាយត្រង់ចំណុចនេះ គឺគាត់និយាយត្រឹមត្រូវដែរឬទេ? ហើយមានករណីហ្នឹងដែរឬទេ?

**ឆៈ** ឥឡូវលោកជឿ ដេវីដ ឆេនដ៍ល័រ ហើយជឿខ្ញុំ? បើខ្ញុំនៅក្នុងហ្នឹង ខ្ញុំជាអ្នករៀនសូត្រអីជាមួយពួកអស់ហ្នឹង។ ហើយអត់មានជ្រើសរើសអីទេ ព្រោះពួកហ្នឹងមក -- សុំមកប៉ុន្មាន គេបញ្ជូនមកទាំងអស់ហ្នឹង ព្រោះពួកហ្នឹង សុទ្ធតែគេស្ម័គ្រចិត្តតើ។ បាទ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

**សៈ** នេះគឺនៅក្នុងឆ្នាំ៧៣ ដែលមានករណីអ៊ីចឹង។ តើអ៊ីចឹងទេ ពេលដែលយើងកំពុងនិយាយពីបញ្ហាហ្នឹង គឺនៅក្នុងឆ្នាំ៧៣ តើអ៊ីចឹងទេ?

**ឆៈ** បាទ នៅក្នុង៧៣ បាទ។

[០៩:៥៩:២២]

**សៈ** សូមអរគុណ។ នៅពេលមួយនោះ លោកបាននិយាយប្រាប់យើងខ្ញុំតាមចម្លើយសក្ខីកម្មរបស់លោក នៅថ្ងៃទី០៦ ខែសីហា ខ្ញុំនិយាយខ្មែរ តាមទំព័រខ្មែរ 00832199 ទៅ 200, បារាំង 00833160 ទៅដល់ 62, អង់គ្លេសគឺ 00833272 ទៅដល់ 74។ លោកបានឆ្លើយថា "លេខាដែលនៅអមនឹងទូតនោះមានអំណាចជាក់ស្តែង។ តើលោកចាំថា លោកបានឆ្លើយដូច្នេះដែរឬទេ?

**ឆៈ** ខ្ញុំបានឆ្លើយថា លេខារបស់បក្សអមស្ថានទូត ហើយអាហ្នឹងជារចនាសម្ព័ន្ធចាត់តាំងរបស់បក្សកុម្មុយនីស្តអ៊ីចឹង គឺថាជាបក្សមានតួនាទីដឹកនាំ។ អ្នកណាជាលេខារបស់បក្ស អ្នកហ្នឹងដឹកនាំហើយមិនមែនឯកអគ្គរដ្ឋទូតទេបាទ។

[១០:០០:៤៨]

**សៈ** ឥឡូវនេះខ្ញុំចង់បន្តទៅឯកសារ E3/101 ដែលជាចម្លើយរបស់លោក គឺថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ហើយសង្ឃឹមថាលោកអាចបញ្ជាក់បន្ថែមទៀតទៅលើចម្លើយដែលលោកបានផ្តល់ឱ្យនោះ។ គឺបន្ថែមទៅលើចម្លើយរបស់ ដេវីដ ឆេនដ៍ល័រ ផងដែរ ដែលនិយាយអំពីលេខាទូតនោះ។ គេសួរលោកថា គឺERN មានលេខ -- ខ្ញុំនិយាយអំពីឯកសារ E3/101។ ERN មានលេខ 00290437 ដល់ 38 ជាភាសាខ្មែរ, ភាសាបារាំងគឺមានលេខ 00290449, ហើយភាសាអង់គ្លេសគឺមានលេខ 00290443។ ហើយនៅក្នុងចំណុចមួយនេះ គឺលោកបានបញ្ជាក់ថា "គឺគ្រប់គ្នាត្រូវឆ្លងកាត់តាមស្ថានទូតកម្ពុជាប្រចាំនៅប៉េកាំង ដោយការទំនាក់ទំនងរវាងស្ថានទូតទាំងឡាយ និងភ្នំពេញ ត្រូវបានធ្វើឡើងតាមរយៈខ្សែពីរ។ ខ្សែបក្ស និងខ្សែរដ្ឋ ឬរដ្ឋាភិបាល។ វាអាចថា ការណែនាំ ឬបញ្ជាត្រូវបានបញ្ជូនដោយ ប៉ុល ពត ទៅសាខាបក្សនៅប៉េកាំង"។ តើលោកបានឃើញចម្លើយរបស់លោកនេះដែរឬទេ លោកសាក្សី?

[១០:០២:៤៤]

**ឆ៖** បាទ ខ្ញុំបានឃើញចម្លើយនេះ។

**ស៖** ដូច្នេះអំឡុងពេលដែលលោកនិយាយនៅទីនេះ ថាតើនៅក្រោយ៧៥ ឬមួយក៏រួមបញ្ចូលទាំងរយៈពេលមុនឆ្នាំ៧៥ ផងដែរនោះ?

**ឆ៖** លោកប្រធាន មុន៧៥ ដូចបក្សកុម្មុយនីស្តកម្ពុជាដូចទាន់យកអំណាចទេ។ ហេតុអីបានជាកាត់ -- លោកមេធាវីសួរនេះ ដូចខ្ញុំឆ្ងល់ដែរណ៎ា?

**ប្រធានអង្គជំនុំ៖**

អាចមានពីរ សំណួរមុនគឺសំណួរ៧៣។ ឥឡូវសំណួរនេះគឺយើងអត់បាន -- ដោយសារចម្លើយរបស់លោកមិនបានបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់ទេ។ អ៊ីចឹងគាត់ មេធាវីសួរហ្នឹងត្រឹមត្រូវហើយ។

លោកពិនិត្យនូវខ្លឹមសារនៃចម្លើយរបស់លោកឆ្លើយទៅ ហើយស្តាប់សំណួរឲ្យបាន ហើយនិងលោកអាចឆ្លើយតបបានហើយ។

[១០:០៣:៥៨]

**លោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី តើលោកដឹងដែរទេ ថាតើមានការណែនាំដែលផ្តល់ឲ្យដោយ ប៉ុល ពត ទៅដល់សាខាបក្សនៅប៉េកាំងមុនឆ្នាំ៧៥ ពាក់ព័ន្ធទៅនឹងការត្រឡប់មកប្រទេសវិញរបស់ពួកបញ្ញាជន តើលោកចាំថាមានបញ្ហានេះដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** មុនឆ្នាំ១៩៧៥ ទូតរបស់កម្ពុជាទាំងអស់គឺថាជាទូតរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានសម្តេច នរោត្តម សីហនុ ព្រះអង្គជាប្រធាន ដូច្នោះមិនមានទាក់ទងអីជាមួយបក្សកុម្មុយនីស្តកម្ពុជាទេ។ បក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងប្រទេស និងដឹកនាំប្រទេសចាប់តាំងពីថ្ងៃទី១៧ មេសា ១៩៧៥ មកបាទ។

**ស៖** សូមអរគុណ។ ហើយខ្ញុំមានសំណួរចុងក្រោយសម្រាប់ប្រធានបទមួយនេះ គឺថានៅទីក្រុងប៉េកាំងមុនឆ្នាំ៧៥ គឺថាសាខាបក្សនៅទីក្រុងប៉េកាំងមុនឆ្នាំ៧៥ តើមានដែរឬទេ?

**ឆ៖** បាទ មុន៧៥ បក្សកុម្មុយនីស្តកម្ពុជាមានសាខានៅប្រចាំទីក្រុងប៉េកាំងមួយ គឺថាមានលោកស្រី សៀន អាន គឺជាលេខាបក្ស។

**សៈ** ថាតើគាត់នៅបន្តតួនាទីជាលេខាក្រោយឆ្នាំ៧៥ ដែរឬទេ?

**ឆៈ** ទេ ដល់៧៥ ឆ្នាំ៧៥គាត់ត្រឡប់មកនៅជាមួយនឹង -- តាមខ្ញុំចាំ គាត់ត្រឡប់មកក្នុងប្រទេសវិញហើយបាទ។ គាត់អត់មានបន្តលេខាអីទេ ពីអានេះលេខានៅប៉េកាំង មិនមែននៅលេខានៅស្ថានទូតទេបាទ។

[១០:០៦:៣៥]

**សៈ** តើលោកដឹងដែរឬទេ ថាតើអ្នកជាអ្នកណាធ្វើការសម្រេចចិត្តផ្លាស់ប្តូរតំណែងរបស់គាត់ ឬមួយក៏គាត់ខ្លួនគាត់ផ្ទាល់សម្រេចចិត្តត្រឡប់មកវិញ?

**ឆៈ** ខ្ញុំមិនបានដឹងអ្នកណាផ្លាស់ប្តូរតំណែងរបស់គាត់ ប៉ុន្តែពេលនោះ ខ្ញុំដឹងថាប្តីគាត់ លោក សៀន អាន ហ្នឹងធ្វើជាឯកអគ្គរដ្ឋទូតរបស់រដ្ឋាភិបាល រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំទីក្រុងហាណូយ បាទ។ ដូច្នោះគាត់អាចត្រឡប់មកទីក្រុងហាណូយដែរបាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមពិភាក្សាអំពីប្រធានបទថ្មីមួយពាក់ព័ន្ធទៅនឹង ប៉ុល ពត ផងដែរ។ គេចោទសួរនូវសំណួរជាច្រើនចំពោះលោកពាក់ព័ន្ធទៅនឹងកម្មាភិបាលមូលដ្ឋានដែលត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស ហើយនិងមានការនិយាយយោងទៅលើ កែ គឹមហួត។ ខ្ញុំចង់សួរសំណួរលោកពាក់ព័ន្ធទៅនឹងចំណុចមួយនេះ។ លោកបានបញ្ជាក់នៅក្នុងសក្ខីកម្មរបស់លោកនៅថ្ងៃ០៧ ខែ៨ គឺភាសាខ្មែរមានលេខ 00832525 ដល់ 26, បារាំងគឺមាន 008333 -- អ៎! 3639, ហើយភាសាអង់គ្លេសគឺមាន 00833521 ដល់ 22។ លោកបានបញ្ជាក់ថា "លោក អៀង សារី គឺហាក់ដូចជាអ្នករដ្ឋបាលដែលគ្រប់គ្រងទៅលើការបញ្ជូនការងារ។ ប៉ុន្តែសេចក្តីសម្រេចសំខាន់ -- ប៉ុន្តែសម្រេចគឺថា ប៉ុល ពត។ គាត់សម្រេចទាំងអស់ អ្នកណាត្រូវមក អ្នកណាត្រូវទៅ គឺថាគាត់សម្រេចទាំងអស់។ ដូច្នេះអ្នកណា -- ដូច្នេះរឿងពិធីការធ្វើម៉េចត្រូវតំណាងឲ្យប្រទេសមួយៗហ្នឹង មានស្អីដែលចាំបាច់ត្រូវហ្នឹង គឺសំខាន់ពិធីការធ្វើសារតាំងអ្វីហ្នឹង គឺថា ដូច្នេះក្នុងហ្នឹងក៏មានលោកមួយចំនួន"។ តើលោកចាំថាលោកបាននិយាយនូវសក្ខីកម្មបែបនេះនៅក្នុងតុលាការដែរឬទេ?

[១០:០៩:២៥]

**ឆៈ** កម្មាភិបាលមូលដ្ឋាន ដែលត្រូវមកក្រសួងការបរទេស គឺមិនមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក អៀង សារី ទេ ព្រោះគាត់ជាកម្មាភិបាលមូលដ្ឋាន។ ដូច្នោះ អ្នកគ្រប់គ្រងហ្នឹងគឺថាជាគណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស។ អាហ្នឹងច្បាស់ហើយ។ ហើយការតែងតាំងឲ្យគាត់ទៅធ្វើស្អីៗទូតអីទៅ

ត្រង់ណា ក៏ៗ គឺថាមជ្ឈិមបក្សដែរ មិនមែនលោក អៀង សារី ជាអ្នកតែងតាំងទេ។ លោក អៀង សារី គ្រាន់តែអ្នក ដូចថា គេយកមកផ្ញើទៅ កន្លែងដែលសមស្របមកផ្ញើ វាត្រូវទៅធ្វើទូត វាត្រូវយកមកផ្ញើមកប-១ ហ្នឹងហើយ ដើម្បី -- ព្រោះខ្ញុំផ្ទាល់ កម្មាភិបាលហ្នឹង ខ្ញុំកាន់សម្ភារៈ ខ្ញុំជូនគាត់ គឺថា វិទ្យុ ម៉ាញ៉េ ឬស្អីៗ ដែលនេះ ខ្ញុំជូនគាត់មួយៗ។ អ៊ីចឹង ខ្ញុំអ្នកជូនគាត់ផ្ទាល់ ព្រោះកម្មាភិបាលទាំងនោះ គាត់មកភ្នំពេញ គាត់មិនសូវដែល -- គឺគ្រាន់តែនៅមូលដ្ឋានមុននឹងចូលធ្វើការ គាត់មកនៅ គាត់មកប្រជុំគ្នានៅបន្ទប់ខ្ញុំ។ ព្រោះនៅក្រសួងការបរទេស បន្ទប់ខ្ញុំគឺថានៅឡើងជណ្ដើរចូលមក គឺបន្ទប់ខ្ញុំទី១ហើយ។ ដូច្នោះ ខ្ញុំចង់ជម្រាបថា ក្រសួងការបរទេស គ្រាន់ជាៗការឆ្លងកាត់ទេ មិនមែនជាអ្នកសម្រេចអីទាំងអស់ទេបាទ។

[១០:១១:០៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងសូមត្រឡប់ទៅលើចម្លើយរបស់លោក ដែលលោកបានផ្ដល់នៅក្នុងចម្លើយរបស់លោក លោកបាននិយាយថា “សេចក្ដីសម្រេចធ្វើឡើងដោយ ប៉ុល ពត” លោកមិនបាននិយាយអំពីគណៈអចិន្ត្រៃយ៍នោះទេ។ នេះជាចំណុចទី១របស់ខ្ញុំ គឺលោកផ្ដល់សក្ខីកម្មនៅថ្ងៃ០៧ ខែ៨ ហើយឥឡូវនេះ ប្រសិនបើលោកមើលឯកសារដែលមានលេខ E3/42 គឺជាចម្លើយរបស់លោក នៅថ្ងៃ០៦ ខែ៥ ឆ្នាំ២០០៩។ ខ្ញុំនិយាយអំពីភាសាខ្មែរ 00327207 ដល់ 09, ភាសាបារាំងគឺមាន 00327227 ដល់ 28 ឬក៏អាចថាទៅដល់ 29 ហើយនិងភាសាមួយទៀត គឺ 00327218 ដល់ 19។ ហើយនៅចំណុចនេះ គេសួរលោកអំពីមតិយោបល់ទាក់ទងទៅនឹងការថ្លែងរបស់ៗ -- ហើយនៅចំណុចនេះ លោកបាននិយាយថា -- លោកនិយាយថា លោកមានចម្លើយនៅក្នុងសេចក្ដីព្រាងឯកសាររបស់លោក ដែលនិយាយថា “ក្រសួងការបរទេសបន្ទប់រង់ចាំសេចក្ដីសម្លាប់” សញ្ញាសួរ(?) ទំព័រ១៥៤ តើអ្វីដែលខ្ញុំអាចនិយាយបាន គឺថាកម្មាភិបាល ដែល រ៉ូឡង់ ពិច បាននិយាយនៅក្នុងសៀវភៅគាត់ គឺជាកម្មាភិបាលមកពីតំបន់ ហើយមានបញ្ហានៅក្នុងតំបន់របស់ពួកគេ។ ពួកគេត្រូវបានកោះហៅ ដើម្បីទៅធ្វើជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យនៅបរទេស។ ពួកគេទទួលការបណ្ដុះបណ្ដាលផ្នែកការទូតនៅក្រសួងការបរទេស។ ប៉ុន្តែសេចក្ដីសម្រេចហៅពួកគេមកភ្នំពេញ និងតែងតាំងជាអគ្គរដ្ឋទូត គឺហួសពីសមត្ថកិច្ចរបស់ក្រសួងការបរទេស។ វាគឺជាសមត្ថកិច្ចរបស់មន្ទីរ៨៧០។ និយាយឲ្យចំទៅ គឺ ប៉ុល ពត។ នេះ គឺជាលក្ខណៈរួមនៃរបបកុម្មុយនីស្ដទាំងអស់។

[១០:១៣:៥២]

ហើយលោកបាននិយាយបន្តទៀត ទាក់ទងទៅនឹង កែ គឹមហួត។ ដូច្នេះ នៅត្រង់ចំណុចនេះ វាហាក់ដូចជាបង្ហាញថា លោកនិយាយថា គឺ ប៉ុល ពត គឺជាអ្នកធ្វើសេចក្ដីសម្រេច។ តើលោកនៅរក្សាចម្លើយរបស់លោកដែលបានផ្ដល់ឱ្យទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃ០៦ ខែ៥ ដែរឬទេ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅដែលមិនទាន់បានបោះពុម្ពផ្សាយរបស់លោកនោះ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា កម្មាភិបាលទាំងនោះ ជាកម្មាភិបាលមូលដ្ឋាន។ ដូច្នោះ មិនមែនលោក អៀង សារី គាត់ជាអ្នកគ្រប់គ្រងទេ។ បាទ ដូច្នោះមាននរណា? បើៗសិនជាលោក អៀង សារី គ្មាន -- ដូចថា មិនបានចាត់តាំងទៅណាៗ មានអ្នកណាក្រៅពីលោក អៀង សារី លើ -- នៅលើពីគាត់មានតែ ប៉ុល ពត នេះឯង មានអ្នកណាទៀត។ ដូច្នេះ ប៉ុល ពត គាត់សម្រេចកោះហៅមកក្រសួង អ្នកណាពីតំបន់ផ្សេងៗ ហើយដូច -- ហើយចាត់ចែងទៅធ្វើទូតនៅឯណាក៏ត្រូវស្រេចតែគាត់ដែរបាទ។ នេះខ្ញុំៗនៅរក្សាទុកចម្លើយរបស់ខ្ញុំយ៉ាងដូច្នេះ។

**ស៖** សូមអរគុណ។ ដូច្នេះ ចម្លើយរបស់លោកក៏អាចនិយាយផងដែរថា ពាក់ព័ន្ធទៅនឹងលោក កែ គឹមហួត តើមែនដែរឬទេ?

**ឆ៖** បាទ ដូច្នោះមែន ហើយនៅក្នុងសៀវភៅរបស់ខ្ញុំគឺខ្ញុំដាក់ចំណងជើង លោកប្រធានសុំ -- ខ្ញុំដាក់ចំណងជើងថា "*អ៊ីល ហ្វូត៍ រ៉ង់ដ្រ អា សេហ្សារ សេ គី អាប់ប៉ាដែរ អា សេហ្សារ*" ជាភាសាបារាំងគឺថា "អ្នកណាដែលធ្វើអ្វី ត្រូវប្រគល់ -- ត្រូវទទួលខុសត្រូវចំពោះអ្វីដែលបានធ្វើ" បើនិយាយឱ្យចំទៅ បើខ្មែរយើងតែងនិយាយថា "ក្បាលអ្នកណា សក់អ្នកហ្នឹង"។ ខ្ញុំនិយាយនេះមិនមែនខ្ញុំចង់ការពារអ្នកណា ឬលម្អៀងទៅអ្នកណាទេ។ ខ្ញុំចង់នេះឱ្យៗរកយុត្តិធម៌ពិតប្រាកដអ្វីដែលខ្ញុំបានធ្វើ។ អ្វីដែលខ្ញុំបានឃើញ ខ្ញុំបានជម្រាបដោយអត់លម្អៀងទេបាទ។

[១០:១៦:២៤]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីឯកសារដែលខ្ញុំបានបង្ហាញជូនលោក គឺឯកសារដែលបង្ហាញដោយមេធាវីការពារក្រុម នួន ជា ហើយខ្ញុំសុំសួរទៅលើសំណួរមួយចំនួន ហើយខ្ញុំចង់និយាយអំពីឯកសារ D199/26.2.80។ ហើយនេះគឺជាទូរលេខ។ ហើយនិយាយអំពីទស្សនកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការបរទេសថៃនៅភ្នំពេញ។ គឺវាមាន -- គឺជាឯកសារដែលមានពីរទំព័រ ហើយខ្ញុំសូមនិយាយយោងទៅដល់ទំព័រទី២។ ហើយនៅក្នុងនេះគឺមាននិយាយអំពីលោក ដែលលោកអាចមើល

ឃើញនៅត្រង់ឯកសារនេះ។ ហើយយើងរកឃើញនូវត្រង់ប្រតិចារឹកទំព័រ១៨-១៩, ភាសាបារាំង ២៤ ដល់ ២៥, អង់គ្លេស ២៣ ហើយជាប្រយោគនៅក្នុងទំព័រ -- នៅក្នុងកថាខណ្ឌទី២។ ខ្ញុំអាចអានលេខ ERN ប្រសិនបើចាំបាច់ ប៉ុន្តែនេះគឺជាអ្វីដែលបានសរសេរមកលោក។

"លោក ប៉ុល ពត មានអំណាចពិតប្រាកដ ផ្ដាច់មុខ ជាមនុស្សដែលមានសមត្ថភាពមុតមាំនៅក្នុងការសម្រេច និងមានទំនុកចិត្តចំពោះខ្លួនឯង។ និយាយដោយសព្វនាមជាបុរសទី១ ដូចជាគាត់ចង់បង្ហាញយ៉ាងគេច្បាស់ គឺគាត់បានដឹកនាំការពារប្រទេសរបស់ -- ដឹកនាំកិច្ចការរបស់ប្រទេសខ្លួនតាំងពីឆ្នាំ១៩៧៥ មក"។

[១០:១៨:៣៧]

ដូចគ្នាផង គាត់ក៏ចង់បង្ហាញផងដែរ "ថាគាត់ជាអ្នកអនុម័តយកនយោបាយមិត្តភាពជាមួយប្រទេសថៃដែលបានបញ្ជាក់ថា គឺរូបគាត់សម្រេចបញ្ជូនលោក អៀង សារី ទៅកាន់ទីក្រុងបាងកកនៅខែតុលា ឆ្នាំ១៩៧៥។ ម្យ៉ាងវិញទៀតលោក អៀង សារី បានតាំងខ្លួនជាថ្នាក់ក្រោមដែលស្ដាប់បង្គាប់ដោយតែងតែបដិសេធ មិនធ្វើការឆ្លើយតបភ្លាមៗឡើយ។ ហើយគាត់ហាក់ដូចជាតែងតែចង់បញ្ជូនបញ្ហាដែលត្រូវឆ្លើយតបនោះទៅកាន់អាជ្ញាធរថ្នាក់ខ្ពស់ ឬអាជ្ញាធរសហសេវិកតា។ នៅក្នុងការពិភាក្សាលោក អៀង សារី ក៏សង្កត់ធ្ងន់ផងដែរលើលោក ជួន ប្រាសិទ្ធ និង គាត ឈន់ ដែលជាឥស្សរជនចាស់ទុំ ប៉ុន្តែពួកគាត់មិនត្រូវបានគេបញ្ជាក់អំពីមុខងារនៅក្នុងក្រសួងការបរទេសនោះទេ"។

[១០:១៩:៤១]

ឥឡូវនេះ ផ្អែកទៅលើសក្ខីកម្មរបស់លោកគឺបានបញ្ជាក់ថាលោកមិនមានវត្តមាន គឺថាលោកមិនបានចូលរួមដោយផ្ទាល់នៅក្នុងកិច្ចប្រជុំនោះទេ។ ដូច្នេះលោកប្រហែលជាមិនអាចពិនិត្យមើល ឬក៏អាចបញ្ជាក់បាន -- ប៉ុន្តែលោកបានបញ្ជាក់ថា លោកបានធ្វើការនៅក្នុងក្រសួងការបរទេសពីឆ្នាំ៧៥ ដល់ ១៩៧៩។ ហើយលោកបានប្រាប់យើងថា លោកបានប្រាប់យើងថា លោកបានស្គាល់លោក អៀង សារី ក៏ដូចជាលោក ប៉ុល ពត ផងដែរ។ សំណួររបស់ខ្ញុំគឺថា នៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួមនានា កិច្ចប្រជុំផ្សេងៗ។ តើ ប៉ុល ពត ពិតជាបានបង្ហាញនូវសមត្ថភាព លក្ខណៈជាមនុស្សដែលមានសមត្ថភាពមុតមាំក្នុងការសម្រេចចិត្ត និងមានទំនុកចិត្ត ក្នុងការដែលអ្នកដឹកនាំកិច្ចការប្រទេសរបស់ខ្លួនដែរឬទេ តើនៅពេលដែលលោកជួបនោះ?

[១០:២០:៤៤]

**ផ៖** ទេ តាមខ្ញុំស្គាល់គាត់ ដូចមិនមានជាអ្នកអួតអាងអីចឹងទេ។ បាទ គាត់មិនដែលសម្តែង ជាបុគ្គលគាត់មិនអីចឹងទេ ប៉ុន្តែថាការដឹកនាំរបស់គាត់ក្នុងឋានៈជាលេខារបស់បក្សហ្នឹង គឺថាទាំងអស់គ្នាទទួលយល់ព្រមទាំងអស់គ្នាហ្នឹង តាំងពីអ្នកដឹកនាំ សហការីរបស់គាត់ រហូតទៅដល់ពួកយើងខ្ញុំ ក៏ទទួលយល់ព្រម។ ដូច្នោះ ដែលជាបុគ្គលខ្ញុំមិនមានដូចថា មិន -- មិនមានដូចថា -- ខ្ញុំមិនដឹងថា ក្នុងពេលដែលប្រជុំទទួលរដ្ឋមន្ត្រីការបរទេសថៃហ្នឹង មាន ប៉ុល ពត ហ្នឹង ខ្ញុំមិនដែលចូលទេបាទ។ ព្រោះនេះគឺថាជាការណ៍-- ហើយក្នុងឋានៈគាត់ ជារដ្ឋមន្ត្រីទី១ ទទួលពេលនោះ ក្នុងឋានៈគាត់ជារដ្ឋមន្ត្រីទី១ ជានាយករដ្ឋមន្ត្រី ពេលនោះគេហៅរដ្ឋមន្ត្រីទី១ ទទួលរដ្ឋមន្ត្រីក្រសួងការបរទេសថៃ។ ហើយធម្មតាទេគឺថារដ្ឋមន្ត្រីទី១ តែងតែចាត់តាំង ហើយសម្រេចបញ្ជូនរដ្ឋមន្ត្រីការបរទេសទៅប្រទេសនោះ ទៅប្រទេសនេះអាហ្នឹងជាការធម្មតាក្នុងការចាត់តាំង ហើយតាមខ្ញុំមើលទៅគាត់មិនមានបញ្ចេញអី ស្នាដៃអីទេ ព្រោះគាត់ -- និយាយឲ្យត្រង់ទៅគឺថា--

**ស៖** ខ្ញុំសូមទោស ខ្ញុំសូមកាត់លោកត្រឹមនេះ ព្រោះថា -- ខ្ញុំចង់សួរថាតើលោកធ្លាប់ឃើញ ប៉ុល ពត មានលក្ខណៈដូចអ្វីដែលខ្ញុំ ដូចដែលបានពិពណ៌នានៅទីនេះដែរឬទេ? ដូច្នេះ អ្វីៗពាក់ព័ន្ធនឹងការប្រជុំជាមួយប្រទេសថៃ ជាមួយរដ្ឋមន្ត្រីថៃហ្នឹង គឺថាលោកធ្វើការស្មានៗទេ។ ប៉ុន្តែខ្ញុំចង់សួរថា តើលោកគិតថា ប៉ុល ពត ជាមនុស្សបែបនេះដែរឬទេ?

[១០:២២:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:២២:៥៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសាក្សីទើបតែឆ្លើយទៅនឹងសំណួរនេះហើយ ហើយឥឡូវសំណួរនេះ ជាសំណួរច្រំដែលហើយ។ ខ្ញុំគួរតែងើបពីមុន ពីព្រោះថា ការសួរនេះសួរឲ្យសាក្សីធ្វើការសន្និដ្ឋាន ហើយសំណួរនេះក៏មិនសូវច្បាស់ដែរ។ ពីព្រោះថា គេមិនដឹងថា តើកិច្ចប្រជុំណាដែលគាត់បានចូលឲ្យច្បាស់នោះ ហើយខាងមេធាវីការពារក្តីក៏មិននិយាយថាសំដៅដល់កិច្ចប្រជុំមួយណាឲ្យច្បាស់ដែរ។ ដូច្នេះ ខ្ញុំគិតថា សំណួរនេះត្រូវបានឆ្លើយរួចមកហើយ ហើយជាសំណួរច្រំដែល។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់សួរថាតើមានកិច្ចប្រជុំបែបនេះដែរឬទេ? ហើយប្រសិនបើមានតើយ៉ាងម៉េចដែរ? ថាតើលោក ប៉ុល ពត មានលក្ខណៈបែបណាដែរ បែបនេះ ឬក៏បែបនោះ ប្រសិនបើគេនិយាយថាជាសំណួរដដែលៗ ខ្ញុំសូមបន្តទៅមុខទៀត។ ដូច្នេះ ខ្ញុំបន្តទៅចំណុចផ្សេង។

[១០:២៣:៥៨]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ លោកបាននិយាយអំពីការដែលលោកស្គាល់ ប៉ុល ពត យ៉ាងច្បាស់។ លោកបាននិយាយបែបនេះនៅថ្ងៃ១៦ ខែ៨ ដែលលោកនិយាយថាលោកស្គាល់គាត់ដោយផ្ទាល់។ ហើយលោកមិនខ្លាចគាត់នោះឡើយ។ ហើយវាមាននៅក្នុងប្រតិចារឹកទំព័រ២៤-២៥ ជាភាសាខ្មែរ ហើយភាសាអង់គ្លេសគឺ៣២ ដល់៣៣ ហើយភាសាអង់គ្លេស (ស៊ីក) គឺ ៣០។ ហើយលោកបានបញ្ជាក់ថា "ខ្ញុំបានដឹងអំពីអ្វីដែលបានកើតឡើងនៅក្នុងរបប -- គឺទើបតែដឹងនៅក្រោយឆ្នាំ៧៩ ប៉ុណ្ណោះ។ ហើយប្រសិនបើនៅក្នុងរបបនោះ ខ្ញុំប្រហែលជាមិនហ៊ានបដិសេធនោះឡើយ"។ អានេះគឺជាអ្វីដែលលោកនិយាយពី ប៉ុល ពត ពីការធ្វើការសម្រេចផ្លូវចិត្តរបស់ ប៉ុល ពត។

[១០:២៥:០០]

ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយ ខ្ញុំចង់បញ្ជាក់បំភ្លឺ ទៅលើចំណុចមួយចំនួន។ នៅថ្ងៃ០៨ ខែ៨ ឆ្នាំ២០១២ លោកបានប្រាប់យើងថា គឺថាចម្លើយរបស់លោកហ្នឹងគឺមាននៅ ERN 00834205, ភាសាបារាំង គឺមានលេខ 00834407 និងភាសាអង់គ្លេស 00834298។ លោកបាននិយាយថា "ខ្ញុំនៅក្នុងទីក្រុងប៉េងកាំង ខ្ញុំមិនអាចប៉ាន់ស្មានថា ប៉ុល ពត ដែលមានឈ្មោះដើមថា សាឡុត ស គឺពិតជាលេខាបក្សនោះទេ"។ គឺលោកគិតថា "ប៉ុល ពត ឬក៏ អៀង សារី ទេដែលជាលេខា -- បាទ ខៀវ សំផន ឬ អៀង សារី ទេដែលជាលេខាបក្ស។ ប៉ុន្តែតាមពិត គឺ ប៉ុល ពត។ ដូច្នេះ ខ្ញុំមិនអាចនិយាយឲ្យបានច្បាស់ ហើយខ្ញុំមិនអាចឆ្លើយតបឲ្យបានលម្អិតទៅលើសំណួរនេះបានឡើយ"។ ដូច្នេះ សំណួររបស់ខ្ញុំ គឺថាតើលោកចូលរួមពាក់ព័ន្ធទៅនឹងការងារនយោបាយ ការងារបក្ស ទាំងសកម្មភាពនៅទីក្រុងប៉េកាំង ទីក្រុងបារាំង ហើយលោកដឹង ហើយស្គាល់ ប៉ុល ពត យ៉ាងច្បាស់ នេះគឺជាអ្វីដែលលោកបានប្រាប់យើង។ ប៉ុន្តែខ្ញុំចង់ដឹងថា តើហេតុអីក៏លោកមិនអាចស្មានដឹង ស្មានត្រូវថា ប៉ុល ពត គឺជាលេខាបក្ស ដែលលោកគឺជាសមាជិកបក្សផងដែរហ្នឹង? ហេតុអ្វីក៏លោកមិនអាចស្មានដឹង ឬក៏លោកមិន

អាចប៉ាន់ប្រមាណបាន?

[១០:២៦:៥១]

**ឆ៖** ខ្ញុំមិនអាចប៉ាន់ប្រមាណបាន គឺស្រួលយល់ទេ ព្រោះខ្ញុំចូលជាសមាជិកសម្ងាត់នៅក្នុងប្រទេសកម្ពុជាមុនខ្ញុំទៅប្រទេសបារាំងនៅខែតុលា ឆ្នាំ១៩៥៧ហ្នឹង គឺជាលោក អៀង សារី ជាអ្នកបញ្ចូលខ្ញុំ។ ហើយដល់ខ្ញុំទៅស្រុកបារាំងហ្នឹង គឺពេលនោះ វង់មាក្ស-ឡេនីន មានលោក ខៀវ សំផន ជាប្រធាន។ ដូច្នោះហើយខ្ញុំស្គាល់ ប៉ុល ពត ហ្នឹងពេលដែលនៅឆ្នាំ១៩៥៦ ពេលដែលខ្ញុំធ្វើគ្រូ ធ្វើសាស្ត្រាចារ្យនៅអនុវិទ្យាល័យឯកជននោះឈ្មោះ "ចំរើនវិជ្ជា"។ គាត់បង្រៀនអក្សរសាស្ត្របារាំង។ ខ្ញុំបង្រៀនប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ហើយមិនមានសញ្ញាណាសម្គាល់ថាគាត់ជាអ្នកតស៊ូទេ។ ខ្ញុំដឹងថាលោក ប៉ុល ពត គាត់រូបរាងគាត់ស្អាតណាស់ ហើយគាត់គួរសមណាស់។ ការរស់នៅ ខ្ញុំរស់នៅជាមួយគាត់គឺគាត់ស្រួល គាត់នែអានេះណ៎ះ។ ក៏ប៉ុន្តែ ដូច្នេះមានអ្នកណាស្មានថា គាត់ទៅប្រែក្លាយទៅធ្វើជាលេខារបស់បក្ស អត់មាន អ្នកក្រៅអត់ស្មានទេ។ ហើយការដែលស្គាល់លោកដឹងថា ប៉ុល ពត ជាសាឡុត ស ហ្នឹង ពេលដែលគាត់អញ្ជើញទៅធ្វើទស្សនកិច្ចនៅប្រទេសចិន នៅខែកញ្ញា ១៩៧៧។ អាហ្នឹងបានបើឆាកឡើងថា អូ៎នែ ប៉ុល ពត ហ្នឹងគឺ សាឡុត ស ទេបាទ។ អាហ្នឹងរឿងរ៉ាវវាយ៉ាងនេះបាទ។

[១០:២៨:៤២]

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំចង់សួរថា តើលោកនៅចាំដែរឬទេ ថាតើនៅពេលណាដែលលោកបានដឹងថា ប៉ុល ពត គឺជាលេខាបក្ស? តើលោកចាំដែរឬទេ ថាលោកដឹងនៅឆ្នាំណា?

**ឆ៖** ខ្ញុំដឹងពេលដែលខ្ញុំនៅប៉េកាំង ខ្ញុំចូល ចូលធ្វើជា ចូលជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាបាទ។

**ស៖** តើលោកនិយាយអំពីឆ្នាំណាដែរ?

**ឆ៖** នៅឆ្នាំ១៩៧១ បាទ។

**ស៖** តើគឺនៅឆ្នាំនោះឬ ដែលលោកដឹងថា សាឡុត ស គឺជាមេ -- ជាលេខាបក្ស ឬមួយក៏លោកនៅឆ្នាំនោះ លោកដឹងថា ប៉ុល ពត ជាលេខាបក្សនោះ? តើលោកដឹងថា សាឡុត ស ឬ ប៉ុល ពត?

**ឆ៖** ដឹងថា សាឡុត ស បាទ។

[១០:២៩:៥៨]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់និយាយអំពីចម្លើយរបស់លោក នៅថ្ងៃ០៧ ខែ៥ ឆ្នាំ២០០៩ ហើយវាមានទំនាក់ទំនងជាមួយសំណួរចុងក្រោយ -- សំណួរក្រោយមួយនេះ។ ព្រោះលោកនិយាយថា លោកមិនអាចប៉ាន់ស្មានថា ប៉ុល ពត ក្លាយជាលេខាបក្សនោះ។ ហើយខ្ញុំនិយាយអំពីឯកសារ E3/377 ភាសាខ្មែរគឺមានលេខ 0032735 ដល់ 38, ភាសាបារាំងគឺមានលេខ 00327255 ដល់ 57 និងភាសាអង់គ្លេសគឺមានលេខ 00327246 ដល់ 47។ ហើយគេសួរសំណួរលោកថា "អំពីទំនាក់ទំនងជាមួយ ប៉ុល ពត -- រវាង ប៉ុល ពត ជាមួយ អៀង សារី"។ ហើយចម្លើយរបស់លោក គឺលោកបានឆ្លើយថា "ប៉ុល ពត និង អៀង សារី គឺមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ហើយមានការពាក់ព័ន្ធខុស -- មានបុគ្គលិកលក្ខណៈផ្សេងៗគ្នា ហើយមានការវិវត្តខុសគ្នាខ្លាំង។ តាមពិតទៅ ប៉ុល ពត មិនមែនជាអ្នកបដិវត្តន៍ទេ។ គាត់បានធំធាត់នៅក្នុងព្រះបរមរាជវាំង។ នៅពេលរស់នៅប៉ារីសគាត់ចូលចិត្តសប្បាយ។ ក្រោយមកគាត់លែងទទួលយកនូវគំនិតយោបល់ផ្ទុយ។ ចំពោះគាត់ជីវិតរបស់មនុស្សម្នាក់មានតម្លៃតិចជាងទឹកមួយដំណក់នៅក្នុងមហាសមុទ្រ។ ផ្ទុយទៅវិញ អៀង សារី បានសង្គ្រោះជីវិតមនុស្សជាច្រើន។ គាត់ៗតែងតែប្រាប់យើងឲ្យនិយាយការពិត ទោះបីជាការពិតនោះធ្វើមិនធ្វើឲ្យគាត់មិនសប្បាយចិត្តក៏ដោយ។ បានក្លាយជាជនកុម្មុយនីស្តយ៉ាងលឿន។ ជាសរុបទៅ ខ្ញុំមិនមែនការពារ អៀង សារី ប៉ុន្តែខ្ញុំស្គាល់ច្បាស់។ ហើយខ្ញុំសូមនិយាយថា បើមិនមានការបះបោរនៅប៉ៃលិន និងម៉ាឡៃ នៅទសវត្សរ៍៩០ទេ សង្គ្រាមច្បាស់ជានៅតែបន្តរហូតដល់ពេលនេះ"។

[១០:៣២:២៩]

ពាក់ព័ន្ធទៅនឹងបរិបទនៃអ្វីដែលលោកបាននិយាយថា លោកមានការភ្ញាក់ទាក់ទងទៅនឹង ប៉ុល ពត នោះ ថាតើនេះគឺជាហេតុផលមួយដោយសារតែ ប៉ុល ពត ដែលលោកស្គាល់ថាជា សាឡុត ស នៅទីក្រុងប៉ារីសហ្នឹង គឺមិនមែនជាអ្នកបដិវត្តន៍នោះ? ហើយគាត់ហាក់ដូចជាមកពីអ្នក -- គឺមកពីវណ្ណៈគហបតីនោះ តើមែនដែរឬទេ?

**ឆ៖** ព្រោះនេះវាមានជាៗការវិវត្តខាងប្រវត្តិសាស្ត្រហ្នឹង អ្នកដែលមានលទ្ធភាពធ្វើជាប្រធានបក្សហ្នឹង គឺវាមានលោក រ័ត្ន សាមឿន ដែលគាត់ -- ខ្ញុំមិនបានស្គាល់គាត់ទេ ប៉ុន្តែខ្ញុំឮតែតាមមិត្តភក្តិរបស់គាត់ៗ របស់មិត្តរបស់ខ្ញុំនិយាយអំពីគាត់ ដែលបានស្គាល់គាត់ហ្នឹង។ គឺគាត់មានបំពេញលក្ខណៈសម្បត្តិគ្រប់គ្រាន់ គាត់អ្នកដូចថា នឹងនរ ចាស់ទុំ ហើយនិងលោក អៀង សារី ដែលគាត់ធ្លាប់--

[១០:៣៣:៥៤]

**ស៖** សូមអធ្យាស្រ័យលោក យើងនិយាយអំពី ប៉ុល ពត។ ខ្ញុំអធ្យាស្រ័យ យើងនិយាយអំពី ប៉ុល ពត។ ខ្ញុំសូមចូលទៅដល់សំណួរបន្ទាប់ទៀត ដែលសួរពាក់ព័ន្ធនឹងចម្លើយរបស់លោកក្នុងនេះ។ លោកបានឆ្លើយថា "ក្រោយមក គាត់លែងទទួល (គឺគាត់នេះសំដៅលើ ប៉ុល ពត)។ គាត់លែងទទួលយកនូវគំនិតផ្ទុយ។ ចំពោះគាត់ជីវិតរបស់មនុស្សម្នាក់មានតម្លៃតិចទឹកមួយដំណក់នៅក្នុងមហាសមុទ្រ"។ នៅពេលដែលលោកនិយាយថា "គាត់លែងទទួលយកនូវគំនិតយោបល់ផ្ទុយនោះ" តើលោកចង់បានន័យយ៉ាងម៉េចដែរ?

**ឆ៖** គឺតាមខ្ញុំដឹង គឺគំនិតណាដែលផ្ទុយពីគំនិតគាត់ គាត់តែងតែថាអ្នកហ្នឹងមិនមានគោលជំហរបក្សរឹងមាំ។ ដូច្នោះជួនកាលគាត់មិនមែន -- គាត់មិនបដិសេធអីទេ។ គាត់ជាអ្នកដូចថាមនុស្សគាត់នឹងនរ គាត់ -- ក៏ប៉ុន្តែគាត់រក្សានូវគំនិតរបស់គាត់ ព្រោះគាត់ក្រោយពីជ័យជម្នះនៅថ្ងៃទី១៧ មេសា ១៩៧៥ មក គឺគាត់គិតថា អ្វីដែលគាត់គិតហ្នឹងគឺថា មិនខុសទេ គោលជំហររបស់គាត់មិនខុសទេ។ អានេះខ្ញុំគិតថា គាត់មិនទទួលទេ គំនិតដែលផ្ទុយពីគាត់។ ហេតុនេះហើយបានជាមានការផ្តោះផ្តោយ មានការឧក្រិដ្ឋកម្មយ៉ាងធំធេងដូច្នេះ។ តាមខ្ញុំយល់ គឺដោយសារការកំណត់មាគ៌ារបស់បក្សពេលនោះធ្វើបដិវត្តន៍សង្គមនិយមលឿនពេក ហើយជារបៀបគ្រប់គ្រងដែលអាស្រ័យតែលើបុគ្គលម្នាក់ ដែលនាំឲ្យមានវិនាសកម្មដូច្នេះ។ អាហ្នឹងជាការយល់ជាបឋមរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំមិនមានវិនិច្ឆ័យថាមកពីគាត់ចូលចិត្តសប្បាយ ឬមកពីគាត់នេះទេ ហើយអ្នកដែលក្នុងកំណត់ហេតុនេះថា ចំពោះគាត់គឺជីវិតរបស់មនុស្សម្នាក់ គឺដូចជាដំណក់ទឹកនោះ មិនមែនខ្ញុំមានមតិអ៊ីចឹងទេ។ ព្រោះខ្ញុំមិនដឹងគាត់គិតយ៉ាងម៉េចទេ។ ប៉ុន្តែខ្ញុំគិតថា ទស្សនៈរួមក្នុង -- នៅក្នុងពេលកម្ពុជាប្រជាធិបតេយ្យគឺគិតរបៀបហ្នឹងបាទ។

[១០:៣៦:៤២]

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី អរគុណណាស់សាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សាសាក្សី ហើយនិងឲ្យអញ្ជើញពួកគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដែលបានកំណត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧ នាទី ដល់ម៉ោង ១០:៥៨ នាទី)*

[១០:៥៨:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងសូមពិនិត្យទៅលើប្រធានបទថ្មីមួយទៀត ហើយខ្ញុំនឹងពិភាក្សាអំពីហេតុការណ៍នៃ តូច ខាំឌឿន។ លោកបានជម្រាបមកយើងថា នៅក្នុងសក្ខីកម្មរបស់លោកថ្ងៃ០៦ ខែ៨ លោកបាននិយាយថា តូច ខាំឌឿន ត្រូវបានគេយកទៅក្រៅ។ នៅពេលលោក អៀង សារី បំពេញទស្សនកិច្ចផ្លូវការទៅ ម៉ាឡេស៊ី។ ហើយលោកបានបញ្ជាក់ថា នៅចំណុចមួយនោះ គឺលោកចាំថាចម្លើយសារភាពរបស់គាត់ ត្រូវបានគេយកមកអាន។ ហើយផ្អែកទៅលើសំណួរទាំងនោះ គេសួរលោកថា “តើលោកអាចកំណត់នូវបុគ្គលមួយចំនួនដែលមាននៅក្នុងចម្លើយនោះដែរឬទេ?” ហើយខ្ញុំចាំថា លោកបានបញ្ជាក់ថា “មាន ជួន ប្រសិទ្ធិ, គាត ឈន់ ព្រមទាំង អ៊ុក សុឃុន -- ឱក សុគន្ធ”។ តើលោកចាំដែរ ដែរឬទេថា ឱក សុគន្ធ ហ្នឹង គាត់នៅរស់ ឬក៏គាត់បានស្លាប់បាត់បង់ជីវិតហើយ?

[១១:០០:១០]

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំចាំមិនមែនឈ្មោះ ឱក សុគន្ធ ទេបាទ គឺក្នុងចម្លើយសារភាពរបស់ តូច ខាំឌឿន បាននិយាយថា មានជាដូចជាសាខារបស់អង្គការចារកម្មរបស់សហរដ្ឋអាមេរិកហ្នឹង សេ.អ៊ី.អា ហ្នឹង គឺឈ្មោះថា ស-៨០៨។ ពេលក្នុងនុ៎ងមាន តូច ខាំឌឿន, មានខ្លួនខ្ញុំ, លោក គាត ឈន់, លោក ជួន

ប្រសិទ្ធិ, ហាក់ សៀងឡាយនី។ មិនមានឈ្មោះលោក ឱក សុគន្ធទេ។ ហើយក៏ប៉ុន្តែលោក ឱក សុគន្ធ គាត់ៗស្លាប់ហើយបាទ។

**ស៖** ទោះបីថាបុគ្គលដែលមិនមានបង្ហាញវត្តមាននៅក្នុងការប្រជុំ ដែលបានកើតឡើងនោះក៏ដោយ ហើយនៅពេលដែលមានចម្លើយសារភាពរបស់ គួច ខាំឌឿន ដែលបានអាន។ តើលោកចាំថាមិនមានបុគ្គល -- បានន័យថាលោកមិនចាំថាមានបុគ្គល ឱក សុគន្ធ ទេឬនៅពេលដែលគេអានចម្លើយសារភាពនោះ?

[១១:០១:៣០]

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ។ លទ្ធភាពអាចៗមានគាត់ដែរ អាហ្នឹងមានលទ្ធភាពព្រោះគាត់ជាកម្មាភិបាលសំខាន់មួយរូបដែរបាទ នៅក្រសួងការបរទេស។

**ស៖** សំណួរដែលខ្ញុំចង់បញ្ជាក់ គឺថាលោកបានបញ្ជាក់ថាមានកិច្ចប្រជុំមួយ ដែលនៅក្នុងកិច្ចប្រជុំហ្នឹង គេអានទូវចម្លើយសារភាព ហើយយើងដឹងមាន ជួន ប្រសិទ្ធិ និង គាត ឈន់ មានវត្តមាននៅក្នុងកិច្ចប្រជុំនោះ។ ហើយប្រហែលជាមានវត្តមានបុគ្គលម្នាក់ទៀត គឺខ្លួនលោកផ្ទាល់។ តើមែនដែរឬទេ? តើលោកចាំថាមានបុគ្គលបែបនេះដែរឬទេ ដែលចូលរួមនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ មិនដឹងតើមានលោក ជួន ប្រសិទ្ធិ ឬនិងលោក គាត ឈន់ បានចូលរួមក្នុងការប្រជុំហ្នឹងទេ។ ប៉ុន្តែគឺថាខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែលទ្ធភាពមាន ព្រោះសុទ្ធតែកម្មាភិបាលនៅក្រសួងការបរទេសដូចគ្នាបាទ។

**ស៖** ដូច្នេះ ឥឡូវនេះ ខ្ញុំសូមនិយាយឲ្យច្បាស់ វាហាក់ដូចជាមានការយល់ច្រឡំថា គាត់មិនមានវត្តមាន។ ហើយនៅពេលដែលព្រះរាជអាជ្ញាចោទសួរលោក គឺលោកថា គឺលោកបានឆ្លើយថា "ខ្ញុំមិនចាំច្បាស់ថ្ងៃកាលបរិច្ឆេទ ហើយអ្នកណា គឺថាមានវត្តមាននៅកន្លែងនោះក៏ខ្ញុំចាំមិនច្បាស់ដែរ។ ខ្ញុំគ្រាន់តែអាចថា និយាយបានថានៅក្នុងរយៈពេល គឺថាឆ្នាំ១៩៧៧ ហើយអ្នកដែលមានវត្តមានពេលនោះ គឺជាអ្នកធ្វើកម្ម -- ធ្វើការងារកម្មាភិបាល ដែលធ្វើការជាមួយខ្ញុំនៅក្នុងក្រសួងបរទេស ផ្នែកការិយាល័យផ្នែកការទូតហ្នឹង។ ដែលសុទ្ធតែជាពួកម៉ាកជិតស្និទ្ធរបស់ គួច ខាំឌឿន គឺដូចជា ជួន ប្រសិទ្ធិ, លោក គាត ឈន់, លោក ឱក សុគន្ធ ជាដើម"។ ហើយដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំបានអានចេញពីប្រតិចារឹកនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២ គឺភាសាខ្មែរមានលេខ 00832205 ដល់ 06, ភាសាបារាំងគឺមានលេខ 008331166 (ស៊ីក) ដល់ --, ហើយភាសាអង់គ្លេស 00833281។

[១១:០៤:១៥]

ហើយខ្ញុំចង់ឲ្យមានការបញ្ជាក់ច្បាស់ ប្រសិនបើលោកមិនចាំទេ អត់បញ្ហាទេ។

**ឆ៖** ខ្ញុំមិនចាំច្បាស់ថាអ្នកណា -- កម្មាភិបាលណាខ្លះបានចូលរួមទេ។ ខ្ញុំគ្រាន់ថាវាលទ្ធភាពច្រើន ព្រោះខ្ញុំបានចូលរួម ហើយកម្មាភិបាលទាំងនោះ ពេលនោះនៅកន្លែងនោះដែរ ហើយមានឋានៈប្រហែលៗខ្ញុំ ដូច្នេះអាចមានលទ្ធភាពអាចចូលរួមក្នុងការប្រជុំនុំងដែរ។

**ស៖** សូមអរគុណ។ ហើយបញ្ហាមួយទៀតដែលយើងបានពិភាក្សាកាលពីមុន ដែលលោកនិយាយអំពី ប៉ុល ពត នោះ។ គឺថា ប៉ុល ពត មិនទទួលយកនូវការ -- នូវមតិយោបល់ជំទាស់ ហើយនៅទីនេះ លោកហាក់ដូចជាបញ្ជាក់ថា លោក អៀង សារីៗ បានចូលរួមនៅទីនោះ ហើយដោយសារតែគាត់នៅទីនោះ ទើបគេមិនអាចដក តូច ខាំឌឿន ចេញ។ ប្រសិនបើគាត់នៅ គឺគេមិនអាចដកបានទេ។ ប៉ុន្តែឥឡូវនេះ ខ្ញុំនិយាយអំពីប្រយោគរបស់លោក គឺនៅថ្ងៃ២០ ខែមីនា ឆ្នាំ២០០៩ គឺ E3/371 គឺទំព័រ៤ ភាសាអង់គ្លេស ហើយភាសាខ្មែរ គឺមានលេខ 00288236 ដល់ 37, ភាសាបារាំង គឺមានលេខ 00288243 ដល់ 44, និងភាសាអង់គ្លេស គឺមានលេខ 00290415។ ហើយនៅក្នុងចម្លើយរបស់លោក គឺលោកបាននិយាយថា "ខ្ញុំសូមបន្ថែមថាៗ តូច ខាំឌឿន គឺស្និទ្ធស្នាលជាមួយនឹង អៀង សារី ហើយនៅក្នុងគំនិតរបស់ខ្ញុំ ការចាប់ខ្លួននេះ មិនកើតមានឡើងទេ ប្រសិនបើលោក អៀង សារី មានវត្តមាននៅក្នុងទីក្រុងភ្នំពេញ"។ ហើយនៅត្រង់ចំណុចនេះ លោកហាក់ដូចជាចង់បង្ហាញនូវគំនិតដែលថា -- ខ្ញុំចង់ឲ្យបញ្ជាក់ទៅលើចំណុចនេះ។ គឺតើលោកចង់មានន័យបែបនេះ មែនទេ?

[១១:០៧:១៧]

តើលោកធ្វើការស្មានដែរឬទេ ដែលថាតាមគំនិតរបស់លោក គឺថាការចាប់ខ្លួននេះ នឹងមិនអាចកើតឡើង? ដោយស្របទៅតាមចម្លើយរបស់លោក ដែលបានបញ្ជាក់ពីមុន ដែលថា ប៉ុល ពត គឺជាព្រះ ហើយគាត់មានឆន្ទានុសិទ្ធិផ្តាច់មុខ ហើយគាត់នឹងមិនទទួលយកនូវការជំទាស់ណាមួយពីអ្នកដទៃ?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប! បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ផ្នែកដំបូងនៃសំណួររបស់លោក កាណាវាស នោះ គឺថាចង់ដឹងថាតើសាក្សីនៅពេលដែលធ្វើការវិភាគនេះ គាត់ស្មាន ឬក៏មិនមែន? ក៏ប៉ុន្តែនៅពេលដែលមេធាវីការពារ

ក្តី គាត់បន្ថែមទំនាក់ទំនងជាមួយនឹងអ្វីដែលគាត់និយាយពីមុនជាមួយ ប៉ុល ពត នោះ ខ្ញុំគិតថា ការធ្វើបែបនេះ គឺថាធ្វើឲ្យសាក្សីនិយាយស្មានហើយ ប្រសិនបើគាត់ភ្ជាប់នោះ។ ដូច្នេះ សំណួរបែបនេះ វានាំមុខទៀត។ អាផ្នែកដំបូងនៃសំណួរនោះ គឺត្រឹមត្រូវ ក៏ប៉ុន្តែផ្នែកបន្ទាប់មក ភ្ជាប់ -- ពេលដែលភ្ជាប់សំណួរជាមួយគ្នាទៅ គឺធ្វើឲ្យសាក្សីស្មាន។

[១១:០៨:៣១]

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំរីករាយ ប្រសិនបើថាឲ្យគាត់ឆ្លើយតែផ្នែកដំបូងនៃសំណួរ ដើម្បីធ្វើការភ្ជាប់ជាមួយនឹងសំណួរដែលខ្ញុំបានសួរពីខាងមុន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅពេលដែលលោកនិយាយថា តាមគំនិតរបស់លោក តើលោកធ្វើការទាយស្មានដែរឬទេ?

**លោក ស្វង ស៊ីគឿន៖**

**ឆ៖** អាហ្នឹងថា ស្មាន ក៏បានដែរ ព្រោះអ្វីដែលវាសុទ្ធតែជាចំណោទ ជាការចោទសួរដែរ ប៉ុន្តែតាម -- ព្រោះកាលដែលគេចោទលោក តូច ខាំឌឿន ហ្នឹង វា -- បើដែលចោទគាត់ហ្នឹង វាដូចវាគ្មានចោទគាត់ថា គាត់ជាអ្នកសរសេរសភាពការណ៍ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ បញ្ជូនទៅឲ្យ -- ទៅក្រៅប្រទេស បញ្ជូនទៅ សេ.អ៊ី.អា តាមរយៈស្ថានទូតអេហ្ស៊ីបប្រចាំទីក្រុងភ្នំពេញ។ ហើយអ្នកដែលយកសេចក្តីរាយការណ៍របស់គាត់ហ្នឹង គឺជាប្រពន្ធរបស់គាត់ ដែលធ្វើការនៅក្នុងផ្នែកពិធីការរបស់ក្រសួងការបរទេស។ បាទ ហើយអ្នកដែលផ្តល់ព័ត៌មាន--

[១១:០៩:៥២]

**ស៖** សូមអរគុណ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើលោកធ្វើការទាយស្មានអត់? នៅពេលដែលលោកផ្តល់ឆ្លើយបែបនេះ ហើយលោកបានឆ្លើយនូវសំណួរនេះរួចហើយ។ ហើយលោកប្រធានបានបញ្ជាក់ហើយ ថាយើងមិនត្រូវការនូវការពន្យល់បន្ថែមអ្វីតទៅទៀតនោះទេ។ ឥឡូវនេះ សូមត្រឡប់ទៅលើប្រធានបទថ្មីមួយទៀត ដោយសារតែខ្ញុំមិនមានពេលវេលាច្រើនទៀត។ ឥឡូវនេះ យើងធ្វើការពិភាក្សាអំពី គាត ឈន់ និង ជួន ប្រសិទ្ធិ។ ខ្ញុំចាប់អារម្មណ៍ទៅលើចំណុចមួយចំនួន នៃចម្លើយរបស់លោកដែលលោកបានផ្តល់នៅថ្ងៃ០៧ ខែ៨ ខែសីហា ហើយគេសួរលោកថា -- សំណួរដែលគេសួរ

លោកនេះគឺមាននៅប្រតិចារឹកខ្មែរមានលេខ 00832516 ដល់17, ភាសាបារាំងគឺមានលេខ 00833623 ដល់ 24, និងភាសាអង់គ្លេសមានលេខ 00833508 ដល់ 09។

[១១:១១:១១]

ហើយគេសួរលោកថា "តើលោកដឹងដោយរបៀបណា ដែលថា ជួន ប្រសិទ្ធិ ជាមួយនឹង គាត ឈន់ ត្រូវបានគេឆ្លើយដាក់នៅក្នុងឯកសារមួយចំនួន?" ហើយលោកឆ្លើយថា "គឺមានការពិភាក្សានៅក្នុងកិច្ចប្រជុំដែរឬទេ? បាទ ចំណុចនេះ ខ្ញុំដឹងដោយសារ អៀង សារី ជាអ្នកបានប្រាប់ ប៉ុន្តែកាលៈទេសៈដែលប្រាប់នេះ គឺក្នុងអង្គប្រជុំ។ ប៉ុន្តែខ្ញុំមិនចាំថា នៅពេលណា ឬក៏ចាំសេចក្តីលម្អិតនោះទេ"។ នេះគឺជាអ្វីដែលលោកបានផ្តល់សក្ខីកម្មនៅថ្ងៃ៧ ខែសីហា។ ដោយយើងចាំទៅលើចំណុចទាំងអស់នេះ ខ្ញុំសូមបន្តទៅនឹងចម្លើយសារភាព -- ទៅនឹងចម្លើយរបស់នៅថ្ងៃ០៦ ខែ៥ ឆ្នាំ២០០៩ គឺ E3/42 គឺទំព័រ៨ ជាភាសាអង់គ្លេស។ ភាសាខ្មែរគឺមាន 00327209 ដល់ 010, ភាសាបារាំង 00327228 ដល់ 29, និងភាសាអង់គ្លេសគឺមានលេខ 0032219 (ស៊ីក)។ ហើយនៅត្រង់ចំណុចនេះ គឺលោកបានផ្តល់ចម្លើយដូចតទៅ "អៀង សារី មិនបានជម្រាបខ្ញុំដោយផ្ទាល់ -- មិនបានប្រាប់ខ្ញុំដោយផ្ទាល់ទេ គាត់បាននិយាយពីរឿងនេះនៅក្នុងកិច្ចប្រជុំមួយរបស់នាយកដ្ឋានទូទៅ ដែលមានការចូលរួមពីសហការីជិតស្និទ្ធរបស់គាត់ ដូចជា ជួន ប្រសិទ្ធិ, គាត ឈន់, តូច ខាំឌឿន, ឌិក សុគន្ធ ហើយនិងមនុស្សផ្សេងទៀតជាច្រើន"។

[១១:១៣:១៣]

ដូច្នេះអ្វីដែលយើងមាននៅត្រង់ចំណុចនេះ គឺមានការផ្ទុយគ្នាបន្តិច នៅក្នុងចម្លើយរបស់លោក លោកហាក់ដូចជាចង់បង្ហាញថា -- គឺនៅក្នុងចម្លើយថ្ងៃ០៦ ខែ៥ លោកចង់និយាយថា "អៀង សារី មិនបានជម្រាបដោយផ្ទាល់នោះទេ គឺលោកដឹងតាមរយៈការប្រជុំ"។ ប៉ុន្តែនៅក្នុងសក្ខីកម្មរបស់លោក នៅថ្ងៃ០៧ ខែ៨ វិញ លោកបាននិយាយថា "លោក អៀង សារី បានហៅលោក ហើយលោកដឹងអំពីបញ្ហានេះនៅក្នុងកិច្ចប្រជុំ"។ ថាតើវាអាចដែរឬទេ ដែលថាលោកនិយាយខុស នៅក្នុងតុលាការ ឬក៏នៅជាមួយសហចៅក្រមស៊ើបអង្កេត ដែលធ្វើនៅថ្ងៃ០៦ ខែ៥ គឺថា អ្វីដែលធ្វើនៅថ្ងៃ០៦ ខែ៥ ហ្នឹងវាត្រូវជាងជាមួយនឹងការចាំរបស់លោក?

[១១:១៤:០៩]

**ឆៈ** លោកធារី -- លោកមេធាវីបែប ដូចមានការច្រឡូកច្របល់ ខ្ញុំដែលលោក អៀង សារី ហៅខ្ញុំទៅប្រាប់ផ្ទាល់ហ្នឹង គឺពីរឿងខ្ញុំៗត្រូវលោក រស់ សារិន ក្នុងចម្លើយសារភាពរបស់គាត់ហ្នឹង គាត់

ចោទថា ខ្ញុំ ហើយនិងលោក គាត ឈន់ ហ្នឹងគឺជាខ្សែរយៈ សេ.អ៊ី.អា ដូចគាត់ដែរ ដែលនាំឲ្យខ្ញុំធ្វើសរសេរជីវប្រវត្តិរូប។ ប្រវត្តិរូបខ្ញុំ ដែលបានចេញផ្សាយជាទូទៅ ឃើញជាអក្សរដៃរបស់ខ្ញុំ ឃើញទេ! គឺតែចំពោះរឿងខ្ញុំផ្ទាល់។ ចំពោះរឿងអ្នកផ្សេងដែលខ្ញុំបានដឹង គឺតាមរយៈអង្គប្រជុំរួមបាទ ខ្ញុំចង់ប្រាប់ប៉ុណ្ណឹង។ ដូច្នោះ មិនមានអី ខ្ញុំឆ្លើយខុស ឬខ្ញុំឆ្លើយត្រូវអីទេ។ ខ្ញុំឆ្លើយទៅតាមដែលខ្ញុំចាំប៉ុណ្ណឹងបាទ។

[១១:១៥:០៨]

**ស៖** សូមអរគុណ នេះគឺជាអ្វីដែលខ្ញុំចង់សួរ។ ឥឡូវនេះ សូមយើងពិនិត្យមើលទៅលើឯកសារ D, D91/26 ហើយនេះជាចម្លើយរបស់លោក។ គឺចម្លើយរបស់លោកនៅថ្ងៃ១៩ ខែធ្នូ ឆ្នាំ២០០៧។ ឥឡូវនេះយើងពិនិត្យមើលទៅលើទំព័រ៤ ជាភាសាអង់គ្លេស ដែលមានលេខ ERN គឺមានលេខភាសាខ្មែរ 00204152 ដល់ 53, ភាសាបារាំងគឺមានលេខ 00343363 ដល់ 65 និងភាសាអង់គ្លេសគឺមានលេខ 00223642។ លោកបាននិយាយថា តាមដែលខ្ញុំដឹងអ្នកណាក៏ដោយដែលមានឯកសារបី ត្រូវបានគេឆ្លើយដាក់ នឹងត្រូវបានគេចាប់ខ្លួន។ ហើយលោកបានបន្តទៀតថា ចំពោះ គាត ឈន់ និង ជួន ប្រាសិទ្ធ គឺពួកគាត់មានឯកសារ១០។ ប៉ុន្តែ អៀង សារី បានប្រាប់ ប៉ុល ពត ថា គាត ឈន់ និង ជួន ប្រាសិទ្ធ មិន -- ប្រសិនបើ គាត ឈន់ និង ជួន ប្រាសិទ្ធ ត្រូវគេចាប់ខ្លួនគឺក្រសួងទាំងមូលហ្នឹងត្រូវបោះចោលតែម្តងទៅ ត្រូវលុបក្រសួងការបរទេសតែម្តងទៅ។ តាមដែលខ្ញុំដឹង តាមសក្ខីកម្មរបស់លោក គឺបាននិយាយថានៅក្នុងកិច្ចប្រជុំនៅពេលដែលលោកទាំងពីររូបនេះបានចូលរួម។ តើវាជាការត្រឹមត្រូវដែរឬទេ?

[១១:១៧:១២]

**លោក សួង ស៊ីគឿន៖**

លោកប្រធាន សូមឲ្យលោកមេធាវីបញ្ជាក់ពីការ ប្រជុំនៅពេលណា? នៅ -- និយាយពីអីបាទ? ព្រោះ--។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី លោកបានផ្តល់សក្ខីកម្មនៅទីនោះ ហើយលោកក៏បានផ្តល់ចម្លើយនេះដែរ។ លោកបានបញ្ជាក់ថា បញ្ហានេះត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំ។ តើលោកចាំដែរឬទេ នៅក្នុងថ្ងៃនេះ ចាំថាកិច្ចប្រជុំហ្នឹង កើតឡើងនៅទីណា? ហើយកិច្ចប្រជុំហ្នឹងមាន គាត ឈន់ និង ជួន ប្រាសិទ្ធ ចូលរួមដែរឬទេ? ហើយដែលកិច្ចប្រជុំនេះនិយាយអំពីឯកសារដែលប្រឆាំងនឹងពួកគាត់ ហើយលោក អៀង សារី បានប្រាប់ទៅលោក ប៉ុល ពត ថា ប្រសិនបើគ្មានលោក គាត ឈន់ និង ជួន ប្រាសិទ្ធ ទេត្រូវលុប

ក្រសួងការបរទេសចោលតែម្តង តើលោកចាំដែរឬទេ?

**លោក ស្វង ស៊ីគឿន៖**

**ឆ៖** ខ្ញុំបានចាំថាមានការប្រជុំដែលខ្ញុំបានចូលរួម ហើយនៅក្នុងការប្រជុំនោះលោក អៀង សារី បានជូនព័ត៌មានដល់យើងខ្ញុំយ៉ាងដូច្នេះមែន។ ក៏ប៉ុន្តែតើក្នុងកិច្ចប្រជុំនោះមានវត្តមានរបស់លោក គាត ឈន់ ឬលោក ជួន ប្រាសិទ្ធ ខ្ញុំមិនបានចាំទេបាទ។

[១១:១៩:០៨]

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបានបញ្ជាក់ថាមានវត្តមាន ដែលៗថា អៀង សារី បានជម្រាបទៅពួកគាត់ទាំងនោះ មានឯកសារប្រឆាំងនឹងពួកគាត់ ហើយឥឡូវនេះ លោកនិយាយថាប្រហែលជាលោកច្រឡំ នៅពេលដែលលោកនិយាយអំពីបញ្ហានេះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ទេ។ ការប្រជុំវាមានច្រើន ចួនកាលគាត់ជម្រាបនៅពេលប្រជុំណាមួយ មិនមែនតាម -- នៅពេលប្រជុំដែលលោកមេធាវីសួរនោះទេ។ ដូច្នោះ ខ្ញុំមិនបានចាំអីច្បាស់លាស់ទេ ព្រោះរឿងនេះកើតមកយូរណាស់មកហើយបាទ។ ប៉ុន្តែខ្ញុំចាំជាគោលៗ។

**ស៖** សូមអរគុណ។ ឥឡូវនេះតើលោកដឹងដែរឬទេថា ជួន ប្រាសិទ្ធ ហើយនិង គាត ឈន់ មានវត្តមាននៅពេលដែលលោក អៀង សារី បាននិយាយដូចដែលលោកបានបញ្ជាក់អ៊ីចឹង ថាប្រសិនបើគ្មានពួកគាត់ទាំងពីរទេ គឺត្រូវលុបក្រសួងការបរទេសចោលតែម្តង គឺនៅពេលដែល អៀង សារី បានជម្រាបទៅ ប៉ុល ពត។ តើលោកចាំទេ?

**ឆ៖** ខ្ញុំមិនបានចាំច្បាស់អ៊ីចឹងទេបាទ។

[១១:២០:៤៨]

**ស៖** សូមអរគុណៗ។ ហើយផ្អែកទៅលើចម្លើយដែលលោកផ្តល់ឲ្យហ្នឹង ខ្ញុំសូមបន្តទៅមុខទៀត។ លោកបានបញ្ជាក់ផងដែរថា លោកបានដឹងថា គាត ឈន់ មានឯកសារចំនួន៦០ ហើយលោកបានបញ្ជាក់ថា លោកដឹងព័ត៌មានលម្អិតមួយចំនួននៃឯកសារទាំង៦០នេះ។ ខ្ញុំគ្រាន់តែចង់ឲ្យមានការយល់ច្បាស់អំពីសក្ខីកម្មនេះ។ តើលោកចង់ជម្រាបយើងថា លោកបានឃើញនូវឯកសារពិតប្រាកដដែលក្នុងឯកសារនោះគេនិយាយអំពី គាត ឈន់ គឺថាប្រហែលជា៦០ដង ដែលត្រូវបានគេឆ្លើយថាជាសត្រូវរបស់បក្ស ឬក៏សត្រូវរបស់ប្រជាជន ឬក៏ជាចារកម្ម ចារបុរស?

**ឆ៖** ខ្ញុំមិនបានឃើញឯកសារ ខ្លួនខ្ញុំផ្ទាល់អ្វីដែលខ្ញុំបានដឹងអំពីលោក គាត ឈន់ គឺលោក អៀង

សារី អ្នកប្រាប់ខ្ញុំ ហើយប្រាប់ហ្នឹងមិនមែនប្រាប់ផ្ទាល់ ប្រាប់ក្នុងអង្គប្រជុំ។ ហើយខ្ញុំបានជម្រាបហើយថា ឯកសារគាត់ហ្នឹង គាត់មានឯកសារជាង៦០ ហើយក្នុងឯកសារហ្នឹង ពេលដែលគាត់ជប់លៀងពេលល្ងាច ហូបបាយនៅផ្ទះមិត្តភក្តិរបស់គាត់ ហើយជាពិសេសគឺថា គាត់ធ្លាប់ធ្វើការនៅក្រសួងសាធារណការ ហើយលោក តូច ភឿន ហ្នឹង គាត់ធ្វើរដ្ឋមន្ត្រីហ្នឹង គាត់ឧស្សាហ៍ហៅគាត់ទៅ។ ពេលនុំង ក៏គេហៅខ្ញុំទៅដែរ ប៉ុន្តែខ្ញុំខ្ជិល ខ្ញុំខ្ជិលទៅ ខ្ញុំមិនសូវចូលចិត្តការជួបជុំអីអឺចឹង។ អាពេលដែលទៅម្តងហ្នឹង គេចាត់ថាជាឯកសារមួយហើយ ដូច្នេះទៅតែបីដងវាចប់ហើយ។ អា៦០ហ្នឹង គឺដោយសារគេ--

[១១:២៤:៥៤]

**សៈ** សូមអរគុណលោកសាក្សី ខ្ញុំគិតថាលោកបានឆ្លើយសំណួរខ្ញុំហើយ។ ហើយសំណួរដែលខ្ញុំចង់សួរបន្ទាប់ គឺការពិភាក្សានៅក្នុងកិច្ចប្រជុំ ដែលៗបាននិយាយថា គាត់មានឯកសារជាង៦០។ តើលោកដឹងដែរឬទេ ថា គាត ឈន់ ក៏គាត់បានដឹងដែរថាមានឯកសារប៉ុណ្ណោះ ចំនួនប្រហែល៦០ ហ្នឹងឆ្លើយដាក់គាត់ដែរ ព្រោះថាកិច្ចប្រជុំហ្នឹងមិនមែនជាកិច្ចប្រជុំសម្ងាត់នោះទេ?

**ឆៈ** តាមខ្ញុំអាចជម្រាបអង្គសវនាការថា លោក គាត ឈន់ គ្រាន់ដឹងថា គាត់ត្រូវគេចោទថាជាភ្នាក់ងារ សេ.អ៊ី.អា។ អាហ្នឹងអាចគាត់ដឹង ត្រង់ថា ៦០ ឬជាង ៦០ ខ្ញុំមិនអាចជម្រាបបានទេ ព្រោះបាទមិនដឹងថាគាត់ដឹង ឬមិនដឹងទេបាទ។

**សៈ** នៅពេលដែលលោកចូលរួមក្នុងកិច្ចប្រជុំដែលលោកក៏ដឹង លោក គាត់ ឈន់ ក៏ដឹងថាមានឯកសារប្រឆាំងនឹងគាត់នោះ។ តើលោកដឹងដែរឬទេថាលោក គាត ឈន់ ក៏មានវត្តមាននៅក្នុងប្រជុំហ្នឹង? តើគាត់មានវត្តមានទេ?

[១១:២៤:១១]

**ឆៈ** ខ្ញុំមិនអាចជម្រាបអង្គប្រជុំ អង្គសវនាការបានច្បាស់ទេ ប៉ុន្តែលទ្ធភាពវាមាន ព្រោះកាលដែលចោទ អានឯកសារចម្លើយសារភាពហ្នឹង វាមានច្រើនដងដែរ។ ហើយយើងអាចសន្និដ្ឋានថា លោក គាត ឈន់ អាចមានវត្តមាននៅទីនោះដែរ ប៉ុន្តែឲ្យខ្ញុំនិយាយច្បាស់ ខ្ញុំមិនចាំទេបាទ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកគប្បីចងចាំឲ្យច្បាស់ថា លោកឆ្លើយតបឲ្យច្បាស់លាស់ ចៀសវាងទី១ ការស្មាន, ទី២ ជាការសន្និដ្ឋានរបស់លោក។ កាលណាលោកឆ្លើយជាការសន្និដ្ឋានហ្នឹង វាអត់មានតម្លៃជាភស្តុតាងទេ ពីព្រោះលោកជាសាក្សី។

[១១:២៥:00]

អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានធ្វើការជម្រាបអំពីកាតព្វកិច្ចរបស់លោក នៅក្នុងការឆ្លើយតបទៅនឹងសំណួរ អ្វីដែលលោកបានដឹង បានឮ បានឃើញ ចងចាំបទពិសោធន៍ផ្ទាល់ផ្ទងកាត់ ឬក៏បានធ្វើការសង្កេតនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងសំណួរដែលសួរ។ កាលណាលោកប្រើថា តាមខ្ញុំយល់ ឬក៏តាមខ្ញុំ -- សេចក្តីសន្និដ្ឋានរបស់ខ្ញុំ គឺអត់មានតម្លៃជាភស្តុតាងទេនៅក្នុងកិច្ចដំណើរការសវនាការ ពីព្រោះលោកមិនមែនជាអ្នកជំនាញទេ។ អ៊ីចឹងកាលណាលោកដឹង គឺលោកឆ្លើយថាដឹងហើយបើមិនដឹងទេ គឺឆ្លើយថាមិនដឹង ជាការ ធ្វើម៉េចតបទៅនឹងកម្រិតសំណួរដែលសួរឲ្យបានត្រឹមត្រូវ។

[១១:២៥:៥១]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងប្តូរទៅប្រធានបទថ្មីមួយទៀត ហើយប្រធានបទនេះ និយាយអំពីប្រវត្តិរូបដែលលោកបានសរសេរ -- ជីវប្រវត្តិដែលលោកបានសរសេរ។ ឥឡូវនេះ យើងសូមពិនិត្យមើលទៅលើសក្ខីកម្មរបស់សាក្សីមួយរូបផ្សេងទៀតដែលបាននិយាយអំពីប្រវត្តិរូប -- ជីវប្រវត្តិរបស់លោក។ ហើយនៅក្នុងសក្ខីកម្មរបស់លោក ឆាំង យុ គឺនៅថ្ងៃ១ ខែ២ ឆ្នាំ២០១២ ភាសាខ្មែរគឺមានលេខ 00776592, ភាសាបារាំងគឺមានលេខ 00776475, និងភាសាអង់គ្លេសគឺមានលេខ 00776350។ ហើយនេះគឺជាឯកសារ -- គឺឯកសារមានលេខ E3/37.1 គាត់ -- គេចោទសួរសំណួរមួយចំនួនទាក់ទងទៅនឹងជីវប្រវត្តិ ហើយចម្លើយរបស់គាត់មួយបានឆ្លើយថា "ពិតហើយថាមានប្រភេទផ្សេងៗគ្នានៃប្រវត្តិរូប ហើយប្រវត្តិរូបរបស់ សួង ស៊ីគឿន ហៅ គង់ គឺជាប្រជាប្រវត្តិរូបដែលសរសេរដោយខ្លួនឯងតែម្តង"។ និយាយអំពីប្រវត្តិរបស់ខ្លួន និយាយអំពីសកម្មភាពដែលខ្លួនបានចូលបដិវត្តន៍ និងផ្សេងៗទៀត ហើយឯកសារនេះវាហាក់ដូចជាទម្រង់បំពេញ គេហៅថាបំពេញជីវទស្សន៍៦ខែម្តង ឬក៏១ឆ្នាំម្តង។ ហើយគាត់ក៏បាននិយាយអំពីឯកសារ D154.3។ សំណួរដែលខ្ញុំចង់សួរលោកគឺថា តើ ឆាំង យុ គាត់និយាយត្រឹមត្រូវដែរឬទេ ដែលថាពិនិត្យមើលទៅលើប្រវត្តិរូបរបស់លោក គឺជាប្រវត្តិរូបដែលគេធ្វើឡើងប្រហែលជា៦ខែ ឬក៏១ឆ្នាំម្តងនោះ។ តើត្រឹមត្រូវដែរឬទេ?

[១១:២៨:០២]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខុសស្រឡះ។ ហើយខ្ញុំនិយាយពីកាលៈទេសៈនោះដែលខ្ញុំសរសេរផ្ទាល់ខ្លួននោះ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ប្រសិនបើយើងពិនិត្យមើល--

**ប្រធានអង្គជំនុំ៖**

ម៉េចទៅតំណាងសហព្រះរាជអាជ្ញា? ប្រសិនបើលោកមានការតវ៉ាជំទាស់ជាការហួសពេល។ ទីពីរ ប្រសិនបើលោកណែនាំដល់ភាគីម្ខាងទៀតក្នុងការប្តូរ ឬក៏រៀបចំការតាំង -- របៀបការតាំងសំណួរនោះ យើងមិនអនុញ្ញាតទេ។ ភាគីទាំងសងខាងហ្នឹងមិនអាចបង្រៀនភាគីម្ខាងទៀតឲ្យតាំងសំណួរតាមវិធីណា របៀបណាទេ។ តែលោកអាចជំទាស់បាន។ បើការជំទាស់ ឬជំទាស់មុនពេលសាក្សីឆ្លើយ។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ លោកទើបតែរំឭកទៅឲ្យសាក្សីកុំឲ្យស្មាន សូមឲ្យគាត់ឆ្លើយឲ្យបានខ្លី ហើយសាក្សីបានឆ្លើយយ៉ាងខ្លីៗហើយ។ សំណួរដែលត្រូវបាន ចម្លើយរបស់សាក្សីទៅនឹងសំណួរមុនៗនោះ គឺថាត្រូវបានកាត់ផ្តាច់ ហើយយើងអត់បានស្តាប់ឮការបញ្ជាក់របស់សាក្សីទេ។ ដូច្នេះសូមឲ្យសាក្សីនិយាយឲ្យចប់សិន កុំឲ្យលោកមេធាវីការពារក្តីកាត់គាត់ ហើយសួរឲ្យគាត់ឆ្លើយថា បាទ ឬក៏ទេ។ គឺថាមានចម្លើយ -- សំណួរខ្លះនោះទាមទារឲ្យមានការពន្យល់អំពីសាក្សី។ ដូច្នេះសុំឲ្យសាក្សីនិយាយឲ្យបានចប់សិន មុននឹងកាត់ផ្តាច់ចម្លើយរបស់សាក្សីនោះ។

[១១:២៩:៤២]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមឆ្លើយតបដោយខ្លី ព្រោះថាខ្ញុំមិនចង់ឲ្យសាក្សីត្រឡប់មកផ្តល់សក្ខីកម្មមួយថ្ងៃទៀតនោះទេ។ ប្រសិនបើចម្លើយរបស់គាត់ គឺហួសពីគោលដៅនៃការសួរ គឺថាសក្ខីកម្មនោះដែលគាត់ផ្តល់ភាគច្រើន គឺទាក់ទងទៅនឹងប្រវត្តិរូប ឬក៏ជីវទស្សន៍នោះ។ ហើយមានសំណួរមានចំនួនពីចៅក្រមអង្គជំនុំជម្រះ។ ដូច្នេះអ្វីដែលខ្ញុំចង់ដឹងគឺថា អ្នកជំនាញដែលគាត់បានមកផ្តល់សក្ខីកម្មនេះគឺគាត់និយាយអំពីប្រវត្តិរូប ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគាត់ផ្ទាល់ហ្នឹង គេបានបញ្ជាក់អំពីឈ្មោះរបស់សាក្សី ហើយវាហាក់ដូចជាសំណួរដែលលើកឡើងដោយព្រះរាជអាជ្ញាផ្ទាល់ ហើយខ្ញុំមិនបានសួរ

សាក្សី ថាតើលោក យុ ឆាំង ហ្នឹងនិយាយត្រឹមត្រូវឬក៏អត់? ហើយគាត់ -- សាក្សីបានឆ្លើយថា ទេ។

[១១:៣០:៥៥]

ដូច្នេះ ខ្ញុំគិតថា ខ្ញុំពេញចិត្តជាមួយនឹងចម្លើយរបស់លោកសាក្សីនេះ។ ហើយដូច្នេះខ្ញុំបន្តទៅចំណុចមួយទៀត ប្រសិនបើគាត់ឆ្លើយថា មិនមែនជាជីវទស្សន៍ដែលផ្តល់រយៈពេល៦ខែម្តងទេ ខ្ញុំបន្តទៅមុខទៀត។ ប្រសិនបើអ្វីដែលយើងបន្តទៅមុខទៀតនោះ គឺ--

[១១:៣១:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣១:៤៧]

**ប្រធានអង្គជំនុំ៖**

សាក្សីអាចបន្តចម្លើយរបស់លោកដែលឆ្លើយតបនឹងអម្បាញ់មិញនេះ ប៉ុន្តែសូមឲ្យសង្ខេបខ្លីទៅបានហើយ អំពីសំណួរចុងក្រោយ ដែលកាត់ដោយមេធាវីការពារក្តីអម្បាញ់មិញនេះ។ អង្គជំនុំជម្រះត្រូវការស្តាប់នូវអ្វីដែលជាចម្លើយបញ្ជាក់លើបញ្ហានេះ ដោយសាក្សីផ្ទាល់ នាពេលនេះ។

**លោក សួង ស៊ីគឿន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំចង់ជម្រាបថា កាលៈទេសៈដែលខ្ញុំសរសេរប្រវត្តិរូបនេះជាកាលៈទេសៈពិសេស គឺក្រោយពីមានការចោទប្រកាន់ ក្នុងចម្លើយសារភាពលោក រស់ សារិន ថាខ្ញុំនិងលោកគាត ឈន់ ជាភ្នាក់ងារ សេ.អ៊ី.អា ដូចគាត់ដែរ។ លោក អៀង សារី បានហៅខ្ញុំទៅក្នុងបន្ទប់របស់គាត់ សួរអំពីហេតុនេះ ហើយខ្ញុំ -- ហើយគាត់បានណែនាំឲ្យខ្ញុំសរសេរប្រវត្តិរូបនេះបាទ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។ នេះគឺជាអ្វីដែលលោកបានផ្តល់សក្ខីកម្ម ហើយយើងនឹងទទួលយកនូវចំណុចនេះ។

[១១:៣៣:០៤]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងបន្តទៅចំណុចមួយទៀត គឺឯកសារដែលមានលេខ E1/95.1 ហើយជាប្រតិចារឹកនៃសាក្សី ដេវីដ ឆេនដ័ល័រ ដែលបានផ្តល់សក្ខីកម្មនៅថ្ងៃ២៤ ខែកក្កដា ឆ្នាំ២០១២ ហើយទំព័រ៩ ជាភាសាអង់គ្លេស ហើយភាសាខ្មែរគឺមានលេខ 00826678 ដល់ 79, ភាសាបារាំងគឺមានលេខ

00828657 ដល់ 58, ហើយភាសាអង់គ្លេសគឺ 00828805។ ហើយគេសួរលោកអំពីប្រវត្តិរូប ហើយគាត់ឆ្លើយថា "ខ្ញុំមិនគិតថា នេះគឺជាគោលដៅនៃការធ្វើ ឬក៏ស្នើសុំសមាជិកឲ្យធ្វើការរៀបចំនូវប្រវត្តិរូបនោះទេ។ វាគ្រាន់តែជាសមាជិកបក្សត្រូវធ្វើម្ដងម្កាល តែប៉ុណ្ណោះ"។ ដូច្នេះ អ្វីដែលខ្ញុំចង់និយាយគឺថា គោលដៅសំខាន់ គឺជាការអនុវត្ត ដែលគេអនុវត្តសកល ឬក៏ជាទូទៅ។ ដូច្នេះ សំណួរដែលខ្ញុំចង់សួរលោកគឺថា ថាតើវាជាការអនុវត្ត ឬក៏មិនមែនជាការអនុវត្តក្នុងការសរសេរប្រវត្តិរូប ដូចដែលលោក ដេវីដ ឆេនដ៍ល័រ ដែលជាអ្នកប្រវត្តិវិទូមួយរូបបានបញ្ជាក់? ខ្ញុំមិនចង់និយាយតែ ស-២១ នោះទេ ខ្ញុំចង់និយាយអំពីក្រសួងការបរទេសផង។

[១១:៣៤:៤៨]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំអាចឆ្លើយថា ពួកខ្ញុំដូចមិនដែលសរសេរប្រវត្តិរូបធម្មតា ៦ខែ ឬ១ឆ្នាំសរសេរម្ដងទេ។ ព្រោះអ្នកដឹកនាំស្គាល់អស់ទៅហើយ។ ប្រវត្តិរូបនេះ ដូចខ្ញុំបាន -- របស់ខ្ញុំនេះ ដូចខ្ញុំបានជម្រាបគឺថាធ្វើឡើងដោយកាលៈទេសៈពិសេស ក្រោយការចោទប្រកាន់ថាខ្ញុំជាភ្នាក់ងារ សេ.អ៊ី.អា បាទ។

**ស៖** សូមអរគុណ។ ជាការពិតលោកបានឆ្លើយទៅលើចំណុចនេះនៅថ្ងៃទី៦ ខែសីហា មាននៅក្នុងប្រតិចារឹករួចហើយ ដែលលោកបានឆ្លើយចង្អុលបញ្ជាក់នៅក្នុងនោះ។ នៅពេលនេះប្រសិនបើយើងមើលទៅលើចំណុចមួយវិញ ទំព័រ១០២ ជាភាសាអង់គ្លេស, ខ្មែរគឺ 00832211, បារាំង 00833179, អង់គ្លេសគឺ 00833289។ នៅក្នុងនោះ គឺលោកបានលើកឡើងថា៖ "អៀង សារី បានហៅខ្ញុំទៅមន្ទីរនៅ -- ទៅក្រសួងការបរទេស ហើយដែលក្នុងនោះបាននិយាយថាលោក សារិន គឺជាប្រធានខាងអាកាសចរណ៍ ហើយជាមិត្តរបស់ខ្ញុំ ហើយក៏ជាមិត្តរបស់ គាត ឈន់ ផងដែរ ហើយគេបានចោទថាគាត់នោះគឺជាប្រធានគិញ សេ.អ៊ី.អា។ ដោយសារតែគេចង់ដឹងអំពីថា គាត ឈន់ ហ្នឹងគឺជាគិញ ឬក៏យ៉ាងណានោះហើយទើប អៀង សារី ហៅខ្ញុំទៅសួរពីបញ្ហានេះ"។ ដោយពិចារណាទៅលើចំណុចនេះ យើងក៏គួរមើលឯកសារ D154.2 ដែលនិយាយអំពីប្រវត្តិរូបបដិវត្តន៍របស់ សួង ស៊ីគឿន។ កាលៈទេសៈនៃការសរសេរប្រវត្តិរូប"។ តើលោកមានឯកសារនេះនៅចំពោះមុខដែរឬទេ? ខ្ញុំនិយាយយោងឯកសារត្រង់លេខ ERN ជាភាសាខ្មែរ 00824620, បារាំងគឺ 00--

**អ្នកបកប្រែ៖**

បាទ លោកប្រធានអនុញ្ញាតឲ្យមេធាវីបញ្ជាក់លេខ ERN ជាភាសាបារាំងឡើងវិញ។

[១១:៣៧:៣០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់លេខ ERN ជាភាសាបារាំងឡើងវិញ ព្រោះអ្នកបកប្រែបកអត់ទាន់ទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** 00290701 ទៅដល់ 02, អង់គ្លេសគឺ 00826569។ ខ្ញុំសង្ឃឹមថាអ្នកបកប្រែបានទទួលលេខនេះហើយ។ ឯកសារនេះមានលេខ D154.2។ នៅត្រង់ឯកសារនេះ នៅក្នុងឯកសារនេះ តើនៅពេលដែលលោកមើល តើលោកស្គាល់ទេឯកសារហ្នឹងលោក?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំចាំ គឺឯកសារហ្នឹង ខ្ញុំសរសេរជាបារាំងទេបាទ។ ដូច្នេះ ជាអក្សរដៃខ្ញុំ មិនមានសរសេរជាខ្មែរទេបាទ។ ដូច្នោះបើលទ្ធភាព គឺថាអាចខ្ញុំមានឯកសារច្បាប់ដើមជាសរសេរអក្សរអក្សរដៃខ្ញុំជាបារាំងបាទ។

[១១:៣៩:១៧]

**ស៖** ឯកសារនេះចាប់ផ្តើមដោយលើកឡើងថា ជាបឋមខ្ញុំសូមលើកឡើងពីកាលៈទេសៈ ដែលខ្ញុំបានសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់ខ្ញុំ។ នេះគឺជាចំណុចដែល -- គឺជាឃ្លាដែលបកប្រែផ្លូវការ ហើយបន្ទាប់មកបានលើកឡើងទៀតថា “នៅដើមខែកក្កដា ឆ្នាំ១៩៧៧ អៀង សារី បានកោះហៅខ្ញុំឲ្យទៅកាន់ការិយាល័យរបស់គាត់នៅមន្ទីរប-១ នៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ។ គាត់បានសួរមកកាន់ខ្ញុំប្រកបដោយទឹកមុខមាំថាតើខ្ញុំទាក់ទងជាប្រចាំដែរឬទេ ជាមួយ រស់ សារិន ដែលជាអតីតអគ្គនាយកក្រុមហ៊ុនអាកាសចរណ៍ជាតិ រ៉ូយ៉ាល់អែរកាំបូដស៍។ គាត់មិនបានប្រាប់ខ្ញុំឲ្យបានដឹងទេថា រស់ សារិន ត្រូវបានចាប់ខ្លួន ក្រោមបទចោទថា ជាភ្នាក់ងារចារកម្ម សេ.អ៊ី.អា របស់អាមេរិក។ រស់ សារិន បានឆ្លើយដាក់ខ្ញុំនិង គាត ឈន់”។ នៅទីនេះគឺវាបង្ហាញថា តាមប្រវត្តិរូបលោកសរសេរដោយផ្ទាល់ខ្លួនឯងនេះ ជាច្រើនឆ្នាំក្រោយមក គឺលោកបានលើកឡើងនៅក្នុងនេះថា លោក អៀង សារី មិនបានប្រាប់លោកថា រស់ សារិន បានឆ្លើយដាក់លោកនោះទេ។

[១១:៤០:៥៩]

ខ្ញុំសូម មុនពេលលោកឆ្លើយសំណួរនេះ គឺខ្ញុំសូមមើលទៅទំព័រហ្នឹងដដែល ខាងក្រោម។ “ខ្ញុំមិនដឹងអំពីភាពធ្ងន់ធ្ងរ -- ខ្ញុំទើបតែបានដឹងអំពីភាពធ្ងន់ធ្ងរនៃករណីរបស់ខ្ញុំ ក្រោយពេលដែល ខ្ញុំដឹងខ្លឹមសារ

ចម្លើយសារភាពរបស់ តូច ខាំឡឿន នៅ ខែធ្នូ ឆ្នាំ២០០១"។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើ ក្រោយឆ្នាំ១៩៧៩ នៅពេលដែលលោកមើលចម្លើយសារភាពរួចហើយ ទើបលោកថាមានឈ្មោះរបស់លោកនៅក្នុងហ្នឹង ហើយលោកមានការច្រឡូលច្របល់ទៅនឹងអ្វីដែលលោកបានឆ្លើយនៅក្នុងតុលាការ និងអ្វីដែលលោកបានសរសេរនៅក្នុងប្រវត្តិរូបរបស់លោក។ តើអីចឹងដែរឬទេ?

**លោក គង់ ស៊ីគឿន៖**

**ឆ៖** លោកប្រធានខ្ញុំមិនសូវយល់សំណួររបស់លោកមេធាវី។ សូមគាត់សួរឲ្យច្បាស់ម្តងទៀតបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី តាំងសំណួរជាថ្មីម្តងទៀត! ហើយសូមលោកព្យាយាមបញ្ចៀសនូវសំណួរបែបដឹកមុខ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹងគោរពតាមការណែនាំរបស់អង្គជំនុំជម្រះ។

[១១:៤២:២៩]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី តើលោកនៅតែរក្សានូវខ្លឹមសារដែលលោកសរសេរនៅក្នុងប្រវត្តិរូបរបស់លោកដដែលដែលថា អៀង សារី មិនបានប្រាប់លោកថា រស់ សារិន ត្រូវបានគេចាប់ខ្លួនដោយចោទថាជាភ្នាក់ងារចារកម្ម សេ.អ៊ី.អា ហើយឆ្លើយដាក់លោក។ គឺគាត់មិនប្រាប់លោកអីចឹងទេ តើអីចឹងដែរឬទេលោកនូវតែរក្សាសម្តីដែលលោកបានសរសេរនៅក្នុងប្រវត្តិរូបរបស់លោកដដែល ដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំនៅតែរក្សាអ្វីដែលខ្ញុំបានសរសេរ។

**ស៖** តាមប្រវត្តិរូបរបស់លោក ដែលលោកសរសេរត្រង់ទំព័រដដែលនេះ គឺបានបង្ហាញថាលោកបានអានចម្លើយសារភាពរបស់ តូច ខាំឡឿន គឺនៅក្រោយខែធ្នូ ឆ្នាំ២០០១។ តើលោកនៅតែរក្សាសម្តីដដែលនេះដែរឬទេ?

[១១:៤៣:៣៩]

**ឆ៖** ខ្ញុំមិនសូវយល់សំណួររបស់លោកមេធាវីទេបាទ។

**ស៖** ខ្ញុំលើកឡើងនូវអ្វីដែលលោកបានសរសេរ។ លោកបាននិយាយថា៖ "ខ្ញុំទើបនឹងបានដឹងអំពីភាពធ្ងន់ធ្ងរនៃករណីរបស់ខ្ញុំក្រោយពេលដែលខ្ញុំបានដឹងខ្លឹមសារនៃចម្លើយសារភាពរបស់ តួច ខាំឌឿន នៅខែធ្នូ ឆ្នាំ២០០១"។ ដូច្នេះ តើត្រឹមត្រូវដែរឬទេដែរយើងអាចនិយាយថា ក្រោយខែធ្នូ ឆ្នាំ២០០១ នោះទើបលោកបានអាន និងបានដឹងអំពីចម្លើយសារភាពរបស់ តួច ខាំឌឿន។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ដូច្នេះមែន គឺថា ខ្ញុំបានដឹងចម្លើយសារភាពរបស់លោក តួច ខាំឌឿន នៅឆ្នាំ២០០១ បាទ។

**ស៖** លោកបានកត់សម្គាល់ថា លោកគឺជាអ្នកប្រវត្តិសាស្ត្រម្នាក់ដែលដឹងច្រើន ហើយលោកបានជម្រាបយើងកាលពីសប្តាហ៍មុន នៅថ្ងៃ១៦ ខែសីហា សប្តាហ៍មុន គឺលោកបានជម្រាបយើងខ្ញុំនៅក្នុងចម្លើយរបស់លោក។ ការងារសរសេរប្រវត្តិរូបរបស់លោកនេះ តើលោកបានយោងទៅលើឯកសារប្រវត្តិសាស្ត្រដែរឬទេ? ឬក៏លោកបានមើលចម្លើយសារភាពរបស់អ្នកដែលធ្វើការរួមជាមួយលោកពីមុនដែរឬទេ នៅពេលដែលលោកសរសេរប្រវត្តិរូបនេះ?

**ឆ៖** ខ្ញុំមិនបានមើលចម្លើយសារភាពអ្នកណាទេ បាទ ខ្ញុំ -- ក្នុងពេលដែលខ្ញុំសរសេរប្រវត្តិរូបនេះ។

**ស៖** សូមអរគុណ។ តើលោកបានអានចម្លើយសារភាពរបស់ រស់ សារិន ដែរឬទេ?

[១១:៤៦:១៥]

**ឆ៖** ខ្ញុំបានអាន ប៉ុន្តែដូចបានអានពីឆ្នាំ២០១០ មក ខ្ញុំទៅរកឯកសារហ្នឹង នៅទួលស្លែង ខ្លួនខ្ញុំតែម្តង។

**ស៖** ចំណុចនេះហើយ ដែលខ្ញុំចង់សួរឲ្យលោកឆ្លើយពីមុន គឺបានន័យថា ក្រោយពេលលោកសរសេរប្រវត្តិរូបផ្ទាល់របស់លោក។ ក្រោយពេលនោះ ជាច្រើនឆ្នាំមក គឺទើបលោកបានឃើញ និងបានពិនិត្យមើលលើចម្លើយសារភាពផ្សេងៗទៀត ជាច្រើន តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទៗ អ៊ីចឹងហើយបាទ។

**ស៖** ខ្ញុំយល់ថា នៅក្រោយពេលដែលលោកអានចម្លើយសារភាពទាំងអស់នោះហើយ ទើបលោកកត់សម្គាល់ឃើញថា នៅពេលដែលគេឆ្លើយសារភាពនោះ នៅពេលដែលគេឆ្លើយដូច្នោះហើយ ទើបគេចាត់ទុកឲ្យលោកនោះ សរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់លោក?

[១១:៤៧:៣៩]

**ឆ៖** អត់ទោសលោកប្រធាន ខ្ញុំដូចមិនសូវយល់ទេ សំណួររបស់គាត់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អាចតាំងសំណួរសាជាថ្មី ព្រោះពិបាកយល់សំណួរជាភាសាខ្មែរ វាពិបាកយល់។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅពេលដែលលោកអានចម្លើយសារភាពនានានោះមក ជាពិសេសចម្លើយសារភាពរបស់ រស់ សារិន។ នៅពេលនោះ តើលោកបានពិនិត្យ និងយកចិត្តទុកដាក់ទៅលើកាលបរិច្ឆេទថា គេបានសរសេរនៅពេលណា? ហើយគិតអំពីពេលដែលគេស្នើសុំនោះ ឲ្យលោកសរសេរចម្លើយសារភាព តើលោកមានគិតអំពីចំណុចទាំងអស់នោះទេ នៅពេលនុ៎ង?

[១១:៤៨:៤០]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំក៏នៅដូចអត់ច្បាស់អំពីសំណួរនេះដែរ បាទ។

**ស៖** បាទ ខ្ញុំសូមបន្តទៅមុខ។ យោងតាម ឡុង នរិន្ទ នៅក្នុងចម្លើយរបស់គាត់ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារលេខ E3/34។ គាត់បានបញ្ជាក់នៅក្នុងទំព័រលេខ៤ ជាភាសាអង់គ្លេស -- ខ្មែរ គឺ 00204007 ទៅដល់ 08, បារាំង គឺ 00491003 ទៅដល់ 04, អង់គ្លេស គឺ 00223556។ នៅក្នុងនោះ បានលើកឡើង -- ឡុង នរិន្ទ បានលើកឡើងថា "គឺលោកបានស្នើសុំឲ្យគាត់ហ្នឹង សរសេរប្រវត្តិរូប"។ តើត្រឹមត្រូវដែរឬទេ ដែល ឡុង នរិន្ទ នេះនិយាយយ៉ាងត្រឹមត្រូវ ដែលថាលោកហ្នឹង នៅក្រសួងការបរទេស ដែលឲ្យគាត់ហ្នឹង សរសេរប្រវត្តិរូបរបស់គាត់? ប្រសិនបើលោកនឹកឃើញហើយចាំ តើអ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹងមែន ព្រោះគាត់នៅជាសមាជិកនៅក្នុងផ្នែករបស់ខ្ញុំបាទ។

[១១:៥០:២៣]

**ស៖** ប្រវត្តិរូបនោះ គឺប្រវត្តិរូបមួយ ដែលលោក ឆាំង យុ បាននិយាយថា ត្រូវបានស្នើសុំឲ្យសរសេររាល់៦ខែម្តង ឬក៏ជាប្រវត្តិរូបផ្សេង។ តើលោកចាំទេ ហើយលោកនឹកឃើញទេ? បើសិនជាលោកនឹកមិនឃើញ ហើយមិនចាំទេ មិនជាបញ្ហាអ្វីនោះទេ។

**ឆ៖** ប្រវត្តិរូបដែលខ្ញុំស្នើឲ្យលោក ឡុង នរិន្ទ សរសេរហ្នឹង គឺថា ដូចប្រវត្តិរូបដែលលោក អៀង សារី បានស្នើខ្ញុំសរសេរ ព្រោះមានការចោទប្រកាន់ថា លោក ឡុង នរិន្ទ ហ្នឹង ជាភ្នាក់ងាររបស់ សេ.អ៊ី.អា ពេលដែលគាត់ដឹកនាំនិស្សិតខ្មែរ នៅឆេកូស្លូវ៉ាគី ពេលនោះ នៅ -- ខ្ញុំថានៅឆ្នាំ១៩៧១ ឬ ៧២ ខ្ញុំមិនចាំច្បាស់ទេ។ ពេលដែលទៅវិស្ថានទូត របស់សាធារណរដ្ឋខ្មែរប្រចាំប្រទេសឆេកូស្លូវ៉ាគី ហើយ កាន់កាប់ស្ថានទូតនោះបាទ ជាមួយដូចពេលនោះ មានដូច អ៊ុស៊ុប គន្ធី នៅទីនោះដែរបាទ។ ក្នុងកាលៈ-ទេសៈនេះគឺ គេបានចោទប្រកាន់លោក ឡុង នរិន្ទ ថាការដែលទៅវិស្ថានទូតនេះគឺជាសកម្មភាពរបស់ អង្គការចាត់តាំងសហរដ្ឋអាមេរិក សេ.អ៊ី.អា ធ្វើឡើងដើម្បីស្រួលបង្កប់ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា បាទ។ ដូច្នោះ ប្រវត្តិរូបរបស់លោក ឡុង នរិន្ទ នេះមិនមែនជាប្រវត្តិរូបធ្វើ៦ខែម្តង ឬ១ឆ្នាំម្តងទេ គឺជាប្រវត្តិរូបធ្វើឡើងក្នុងកាលៈទេសៈពិសេសបាទ។

[១១:៥២:១៨]

**ស៖** បាទ យើងនិយាយអំពីលោក ឡុង នរិន្ទ មែនទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណលោក។ ចំពោះពេលវេលាដែលនៅសល់នេះ គឺខ្ញុំសូមចូលទៅដល់ប្រធានបទ មួយទៀត ដើម្បីឲ្យបញ្ជាក់បំភ្លឺ គឺពាក់ព័ន្ធទៅនឹងការដែលលោកទាក់ទងជាមួយនឹង ភី ភួន នៅពេល ដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ។ ខ្ញុំសូមត្រឡប់សួរអំពីចំណុចនេះ នៅថ្ងៃ១៤ ខែសីហា ឆ្នាំ២០១២ ទំព័រ១០៤ ជាភាសាអង់គ្លេស, ខ្មែរគឺ ៨៤, បារាំងគឺទំព័រ ១១៥ ទៅដល់ ១១៦។ លោកបានលើកឡើងថា "គាត់បានទូរស័ព្ទមកកាន់ខ្ញុំ ហើយខ្ញុំបានទៅជួបគាត់"។ នេះគឺអ្វី ដែលលោកបានឆ្លើយនៅថ្ងៃ១៤ សីហា ឆ្នាំ២០១២។ ខ្ញុំចង់យល់ឲ្យបានច្បាស់ នៅពេលដែលខ្ញុំសួរលោក លោកហាក់ដូចជា បង្ហាញថា លោក ជាអ្នកទូរស័ព្ទទៅកាន់គាត់។ តើមួយណា? គាត់ទូរស័ព្ទមកលោក ឬក៏លោកហៅទៅគាត់?

**ឆ៖** បាទ ទូរស័ព្ទវាពីរដង គឺម្តង លោក ភី ភួន ហ្នឹងប្រាប់ខ្ញុំថា គាត់មកដល់ភ្នំពេញហើយ ហើយខ្ញុំសូមជួបគាត់ហ្នឹង មិនមែនពេលជាមួយគ្នាហ្នឹងទេ ពេលក្រោយទេ។ ដូច្នោះ ខ្ញុំថាឥឡូវ តើ ជាម ឯងនៅកន្លែងណា ខ្ញុំនឹងជួបបាទ។ ដូច្នោះ ខ្ញុំជាអ្នកផ្តើមគំនិតជួបគាត់បាទ។ ហើយខ្ញុំអាចបញ្ជាក់ លោកមេធាវីថា បើក្រៅពីខ្ញុំ មើលទៅគាត់មិនជួបទេ ព្រោះខ្ញុំមិនបានសម្តីដែលគាត់និយាយហ្នឹងមិន ច្បាស់លាស់ទេ។ ប៉ុន្តែដោយសារខ្ញុំ គាត់មិនហ៊ានថាទេបាទ។

[១១:៥៤:២៨]

**ស៖** សូមអរគុណ។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ ត្រង់ទំព័រ ៤៩ ខ្មែរ ទំព័រ ៤០ ដល់ ៤១, បារាំងគឺ ទំព័រ៥២ ដល់ ៥៣ លោកបាននិយាយថា "ខ្ញុំមិនចាំច្បាស់នោះទេ នៅពេលដែលចាកចេញពីម៉ាឡៃនោះ នៅពេលព្រឹកនោះ ក៏គាត់មកផ្ទះរបស់ខ្ញុំ។ គាត់បានយកឯកសារមកជាមួយ គឺនៅប្រហែលជាម៉ោងប្រាំមួយព្រឹក នៅម៉ោងប្រាំបួនទៅម៉ោងដប់នោះ ខាង អ.វ.ត.ក គេយកគាត់ពីផ្ទះគាត់ពីម៉ាឡៃទៅភ្នំពេញ។ នៅទីនេះគឺគាត់ -- លោកបានជម្រាបយើងខ្ញុំថា គាត់នោះបានមកផ្ទះលោកនៅម៉ោងប្រាំមួយព្រឹក ហើយយកឯកសារមកជាមួយ។ តើនោះគឺជាការជួបលើកដំបូងហើយដែលបានជួបនៅពេលនោះ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ជួបអ៊ីចឹងមែន គឺថាគាត់សម្ភាសរបស់គាត់ដែលផ្សាយជាប្រវត្តិរូបរបស់គាត់ដែលផ្សាយក្នុងទស្សនាវដ្ដីការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមកដល់ខ្ញុំ ម៉ោងប្រាំមួយ រួចគាត់ទៅចម្ការ។ គាត់ថាទៅចម្ការទៅដកដំឡូង ឆ្លៀតដកដំឡូងបន្ដិចមុននឹងឡានរបស់តុលាការទៅយកគាត់ម៉ោងប្រាំបួនឬម៉ោងដប់បាទ គាត់ប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** សូមអរគុណ។ តើគាត់ហ្នឹងយកឯកសារហ្នឹងដោយខ្លួនឯងមក ឬក៏គាត់ជាអ្នកស្នើ ឬក៏លោកជាអ្នកស្នើសុំឱ្យគាត់យកឯកសារ ដែលគេចុះផ្សាយក្នុងទស្សនាវដ្ដីស្វែងរកការពិតដោយ ឌី.ស៊ី.ខេម នោះ? លោកជាអ្នកស្នើសុំ ឬក៏គាត់យកមកដោយខ្លួនឯង?

[១១:៥៦:៣២]

**ឆ៖** ខ្ញុំអ្នកស្នើសុំឱ្យគាត់យកមក ព្រោះគាត់បានប្រាប់ថា មានគេផ្សាយពីរឿងគាត់ ហើយខ្ញុំក៏បាន។

**ស៖** សូមអរគុណ។ ហើយលោកក៏បានបន្ដនិយាយទៀតថា នៅទំព័រដដែលទេ លោកបាននិយាយបន្ថែមទៀតថា គាត់មិនមានអ្វីនិយាយទេ ហើយខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកសិន សាក្សី អញ្ជើញសាក្សីទៅបត់ជើង? អញ្ជើញចុះបាទ!

មន្ត្រីរដ្ឋបាលតុលាការសម្រួលដំណើររបស់គាត់។

*(សាក្សីទៅបន្ទប់ទឹក)*

[១១:៥៧:៣៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តីលោក អៀង សារី តើលោកត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

[១១:៥៧:៥០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការប្រហែលជា១០នាទី ប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយសាក្សីមិនអាចទៅរួចទេ ឥឡូវសាក្សីសម្រាកសិនចុះ!

មន្ត្រី -- មេធាវីការពារ --មេធាវីប្រឹក្សាសាក្សីសម្រាកសិន ហើយនាំគាត់ទៅសម្រាកចុះ!

ចុះលោកមេធាវីការពារក្តីលោក អៀង សារី -- អ៎! លោក នួន ជា តើត្រូវមានពេល -- មានសំណួរអ្វីចង់សួរសាក្សីរូបនេះដែរទេ? ហើយដែលបន្ថែមលើឯកសារមួយដែលយើងបានសម្រេចរួចហើយកាលពីព្រឹកមិញ ហើយប្រសិនបើត្រូវការសួរហ្នឹង តើអាចប្រមើលមើល៍ អាចត្រូវការប្រើពេលវេលាប៉ុន្មាន?

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរតែបីទេ ពាក់ព័ន្ធទៅនឹងឯកសារដែលយើងខ្ញុំអនុញ្ញាតឲ្យយកមកប្រើប្រាស់។ សំណួរដែលខ្ញុំចង់សួរនោះគឺ បានឆ្លើយក្នុងពេលដែលលោក កាណាវាស បានសួររួចមកហើយ។ ដូច្នេះហើយខ្ញុំដូចជាមិនត្រូវការពេលវេលាបន្ថែមនោះទេ។

[១១:៥៩:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដែលលោកបានបង្ហាញ បញ្ជាក់ច្បាស់លើបញ្ហានេះ ប៉ុន្តែឥឡូវនេះដោយសារសាក្សីនេះមានបញ្ហាសុខភាព ហើយមិនអាចបន្តផ្តល់សក្ខីកម្មបានទេ ទោះបី ១០មីនុតក៏ដោយ តាមទំនងនាពេលនេះ។

មន្ត្រីរដ្ឋបាលតុលាការទៅពិគ្រោះជាមួយគាត់ចុងក្រោយមើល ថាតើៗ ១០មីនុតអី គាត់អាចបញ្ចប់បានទេ ដើម្បីគាត់មានលទ្ធភាពអាចបញ្ចប់ពេលនេះ គាត់អាចវិលត្រឡប់ទៅលំនៅដ្ឋានតែម្តងនៅក្រោយ នៅពេលអាហារថ្ងៃត្រង់នេះ?

លោកមេធាវីចាំ -- រង់ចាំផងណ៎ា! ពិគ្រោះជាមួយគាត់សិន។ បើសិនជាគាត់អាចបន្ត សូមលោកបន្តប្រហែល១០មីនុតទៀត ដើម្បីបញ្ចប់សំណួរដេញដោលដោយមេធាវីការពារក្តីលោក អៀង សារី ពីព្រោះឥឡូវហ្នឹងមេធាវីការពារក្តី នួន ជា ទំនងគាត់មិនត្រូវការពេលវេលាបន្តទៀតទេ។ ដូច្នេះពេលវេលាតែ១០នាទីទេ មិនគួរឲ្យគាត់ទៅធ្វើដំណើរមកស្អែកទៀតទេ វាមិនទំនង។

[១២:០០:២៣]

*(សម្រាករយៈពេលខ្លី)*

[១២:០១:០៥]

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល កាណាវាស តើភាពចាំបាច់ដែរទេឥឡូវហ្នឹង នៅមីនុត ចុងក្រោយ ព្រោះឥឡូវហ្នឹងគាត់ទៅមិនរួចទេ ព្រោះសូម្បីតែរសៀលទៅមិនរួចដែរ។ ហើយពេលវេលាដែលលោកស្នើតាំងសំណួរហ្នឹង គឺតែ១០មីនុតទៀតទេ។ តើសារៈសំខាន់នៃសំណួរ១០មីនុត តើចាំបាច់ក្នុងការឲ្យគាត់វិលត្រឡប់មកវិញនៅថ្ងៃដែរឬទេ ដើម្បីអង្គជំនុំជម្រះសម្រេចពិចារណាលើបញ្ហានេះ? ពីព្រោះគាត់មើលទៅស្ថានភាពសុខភាពគាត់មានអាការៈមិនល្អទេ ហើយគាត់បានបង្ហាញច្បាស់ថា គាត់មិនអាចមកផ្តល់សក្ខីកម្មនៅរសៀលនេះទេ ហើយបើស្អែកមកតែ១០មីនុត នោះ តើយ៉ាងម៉េចដែរ?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានកាត់បន្ថយរយៈពេលកន្លះម៉ោងទៅលើការសួរដេញដោលរួចមកហើយ។ ខ្ញុំគឺត្រូវការដើម្បីចង់បញ្ជាក់ទៅលើចំណុចមួយចំនួនទៅកាន់សាក្សី ហើយនៅពេលនេះ គឺនៅពេលដែលយើងមើលប្រតិចារឹកនោះ គឺថាយើងមានចំណុចមួយចំនួនទៀតដែលយើងត្រូវសួរបញ្ជាក់។ ដូច្នេះហើយខ្ញុំនៅតែចង់ទុកពេល១០នាទីនេះ ដើម្បីឲ្យសាក្សីត្រឡប់មកវិញនៅថ្ងៃស្អែក ដើម្បីយើងខ្ញុំដេញដោលបន្ថែមបញ្ជាក់លើចំណុចទាំងអស់នេះ។ សូមអធ្យាស្រ័យដែរ លោកប្រធាន។

[១២:០២:២៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ហើយយើងមិនអាចបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន បានទេ។ ទោះបីពេលវេលាតែ១០នាទីក៏ដោយ ក៏បញ្ហាធ្ងន់ធ្ងរផ្នែកខាងសុខភាព។ ហើយដោយសារភាពចាំបាច់នៃការសួរដេញដោលរបស់មេធាវីការពារក្តី អង្គជំនុំជម្រះសូម

អញ្ជើញលោក សួង ស៊ីគឿន មកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ហើយចំណាយពេលប្រហែលជាអតិបរមា ១០នាទី តាមការកំណត់ស្នើសុំរបស់មេធាវីការពារក្តី លោក នួន --អ៎!លោក អៀង សារី។ ដូច្នេះជាពេលវេលាចុងក្រោយហើយ ដែលថាសាក្សីប្រឈមនឹងសម្ពាធនៃការតាំងសំណួរដេញដោលនៅក្នុងអង្គសវនាការនេះ។ ហើយសូមសាក្សីអត់ធ្មត់ ហើយសូមអញ្ជើញមកបន្តស្តាប់សក្ខីកម្មតាមការកំណត់ គឺចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

[១២:០៣:២២]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែង -- សម្របសម្រួល ហើយនិងប្រគល់គាត់ឲ្យទៅពេទ្យពិនិត្យសុខភាពគាត់ភ្លាម ហើយនិងរួចសម្រួលបញ្ជូនត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំចង់តាមដាននីតិវិធីនៅបន្ទប់រង់ចាំខាងក្រោម ដោយសារគាត់ឈឺចង្កេះ និងការឈឺក្បាល ហើយនិងមិនមានការផ្តង់អារម្មណ៍ឲ្យបានខ្ជាប់ខ្ជួន។ ដូច្នេះហើយយើងខ្ញុំក៏បានរៀបចំលិខិតបោះបង់សិទ្ធិនេះផងដែរ ជូនលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ម្តងទៀតមើល៍! តើលោក -- កូនក្តីរបស់លោកចង់ ឬក៏គ្រាន់តែជាការស្នើសុំទេ? ឬក៏គាត់ចង់ធ្វើដូច្នេះ? “ចង់” និង “ការស្នើសុំ" ដូចមាន -- ពាក្យហ្នឹងខុសគ្នាឆ្ងាយណាស់។

[១២:០៤:៣៧]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យច្បាស់ គឺកូនក្តីរបស់ខ្ញុំគាត់មានការឈឺក្បាល ឈឺចង្កេះ និងការមិនអាចផ្តង់ៗ អារម្មណ៍ជាទូទៅបាន។ ដូច្នេះហើយគឺគាត់សុំ និងចង់ទៅបន្តការតាមដាននីតិវិធីនៅបន្ទប់រង់ចាំខាងក្រោម។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមឧបករណ៍សោតទស្សន៍

រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ តម្រូវឱ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

[១២:០៥:៥១]

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឱ្យ នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចតាម -- ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឱ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤៣]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កាលពីថ្ងៃព្រហស្បតិ៍ ក៏ដូចជាអម្បាញ់មិញនេះ យើងបានបញ្ជាក់ហើយថាលោក សួង ស៊ីគឿន នឹងបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែក

ហើយតាមកាលវិភាគដែលបានលើកពីថ្ងៃមុន គឺនៅរសៀលនេះ បន្តស្ដាប់សក្ខីកម្មសាក្សី ស សៀក។ ប៉ុន្តែអម្បាញ់មិញនេះ គឺមានព័ត៌មានចេញមកពីប្រភពនៃសាក្សី សួង ស៊ីគឿន ថា គាត់អាចមានលទ្ធភាព មានកម្លាំងកំហែងឡើងវិញ អាចសូមផ្ដល់សក្ខីកម្មបញ្ចប់នៅរសៀលនេះ។

លោក ឌុច ផារី យ៉ាងម៉េចដែរលើស្ថានភាពសុខភាពរបស់លោក សួង ស៊ីគឿន ហើយតើគាត់មានសំណើសុំអ៊ីចឹងពិតមែនដែរទេ?

[១៣:៣២:២២]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សាក្សីលោក សួង ស៊ីគឿន គាត់មានបំណងក្នុងការបញ្ចប់សក្ខីកម្មរបស់គាត់នៅពេលរសៀលនេះដូច្នេះមែនបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ម៉ៃខល កាណាវាស តើមានបញ្ហាអីទេ? បើសិនជាអង្គជំនុំជម្រះបន្តការស្ដាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន នាពេលនេះដោយតាំងសំណួររបស់លោកបញ្ចប់ ដែលលោកអះអាងព្រឹកមិញថា ចំណាយពេលប្រហែល ១០នាទីទៀតនោះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំអត់មានបញ្ហាអ្វីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញលោក សួង ស៊ីគឿន និងមេធាវីប្រឹក្សារបស់គាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[១៣:៣៤:១២]

បាទ ដើម្បីបង្កើនល្បឿននៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ហើយ

សូមសួរលោកសាក្សី។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** នៅពេលព្រឹកនេះ យើងបានផ្អាកនៅត្រង់ចំណុចមួយដែលនិយាយអំពីសក្ខីកម្មនៅថ្ងៃ១៥ ខែ៨ ដែលលោកបានបញ្ជាក់ថា លោកបានទូរស័ព្ទទៅលោក ភី ភួន ហើយលោក ភី ភួន បានមកជួប លោកនៅផ្ទះ នៅម៉ោងប្រាំមួយពេលព្រឹក។ ហើយលោក ភី ភួន បានទុកនូវចម្លើយរបស់គាត់ដែល ផ្តល់ទៅ ឌី.ស៊ី.ខេម ឲ្យលោកមើល គឺនៅទំព័រ៧ ខ្មែរ គឺ៤០ ដល់៤១, បារាំង គឺ ៥២ ដល់ ៥៣, និងអង់គ្លេសគឺ ទំព័រ៤៩ និង៥០។ ប្រសិនបើយើងទៅមើលក្រោមបន្តិច គឺវាបាននិយាយថា -- គេសួរថា "តើគាត់មានអ្វី? ថាតើគេផ្តល់អ្វីដល់លោក?" ហើយលោកបានឆ្លើយថា "អត់មានទេ។ គាត់ក៏អត់មាន ហើយខ្ញុំក៏អត់មាន។ ពេលព្រឹក គាត់ស្រស់ស្រូបអាហារពេលព្រឹកជាមួយនឹងតំណាងរបស់អង្គភាពគាំពារ សាក្សីម្នាក់ ហើយយើងមិនបាននិយាយអ្វីពាក់ព័ន្ធនឹងតុលាការទេ" ហើយលោកបាននិយាយបន្តទៅទៀត ដោយផ្តល់នូវហេតុផលនៃការជួបគ្នារបស់លោក។

[១៣:៣៦:០២]

ឥឡូវនេះ យើងនិយាយអំពីការប្រជុំ -- ការជួបគ្នានេះ តើលោកជួបតែមួយ ឬក៏ពីរ? គឺថានៅ ថ្ងៃ១៥ ខែ៨ ហ្នឹង លោកបាននិយាយថា "ដំបូង គឺលោកបានជួបគ្នា នៅម៉ោងប្រាំមួយព្រឹក នៅផ្ទះរបស់ លោក" ហើយបន្ទាប់មកទៀត អាចថានៅថ្ងៃហ្នឹង ឬក៏នៅពេលក្រោយ គឺលោកបានជួបគ្នានៅពេល ស្រស់ស្រូបអាហារពេលព្រឹកជាមួយតំណាងរបស់អង្គគាំពារសាក្សី និងអ្នកជំនាញម្នាក់។ តើមានការ ជួបគ្នាតែម្តង ឬក៏ជួបគ្នាដល់ទៅពីរដង?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំជួប លោក ភី ភួន ពីរដង។ ម្តងមុនគាត់ចេញដំណើរមកភ្នំពេញ ពីម៉ាឡៃ គឺខ្ញុំជួប -- គាត់មកជួបខ្ញុំនៅផ្ទះខ្ញុំនៅម៉ាឡៃ។ ហើយក្រោយមក គឺថាជួបគាត់ម្តងទៀត នៅសណ្ឋាគារមិត្តភាព នៅជិតវត្តកោះ បាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកជួបគាត់នៅពេលទី២ ថាតើនៅពេលដែលលោកជួប ហ្នឹង លោក ភី ភួន គាត់កំពុងតែនៅក្នុងផ្តល់សក្ខីកម្មដល់តុលាការ ឬមួយក៏អត់ទេ?

**ឆ៖** គាត់ផ្តល់ហើយ ប៉ុន្តែទាន់ចប់ទេ។ គាត់ផ្តល់ដូច ខ្ញុំតាមចាំ ដូចខ្ញុំជួបគាត់នៅថ្ងៃសុក្រ បាទ។ ថ្ងៃសុក្រ គាត់រៀបទៅផ្ទះកូនគាត់។ កូនគាត់នៅផ្សារដើហុយ ឬនៅឯណាទេបាទ។ គាត់ទៅផ្ទះកូនគាត់

គាត់ប្រាប់ខ្ញុំថា គាត់ទៅថ្ងៃសុក្រ ថ្ងៃសៅរ៍ ហើយយប់ថ្ងៃអាទិត្យ គាត់នឹងមកសម្រាកនៅសណ្ឋាគារមិត្តភាពជិតវត្តកោះវិញបាទ។

**ស៖** ដូច្នេះ ខ្ញុំសូមបញ្ជាក់ឡើងវិញថា អ្វីដែលបានខ្ញុំស្តាប់ គឺត្រឹមត្រូវ។ លោកជួបគាត់ពីរដង។ ទី១ នៅផ្ទះ។ នៅពេលនោះ គាត់មកផ្ទះលោកដោយយកឯកសារ ហើយបន្ទាប់មកគាត់មកផ្តល់សក្ខីកម្ម ដើម្បីផ្តល់សក្ខីកម្ម ហើយគាត់ត្រឡប់ទៅវិញ ទៅម៉ាឡៃ ហើយនៅទីនោះ គឺលោកជួបគាត់ជាលើកទី២។

[១៣:៣៨:២៥]

**ឆ៖** មិនមែនទេ។ ខ្ញុំជួបគាត់លើកទី១ នៅម៉ាឡៃ ហើយគាត់មកភ្នំពេញ ផ្តល់សក្ខីកម្ម ហើយខ្ញុំមកភ្នំពេញ ដូចក្រោយគាត់មួយថ្ងៃ ឬក៏ពីរថ្ងៃ ហើយខ្ញុំជួបគាត់លើកទី២ នៅសណ្ឋាគារមិត្តភាព នៅជិតវត្តកោះនេះបាទ។

**ស៖** តើលោកមានពិភាក្សាជាមួយគាត់ នៅពេលដែលលោកជួបលើកទី១ គឺពិភាក្សាអំពីសក្ខីកម្មដែរឬទេ? ព្រោះផ្អែកតាមសក្ខីកម្មរបស់គាត់ -- របស់លោក គឺលោកថា ភី ភួន គាត់នាំយកចម្លើយដែលផ្តល់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង យកមកឲ្យលោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពេលខ្ញុំជួបលោក ភី ភួន ជាលើទី១ នៅផ្ទះខ្ញុំនៅម៉ាឡៃ គឺថាគាត់បានយកសម្ភាសរបស់គាត់ជាមួយទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមកឲ្យខ្ញុំ។ សម្ភាសនេះធ្វើយូរហើយបាទ មិនមែនធ្វើក្នុងពេលឆាប់ៗនេះទេបាទ។

[១៣:៣៩:៤៨]

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា អ្វីដែលខ្ញុំទទួល គឺត្រឹមត្រូវ។ ថាតើគាត់យកឯកសារហ្នឹងមកខ្លួនឯង ឬក៏លោកស្នើសុំឲ្យគាត់យកឯកសារហ្នឹងមក? ហើយប្រសិនបើលោកស្នើសុំឲ្យគាត់យកមកនោះ តើមានបានសួរអំពីសក្ខីកម្មដែលគាត់បានផ្តល់នូវតុលាការដែរឬទេ?

**ឆ៖** ខ្ញុំបានស្នើសុំឯកសារហ្នឹងដោយខ្លួនខ្ញុំ ក៏ប៉ុន្តែពេលដែលខ្ញុំជួបគាត់ហ្នឹង គឺមុនដែលគាត់អញ្ជើញមកភ្នំពេញដើម្បីផ្តល់សក្ខីកម្មចំពោះអង្គសវនាការនេះ។ ដូច្នោះគាត់ គឺពេលដែលគាត់អញ្ជើញមកផ្តល់សក្ខីកម្មនៅមុខតុលាការនេះ។ ដូច្នោះគាត់មិនបានផ្ញែ -- នៅពេលមុន ខ្ញុំចង់ថា ដូច្នោះគាត់មិនមានព័ត៌មានអីឲ្យខ្ញុំ ចំពោះសវនាការដែលគាត់បានធ្វើទេបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយនៅត្រង់ចំណុចមួយនោះលោកបាននិយាយថា ហេតុផលដែលលោកចង់ជួបលោក ភី ភួន នុ៎ង គឺថាលោកអាចរៀបចំនូវចម្លើយចំពោះតុលាការ ហើយនេះគឺ

ជាអ្វីដែលខ្ញុំចង់ដឹង ហេតុអ្វីបានជាលោកគិតថា ចាំបាច់ត្រូវលោករៀបចំខ្លួននៅពេលដែលលោកត្រូវមកផ្ដល់ភស្តុតាង ហើយនិងធ្វើការរៀបចំខ្លួន? ហេតុអ្វីចាំបាច់ត្រូវសួរ ភី ភួន ដើម្បីឲ្យលោកអាចរៀបចំខ្លួនមកតុលាការហ្នឹងបាន?

[១៣:៤១:២៨]

**ឆ៖** ខ្ញុំគ្រាន់តែចង់ត្រៀមអីទេ មិនមានអីទេបាទ។ ចង់សួរថា គេសួរគាត់ពីស្អី? អ្វីខ្លះ? ជាគោលៗស្រួលខ្ញុំនឹងថា -- ដូចថាខ្ញុំគិតមុនព្រោះដើម្បីឲ្យបានផ្ដល់សក្ខីកម្មចំពោះតុលាការឲ្យបានពេញលេញព្រោះខ្ញុំវាយូរហើយ វាភ្លេចដែរបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំដឹងថាតាមៗអ្វីដែលលោកផ្ដល់សក្ខីកម្មគឺថាលោកបានស្ដាប់ការផ្ដល់សក្ខីកម្មរបស់លោក ភី ភួន តាមវិទ្យុ ហើយលោកមិនបាននិយាយជាមួយគាត់ទេ។ យើងដឹងថាលោកបានអាននូវចម្លើយរបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកបាននិយាយថាគាត់ឲ្យលោកមុនពេលដែលលោកមកផ្ដល់សក្ខីកម្ម តើមានអ្វីផ្សេងទៀតដែលលោកបានអាន បានសិក្សាក្រៅពីចម្លើយរបស់លោកមុនពេលដែលលោកមកផ្ដល់សក្ខីកម្ម មកផ្ដល់ភស្តុតាងនៅទីនេះ?

[១៣:៤២:៣៣]

**ឆ៖** ខ្ញុំមិនមានបានអានចម្លើយរបស់គាត់ជា -- ពេលដែលគាត់មកធ្វើសក្ខីកម្មនៅកន្លែងនេះទេ។ ខ្ញុំអាននៅក្នុងទស្សនាវដ្ដីស្វែងរកការពិតហ្នឹង អានដូចជាប្រវត្តិរូបរបស់គាត់អីចឹង។ បាទ ដូចឈ្មោះគាត់ដែលគាត់ឲ្យនៅក្នុងតុលាការនេះ ខ្ញុំមិនដែលបានឮទេ ខ្ញុំស្គាល់គាត់តែ ភី ភួន ឬ ជាម តែប៉ុណ្ណឹងទេបាទ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកសាក្សី។ ខ្ញុំមិនមានសំណួរអីបន្ថែមទេ ហើយខ្ញុំសូមអរគុណចំពោះលោកសាក្សីដែលបានអញ្ជើញមកតុលាការដើម្បីផ្ដល់នូវភស្តុតាង ហើយក្នុងនាមលោក អាង ឧត្ដម និងលោក អៀង សារី ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ហើយសូមជូនពរឲ្យលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ ហើយខ្ញុំគិតថា ខ្ញុំសូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលារបស់លោក។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

អរគុណលោក សួង ស៊ីគឿន។ លោក សួង ស៊ីគឿន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក ហ្នឹងលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោកដែលបានធ្វើដំណើរមកពីទីឆ្ងាយ ហើយនិងចំណាយពេលវេលាដ៏មានតម្លៃជាច្រើនថ្ងៃ អញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយដោយលោកបានខិតខំអស់ពីសមត្ថភាព។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមលោកមានសុខភាពល្អ ហើយជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានរបស់គាត់វិញ ឬក៏កន្លែងគោលដៅដែលគាត់មានបំណង។

ទៅចុះបានហើយ!

[១៣:៤៥:០៦]

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី ស សៀក។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី ស សៀក ចូលមកកាន់ទីកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។ ហើយប្រសិនបើមានបុគ្គលជំនួយស្មារតីគាត់នោះ សូមអញ្ជើញមកជាមួយតែម្តង។

*(មានបញ្ហាបច្ចេកទេស)*

*(សាក្សីចូលក្នុងបន្ទប់សវនការ)*

[១៣:៤៦:២១]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា បញ្ហាអត់មានការបកប្រែភាសាទេ។

*(មានបញ្ហាបច្ចេកទេស)*

[១៣:៤៩:២៨]

**ប្រធានអង្គជំនុំ៖**

បាទ សួស្តីលោកស្រី ស សៀក។ ឥឡូវនេះយើងបន្តស្តាប់សក្ខីកម្ម អង្គជំនុំជម្រះស្តាប់ -- បន្តស្តាប់សក្ខីកម្មរបស់លោកស្រីជាបន្តទៅទៀត។ ហើយថ្ងៃមុនដោយថា លោកស្រីមានការរំជួលចិត្តខ្លាំង ហើយក្តុកក្តួលក្នុងអារម្មណ៍ដែលមិនអាចដំណើរការបាន។ ហើយថ្ងៃនេះ អង្គជំនុំជម្រះសហការជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីផ្តល់នូវបុគ្គលិកជំនួយដល់លោកស្រី ដើម្បី -- នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនេះ ដើម្បីជួយសម្របសម្រួលនូវកិច្ចដំណើរការនេះឲ្យបានល្អប្រសើរ។

លោកស្រី អញ្ជើញមកពីអង្គភាពណា? ឈ្មោះអីដែរ លោកស្រី?

**លោកស្រី លី និមល៖**

លោកប្រធាន នាងខ្ញុំឈ្មោះ លី និមល ធ្វើការនៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

[១៣:៥០:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ភាគីដឹងហើយថា អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានផ្តល់បុគ្គលិកមួយដើម្បីគាំទ្រដល់ដំណើរការនេះ ដោយបញ្ហាគាត់ -- សាក្សីរូបនេះមានបញ្ហាផ្នែកខាងក្តុកក្តួលអារម្មណ៍កន្លងមក។ យើងបារម្ភថា បង្ការក្រែងលោដំណើរការប្រព្រឹត្តទៅមានបញ្ហា។ ដូច្នេះ ដើម្បីបង្កើនល្បឿនកិច្ចដំណើរការនីតិវិធីនោះ គឺយើងទទួលយកលោកស្រី ដែលជាបុគ្គលិកមកពីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញអមសាក្សីរូបនេះនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម។

ហើយតាមកាលវិភាគដែលបានកំណត់នោះគឺ ដល់ពេលចុងក្រោយនៃតំណាងសហព្រះរាជអាជ្ញា។ មិនដឹងថាតើតំណាងសហព្រះរាជអាជ្ញា ត្រូវការចំណាយពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរសាក្សីនេះទេ? ប្រសិនបើមានសូមអញ្ជើញ! ហើយសូមជម្រាបផង ថាត្រូវការចំណាយពេលវេលាប៉ុន្មានទៀត? ពីព្រោះមុនគឺ ប្រហែលជា១០នាទីប៉ុណ្ណោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការប្រហែល១៥នាទី គឺជាការប៉ាន់ស្មានរបស់ខ្ញុំ ព្រោះថាជារួមទៅ គឺយើងបានធ្វើការប៉ាន់ស្មានទៅលើពេលវេលា ហើយយើងបានពិភាក្សាជាមួយមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណី។ កាលពីសប្តាហ៍មុនយើងបានស្នើសុំដល់អ្នកច្បាប់ជាន់ខ្ពស់ ដែលកាត់បន្ថយពេលវេលាយើងពី១ថ្ងៃកន្លះ ទៅ១ថ្ងៃមួយភាគបួន ដើម្បីអនុញ្ញាតឲ្យមានពេលវេលាបន្ថែម ដើម្បីកោះ

ហៅសាក្សីបន្ទាប់។ នេះគឺជាអ្វីដែលយើងយល់ថា គឺសាក្សីបន្ទាប់គឺ TCW-338។ តាមការគណនារបស់យើង គឺយើងបានធ្វើចំណាយពេលប្រហែលជា៣ម៉ោង១៥នាទី ដូច្នេះយើងបានបញ្ចប់ប្រហែលជា២ម៉ោង៤៥នាទី។ ដូច្នេះហើយ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំត្រូវការពេលវេលាប្រហែលជា១៥នាទី ហើយនៅសល់២ម៉ោងកន្លះទៀត ខ្ញុំប្រគល់ -- នៅសល់ពេល២ម៉ោងជាងទៀត ខ្ញុំប្រគល់ទៅខាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៣:៥៣:០៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី អ្វីដែលខ្ញុំចង់ធ្វើការពិភាក្សា គឺខ្ញុំចង់លើកយកសក្ខីកម្មរបស់លោកស្រី ដែលបានធ្វើកាលពីសប្តាហ៍មុន ហើយខ្ញុំសូមលើកយកបញ្ហាជាក់លាក់មួយចំនួន។ ទី១ ខ្ញុំបានសួរលោកស្រី អំពីការណែនាំដែលបានធ្វើឡើង នៅថ្ងៃ១៧ មេសា ឆ្នាំ៧៥ ដើម្បីពន្យារការចូលទីក្រុងមករយៈពេល៣ថ្ងៃ ដើម្បីអនុញ្ញាតឲ្យមានការជម្លៀសប្រជាជន ដើម្បីឲ្យប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយវាមានចំណុចមួយពាក់ព័ន្ធទៅនឹងបញ្ហានេះ ដែលខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់បំភ្លឺ។ យើងមានប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់លោកស្រីជាមួយអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ D200/6.8 ហើយវាមាននូវការប្លែកគ្នាបន្តិចបន្តួចជាមួយនឹងអ្វីដែលផ្តល់។ ដូច្នេះ សង្ឃឹមថា យើងនឹងអាចរកឲ្យឃើញនូវភាពខុសគ្នានេះ។ លោកស្រីបានជម្រាបមកយើងថា ការណែនាំហ្នឹង គឺមកពី ហ៊ូ នឹម ហើយនិងប្រធានផ្នែករបស់លោកស្រីគឺ សៅ ដែលគាត់ជាអ្នកបញ្ជា គាត់គឺជាអ្នកចេញនូវសេចក្តីណែនាំនេះ។ តើលោកស្រីចាំដែរឬទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន។ នាងខ្ញុំមិនដឹងថា ណែនាំចំណុចអីផង។ សូមលោកឲ្យសំណួរនេះម្តងទៀត។

[១៣:៥៥:១១]

**ស៖** គឺខ្ញុំចង់និយាយអំពីការណែនាំ ការពន្យារពេលចូលមកទីក្រុងភ្នំពេញ គឺការពន្យារពេល៣ថ្ងៃចូលមកទីក្រុងភ្នំពេញ ព្រោះថាគេទុកពេល៣ថ្ងៃហ្នឹង ដើម្បីឲ្យប្រជាជនត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញសិន។

**ឆ៖** ចាស ពេលនុ៎ងប្រធាននាង ខ្ញុំបានជម្រាបមកក្រុមពួកនាងខ្ញុំអ៊ីចឹងមែន ឲ្យសម្រាកនៅភ្នំអង្គរស្នហ្នឹងទម្រាំនឹងគេនឹងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទើបឲ្យចូលមក។

**ស៖** តើលោកស្រីចាំដែរឬទេ កាលពីសប្តាហ៍មុន លោកស្រីបាននិយាយថា គឺថាលោក ហ៊ូ នឹម បាន--

**អ្នកបកប្រែ៖**

សូមអភ័យទោស លោកប្រធាន អ្នកបកប្រែស្តាប់មិនទាន់ទៅអ្វីដែលគាត់និយាយ។

[១៣:៥៦:១៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត ព្រោះអ្នកបកប្រែបកប្រែសំណួរចុងក្រោយរបស់លោកអម្បាញ់មិញនេះអត់ទាន់ទេ។

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចោទសួរសំណួរសាជាថ្មី។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** លោកស្រី តើលោកស្រីចាំដែរឬទេ កាលពីសប្តាហ៍មុនលោកស្រីបានជម្រាបយើងថា តាមដែលលោកស្រីចាំនោះ គឺ ហ៊ូ នឹម ហើយនិង ទីវ អុល បានចេញនូវសេចក្តីណែនាំនោះ។ ហើយគឺមិនមែន ខៀវ សំផន ជាអ្នកចេញទេ។ តើលោកស្រីចាំថាលោកស្រីបានជម្រាបមកតុលាការថាបែបនេះដែរឬទេ?

[១៣:៥៧:០១]

**លោកស្រីស សៀក៖**

**ឆ៖** ចាស លោកខ្ញុំសូមឆ្លើយសំណួរហ្នឹង។ ការពិតខ្ញុំដឹងតពីប្រធានរបស់ផងខ្ញុំ ហើយមិនមែនជាលោក ខៀវ សំផន ជាគាត់អ្នកបានប្រាប់មកក្រុមនាងខ្ញុំទេ គឺមានតែប្រធានរបស់ផងខ្ញុំហ្នឹងហើយ។

**ស៖** ខ្ញុំយល់ថាសំណួររបស់ខ្ញុំ គឺចង់សួរឲ្យលោកស្រីរំឭកការចងចាំ ថាតើការចេញសេចក្តីណែនាំហ្នឹង គឺមកពីអ្នកណា? ឥឡូវនេះ ខ្ញុំសូមអាននូវកិច្ចសម្ភាសរបស់លោកស្រីជាមួយនឹងតំណាងព្រះរាជអាជ្ញា។ គឺឯកសារ D200/6.8។ ភាសាអង់គ្លេសគឺមាន 008834 (ស៊ីក), ខ្មែរគឺ 00833490 និងភាសាបារាំង គឺមានលេខ 00835914។ ហើយខ្ញុំសូមអាននូវចំណុចមួយនេះ "សំណួរ៖ តើអ្នកមឹង

ឮពីការជម្លៀសហ្នឹងពីប្រធានរបស់មីងតែម្តង ឬក៏ប្រធានអ្នកមីងហ្នឹងចេញបទបញ្ជាថាឲ្យមានការជម្លៀសប្រជាជនហ្នឹង? ចម្លើយ៖ មិនទេ។ អានេះអាចខាងគេទាក់ទងមកខាងតាៗហ្នឹង។ ហើយអ៊ីចឹងទៅឲ្យគាត់ណែនាំមកប្រធានពួកខ្ញុំហ្នឹង ថាមិនទាន់បានចូលអ៊ីចឹង ពីព្រោះប្រជាជនវាជម្លៀសខុសទិស។ សំណួរ៖ អ្នកណាគេតាៗដែលមីងនិយាយហ្នឹង? ចម្លើយ៖ អ៊ំៗបីនាក់ហ្នឹង។ សំណួរ៖ ខៀវ សំផន, សុនសេន, ហ៊ូ នឹម បីនាក់ហ្នឹង? ចម្លើយ៖ ចាស"។ លោកស្រី ស សៀក ខ្ញុំដឹងថាលោកស្រីបានជម្រាបថាលោកស្រីបានជួប សុន សេន នៅភ្នំពេញ នៅពេលដែលលោកស្រីចូលមកភ្នំពេញ ថាតើអ្វីដែលខ្ញុំអានហ្នឹង វាជួយរំឭកដល់ការចងចាំរបស់លោកស្រីដែលដឹង ថាតើការបង្គាប់បញ្ជាហ្នឹង ការណែនាំហ្នឹងចេញមកពីខាងណា? ព្រោះថានៅក្នុងកិច្ចសម្ភាសជាមួយសហចៅក្រមស៊ើបអង្កេតហ្នឹង គឺគេបានរួមបញ្ចូលទាំង ខៀវ សំផន ផងដែរ តើលោកស្រីចាំយ៉ាងម៉េចដែរ?

[១៣:៥៩:២៦]

**ធ៖** ចាស លោកប្រធាន តាមនាងខ្ញុំចាំលោក ខៀវ សំផន ខ្ញុំមិនបានឮពីមាត់គាត់ផ្ទាល់ទេ ប៉ុន្តែមានប្រធានខ្ញុំ សៅ ហើយនិង លោក ហ៊ូ នឹម ហើយ ទីវ អុល។ ដូច្នេះ ខ្ញុំដឹងតាមរយៈអ៊ំៗបីនាក់ហ្នឹង។ អ៊ីចឹងក្នុងចម្លើយរបស់នាងខ្ញុំដែលខាងសង្កេតការណ៍គាត់បានទៅសម្ភាស ខ្ញុំឆ្លើយអ៊ីចឹង ព្រោះអីខ្ញុំច្រើនតែហៅអ៊ំ ដែលគាត់មានវ័យចាស់។

**ស៖** ដូច្នេះ ខ្ញុំសូមបន្តទៅចំណុចមួយទៀត។ យើងបានពិភាក្សាអំពីសុន្ទរកថាក្នុងខួបកាលពីសប្តាហ៍មុន ហើយលោកស្រីបាននិយាយថា គឺមានសុន្ទរកថាមួយ ហើយមានប្រតិចារឹកនៃសុន្ទរកថាហ្នឹងដែលខ្ញុំបាននិយាយយោង។ គឺសុន្ទរកថាដែលថ្លែងដោយលោក ខៀវ សំផន នៅថ្ងៃ -- នៅខែ៤ ឆ្នាំ៧៧។ អ្វីដែលខ្ញុំចង់សួរលោកស្រី គឺតាមការដឹងរបស់លោកស្រី ថាតើការផ្សព្វផ្សាយសុន្ទរកថាទាំងត្រូវបានគេធ្វើឡើងតាមវិទ្យុដែរឬក៏អត់? សូមលោកស្រីជម្រាប ថាតើលោកស្រីចាំដែរឬទេ ថាគេមានផ្សព្វផ្សាយនូវសុន្ទរកថារបស់ថ្នាក់ដឹកនាំបក្ស ឬក៏ថ្នាក់ដឹកនាំប្រទេសដែលបានធ្វើឡើងតាមវិទ្យុ? តើមានការផ្សព្វផ្សាយតាមវិទ្យុទេ?

[១៤:០១:១៣]

**ធ៖** ចាស នាងខ្ញុំអត់បានចាំផង។

**ស៖** សូមអរគុណ។ យើងនឹងត្រឡប់ទៅឯកសារ D200/6.8 គឺប្រតិចារឹកពាក្យដើមរបស់លោកស្រី ដែលលោកស្រីបានផ្តល់ឆ្លើយជូនទៅកាន់អ្នកស៊ើបអង្កេត។ ខ្មែរចាប់ផ្តើមពីលេខ 00833495

បារាំងគឺ 00835919, អង់គ្លេសគឺ 00834868។ ចាប់ផ្ដើមនៅត្រង់ចុងទំព័រខាងក្រោមនៃទំព័រនីមួយៗ។ ខ្ញុំនឹងអានផ្នែកដែលពាក់ព័ន្ធជូនលោកស្រី ស សៀក ហើយនៅពេលស្ដាប់ហើយ តើលោកស្រីចាំដែរឬទេ? នឹកឃើញដែរឬទេ?

"សំណួរ៖ ឬក៏ នួន ជា ឬក៏ ប៉ុល ពត ឬក៏ អៀង សារី អី គាត់ដែលមកក្រសួងឃោសនាការអីគាត់និយាយផ្ទាល់នៅនុ៎ង ក្នុងវិទ្យុហ្នឹងទេ? ផ្សាយពីសំឡេងគាត់ ឬក៏ការណែនាំគាត់ គោលការណ៍គាត់អីដែរ? អត់ទេ បើសិនជាគាត់ថា គាត់ចង់ថ្លែងការណ៍ ឬមួយក៏ផ្សាយដំណឹងអីនោះ គាត់ថតម៉ាញ៉េតូចទៅ"។

[១៤:០២:៥០]

ខាងក្រោមបន្តិចនោះ គឺសំណួរសួរថា "អ៊ីចឹងថតយកម៉ាញ៉េតូច ម៉ាញ៉េហ្នឹងមក? ឆ្លើយ៖ ចាស យកអាខ្សែអាត់ហ្នឹង។ សំណួរ៖ ខ្សែអាត់អីហ្នឹង? ចម្លើយ៖ ចាស យកខ្សែអាត់ហ្នឹងមក គេចម្លងទៀតទៅ ដាក់អេកូបន្តិចទៅ គេបំពង"។

អ៊ីចឹងតើលោកស្រីចាំទេ គេថាគេយកកាសែតហ្នឹង ពីមេដឹកនាំមក យកចាក់ផ្សាយតាមវិទ្យុ តើលោកស្រីចាំមានអ៊ីចឹងកើតឡើងដែរឬទេ?

**ឆ៖** ចាស លោកប្រធាន រឿងនេះជារឿងពិតហើយ ពីព្រោះអីថា បើសិនជាលោកមានថ្លែងការណ៍ពេលបុណ្យទានអ៊ីចឹងមិនដែលសូវឃើញលោកមកទេ។ តែគ្រាន់តែករណីខ្លះ ដែលនាងខ្ញុំមិនបានឃើញគាត់មក ឬមួយយ៉ាងម៉េច ខ្ញុំអត់ដឹងទេ ប៉ុន្តែភាគច្រើនសំឡេងរបស់គាត់ ច្រើនតែថតពីកន្លែងមកអ៊ីចឹង។

[១៤:០៣:៥៤]

**ស៖** តើលោកស្រីចាំដែរឬទេ តើសំឡេងដែលថតនោះ សំឡេងនៅក្នុងហ្នឹងគឺសំឡេងនរណាគេដែរ?

**ឆ៖** នាងខ្ញុំមិនបានចាំទេ។

**ស៖** តើលោកស្រីចាំទេ ថានៅពេលនោះលោកស្រីបានស្ដាប់កាសែតសំឡេងហ្នឹងដោយផ្ទាល់ត្រចៀកតែម្ដង? អ៊ីចឹងទេ?

**ឆ៖** អត់ទេលោកប្រធាន ប៉ុន្តែជួនកាលថាបើមានកិច្ចការដែលគាត់ត្រូវថ្លែងការណ៍ ថ្លែងអី ឬមួយក៏ពេលបុណ្យទានអ៊ីចឹង អាហ្នឹងខ្ញុំស្ដាប់តាមវិទ្យុ។

**ស៖** ដូច្នេះឮការថ្លែង ផ្សាយដោយមេដឹកនាំហ្នឹង គឺធ្លាប់បានឮអ៊ីចឹងមែន ឮខ្លះដែរ គឺដូចជាការឮ ការផ្សាយអំពីការគម្រប់ខួបថ្ងៃទីដប់-- ជ័យជម្នះថ្ងៃ១៧ មេសា អ៊ីចឹង។ តើអ៊ីចឹងទេ?

**ឆ៖** នាងខ្ញុំមិនសូវបានចាំទាំងអស់ទេត្រង់ហ្នឹង។ តែគ្រាន់តែករណីខ្លះអាចបានឮ តែមិនសូវចាប់អារម្មណ៍ចងចាំទុកក្នុងខ្លួន។

**ស៖** សូមអរគុណ។ ចូលទៅដល់ប្រធានបទមួយទៀត ដោយខ្លីៗ។ ខ្ញុំចង់សួរខ្លីៗតែប៉ុណ្ណោះ។ យើងក៏បានពិភាក្សាគ្នាកាលពីសប្តាហ៍មុន និយាយជជែកគ្នាកាលពីសប្តាហ៍មុន អំពីការប្រជុំមួយដែលលោកស្រីបានជួបជាមួយនឹង ហ៊ូ នឹម តែខ្លីទេ ការប្រជុំហ្នឹង។ បន្ទាប់មកការប្រជុំនោះគឺមួយភ្លែតទេ គេហៅ ហ៊ូ នឹម ចេញទៅ។ តើលោកស្រីចាំទេ នៅពេលប្រជុំនោះ គឺក្នុងឱកាសអ្វីដែរ? មានកម្មវិធី ឬការផ្សព្វផ្សាយអ្វីទេនៅក្នុងប្រជុំ ពេលដែលលោកស្រីជួបប្រជុំជាមួយ ហ៊ូ នឹម នោះ?

[១៤:០៦:១៥]

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ការប្រជុំជាការដកពិសោធ នៅផ្នែកនីមួយៗ ដូចថាសិល្បៈ ចតចម្រៀង ហើយរវាងអ្នកអាន ខុសត្រូវ ឬមួយក៏យឺត រឝ្វើលយ៉ាងម៉េច ពិសោធតែអ៊ីចឹងទេលោក។

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធាន ដោយសារពេលវេលាខ្លី ខ្ញុំសូមអនុញ្ញាតអានជូនសាក្សីនូវអត្ថបទដកស្រង់ខ្លីមួយចេញពីឯកសារដែលយើងបានយោងពីមុន គឺជាលិខិតដែលសរសេរឡើងដោយ ហ៊ូ នឹម។ សរសេរនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ដែលក្នុងនោះថ្លែង ប៉ុល ពត, បងនួន, បងវ៉ាន់, ខៀវ-- បងខៀវ, និងហែម។ ឯកសារនៅក្នុងដីកាដំណោះ -- បញ្ជូនរឿងទៅស៊ើបសួរលេខ 5.13។ ដូច្នេះហើយសូមការអនុញ្ញាតពីលោកប្រធានអានលិខិតនេះ ដើម្បីសួរទៅសាក្សី ថាតើសាក្សីគាត់នឹកឃើញដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[១៤:០៧:៣៦]

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** លោកស្រី ស សៀក ខ្ញុំនឹងអានជូរមួយបន្ទាត់ ពីរបន្ទាត់ដំបូង។ ខ្ញុំសូមអធ្យាស្រ័យ មុនដំបូង ខ្ញុំផ្តល់ ERN លេខ ERN សិន។ ខ្មែរគឺ 00008923, បារាំង ERN គឺ 00766902, អង់គ្លេសគឺ

00249844។ ហើយខ្ញុំសូមបញ្ជាក់ឯកសារ លើកឡើងឯកសារនេះ គេនិយាយថា៖ “ថ្ងៃនេះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ដែលខ្ញុំកំពុងតែមមាញឹករៀបចំកម្មវិធីផ្សាយវិទ្យុទទួលអំណរបុណ្យខួបទី២ នៃមហាជ័យជម្នះ១៧ មេសា ឆ្នាំ៧៥។ តាមទូរស័ព្ទ សមមិត្ត ប៉ង់ បានហៅខ្ញុំមកធ្វើការជាមួយអង្គការ។ ពេលមិត្តយុទ្ធជនចាប់ខ្ញុំ ខ្ញុំភ្ញាក់ក្រញ៉ាង មិនស្មានយ៉ាងនេះសោះ”។

លោកស្រី ស សៀក នៅពេលដែលលោកស្រីស្តាប់ឮ និងឃើញចំណុចនេះ តើលោកស្រីនឹកឃើញទេថាមានហេតុការណ៍មួយអ៊ីចឹងកើតឡើងនៅថ្ងៃទី១០ មេសា ឆ្នាំ៧៧ ដែលពេលនោះលោក ហ៊ូ នឹម កំពុងតែរៀបចំកម្មវិធីផ្សាយវិទ្យុទទួលអំណរបុណ្យខួបទី២ នៃមហាជ័យជម្នះ១៧ ខែមេសា ឆ្នាំ៧៥។ តើលោកស្រីនឹកឃើញដែរឬទេ? ដែលថានៅពេលនោះ គឺលោកស្រីបានជួបប្រជុំជាមួយនឹង ហ៊ូ នឹម ហើយបន្ទាប់មក គេហៅ ហ៊ូ នឹម ចេញទៅបាត់។

[១៤:០៩:១៤]

**ឆ៖** ចាស នាងខ្ញុំអត់ចាំទេ។

**ស៖** តើគេនិយាយ ក្នុងនេះមានឈ្មោះថា ប៉ង់ នេះ ដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ។ ប៉ង់ ហ្នឹង គឺនរណាដែរ? គេសំដៅទៅលើបុគ្គលណាដែរ?

**ឆ៖** ខ្ញុំមិនសូវស្គាល់ទេ លោកប្រធាន។

**ស៖** ដោយសារតែពេលវេលាខ្លី ខ្ញុំសូមបញ្ជាក់ថា សាក្សីបានលើកឡើងបុគ្គលរូបនេះនៅក្នុងឯកសារ D200/6.8។ ខ្មែរគឺ 00833492, បារាំង 00835916, ហើយអង់គ្លេស 00834865។ លោកស្រី ស សៀក លោកស្រីជម្រាបយើងពីសប្តាហ៍មុនថា លោកស្រីបានស្គាល់លោក ខៀវ សំផន និងប្រពន្ធរបស់គាត់ក្រោយឆ្នាំ៧៩ តើលោកស្រីធ្លាប់ជជែកជាមួយនឹងពួកគាត់នោះ អំពីការបាត់ខ្លួនរបស់ ហ៊ូ នឹម ដែលឬទេ ក្រោយពីស្គាល់ពួកគាត់នោះ?

**ឆ៖** ចាស លោកប្រធាន ខ្ញុំស្គាល់លោក ខៀវ សំផន តាំងពីសង្គ្រាម៥ឆ្នាំ ប៉ុន្តែបើប្រពន្ធទើបតែក្រោយហើយទេ តែខ្ញុំមិនដែលបានសាកសួរសុខទុក្ខ ឬក៏និយាយអីជាមួយលោកទេ។

**ស៖** មានសំណួរមួយចំនួនតូចទៀតដែលខ្ញុំចង់សួរ។ លោកស្រីមិនដែលជជែកផ្ទាល់ជាមួយពួកគាត់ទាំងពីរនោះទេ ចុះហេតុអ្វី មានកាលៈទេសៈអ្វីដែលធ្វើឲ្យលោកស្គាល់ ជួបប្រពន្ធលោក ខៀវ សំផន នោះ?

[១៤:១១:៤៤]

**ឆ៖** ចាស ពីមុនមកឆ្នាំ៧៩ មក៨២ នាងខ្ញុំបានជួបគាត់នៅឯ៨០៨ ជួរភ្នំដងរែក ហ្នឹងជួបគ្រួសារគាត់។

**ស៖** តើលោកស្រីធ្លាប់ធ្វើការជាមួយនឹងគ្រួសារគាត់ ឬជាមួយនឹងលោក ខៀវ សំផន?

**ឆ៖** ចាស នាងខ្ញុំអត់មានបានធ្វើការជាមួយគ្រួសារគាត់ ឬមួយក៏ជាមួយលោក ខៀវ សំផនទេ តែយើងខ្ញុំនៅជាអង្គភាពតាមកងដឹកជញ្ជូន ឆ្នាំ៨២។

**ស៖** លោកស្រីបានជម្រាបថា គ្រួសាររបស់លោក ខៀវ សំផន នោះបានមកជួបលោកស្រី។ តើហេតុអ្វីបានជាគ្រួសារលោក ខៀវ សំផន ស្គាល់កន្លែងលោកស្រីរស់នៅ?

**ឆ៖** ចាស ខ្ញុំភ្លេចឆ្នាំហើយ។ កាលពីមុននឹងគ្រួសារខ្ញុំស្លាប់ ហ្នឹងគាត់ទៅរកគ្រួសារខ្ញុំ។ គាត់ចង់សួរថា លោក ខៀវ សំផន ដែលទៅឃោសនាការអត់? គាត់ចង់សួរតែប៉ុណ្ណឹង ប៉ុន្តែទៅគាត់អត់បានជួបគ្រួសារខ្ញុំទេ ទៅនៅឯភូមិអូរស្វួត នៅឃុំតាសាញ់ ស្រុកសំឡូត។ ប៉ុនពីមុនមក អត់ដែលស្គាល់ទេខ្ញុំ។ គ្រាន់តែស្គាល់ ឃើញគាត់ ប៉ុន្តែមិនដែលទាក់ទាក់អី។

[១៤:១៣:៣១]

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ។ តើគ្រួសាររបស់លោក ខៀវ សំផន នោះ ដឹងថាលោកស្រី និងប្តីលោកស្រីនោះ រស់នៅកន្លែងណា? ដោយរបៀបណាដែរ?

**ឆ៖** ចាស ខ្ញុំមិនដឹងដែរ មិនដឹងថាគាត់ស្គាល់ខ្ញុំនៅកន្លែងសិល្បៈពីមុនមក ឬមួយក៏កន្លែងណាខ្ញុំអត់ដឹងដែរ។ តែគាត់ស្គាល់គ្រួសារខ្ញុំ មិនអត់ទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកស្រី ស សៀក។ សូមអរគុណអង្គជំនុំជម្រះ ចំពោះពេលវេលាដែលបានផ្តល់ជូនយើងខ្ញុំ។ ខ្ញុំពុំមានសំណួរបន្ថែមចង់សួរលោកស្រីទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះ សូមប្រគល់វេទិកាក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនការទាំងមូល។ លោកស្រី -- ពាក់ព័ន្ធទៅនឹងការសួរសំណួរទៅលោកស្រី ស សៀក នេះ សហភាតារបស់ខ្ញុំ –បេនី យេ– នឹងសួរ

សំណួរដំបូង ហើយបន្ទាប់មកខ្ញុំនឹងបន្តសំណួរពេញចុងក្រោយ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! សូមអញ្ជើញ!

[១៤:១៥:១៨]

**លោកស្រី បេនី យេ៖**

សួស្តីលោកប្រធាន។ លោក លោកស្រីចៅក្រម អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ។ ខ្ញុំឈ្មោះ បេនី យេ។ ខ្ញុំគឺជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិមួយរូប ក្នុងចំណោមមេធាវីទាំងឡាយនោះ។ ហើយខ្ញុំចង់សួរសំណួរមួយចំនួនទៅកាន់លោកស្រី ស សៀក។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** លោកស្រី ស សៀក ដំបូង ខ្ញុំសូមសួរអំពីពេលវេលាដែលលោកស្រីធ្វើការនៅក្រសួងឃោសនាការ នៅដើមឆ្នាំ៧៥ និង៧៨។ នៅពេលនោះ លោកស្រីថា លោកស្រីជាអ្នកចម្រៀងនៅអង្គភាពហ្នឹង។ តើអ៊ីចឹងដែរឬទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ពិតមែនលោកស្រី។ ពីឆ្នាំ៧៥ ក្រោយរំដោះមក ទល់នឹងឆ្នាំ៧៧ បាននាងខ្ញុំចេញចេញទៅនៅមន្ទីររោងពុម្ព។

**ស៖** នៅពេលដែលលោកស្រីធ្វើអ្នកចម្រៀងនោះ តើត្រូវទន្ទេញប៉ារ៉ូលចម្រៀង នៅពេលច្រៀងតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស លោកស្រី បើសិនថាមានពេលវេលាដែលត្រូវសម្តែងសិល្បៈជូនកងទ័ព ឬមួយក៏ជូនប្រជាជន មានការហាត់ជាកាយវិការ ឬមួយក៏ចម្រៀងហ្នឹង ទន្ទេញទាល់តែចាំ តែបើថត មើលក្រដាសតែម្តង។ ថតចម្រៀងមើលក្រដាស។

**ស៖** តើលោកស្រីចាំទេ តើអត្ថន័យនៃខ្លឹមសារចម្រៀងនោះគេមានអត្ថន័យយ៉ាងម៉េចដែរ ចាំទេ?

[១៤:១៧:០៩]

**ឆ៖** ចាស នាងខ្ញុំនៅចាំចម្រៀងដែលថ្ងៃដែលរំដោះទីក្រុងភ្នំពេញ ថ្ងៃ១៧ មេសា ចាំខ្លះ។ ប៉ុន្តែចំណងជើង ដឹងថា ១៧ មេសា មិនចាំអស់ទេ យូរឆ្នាំពេកហើយលោកស្រី។ ភ្លេចអស់ហើយ យូរពេក។

**ស៖** តើលោកស្រីចាំចម្រៀងផ្សេងទេ ក្រៅពីចម្រៀងថ្ងៃជ័យជម្នះរំដោះទីក្រុងភ្នំពេញ មានចាំចម្រៀងផ្សេងទៀត? ឬក៏ចាំសិល្បៈ អត្ថបទសិល្បៈអីផ្សេង ក្រៅពីហ្នឹងដែរឬទេ?

**ឆ៖** ចាស ចាំរឿងចំណងជើងរឿង ដូចថាត្រុដិរឿងអី ចំណងជើងវា "អ្វីៗលះដើម្បីបដិវត្តន៍"។ ហ្នឹង ចំណងជើងរឿង ត្រុដិ ត្រុដិរឿង ចាស។ ហើយជាល្ខោនបាសាក់ ជាយីកេអី នាងខ្ញុំមិនបានចង់ចាំទេ ដូចថាវាយូរឆ្នាំពេក លះបង់ចោលខ្មេចខ្ចី លែងគិត លែងរវល់អីទាំងអស់ លោកស្រី។ មិនចាំទេ ចំណងជើង។

[១៤:១៨:៣៤]

**ស៖** តើលោកស្រីអាចជម្រាបបានដែរឬទេ នរណាគេជាអ្នកសរសេរខ្លឹមសារចម្រៀងជ័យជម្នះរំដោះទីក្រុងភ្នំពេញនោះ? ឬក៏សរសេរខ្លឹមសារល្ខោន យីកេ ឬក៏អត្ថបទរឿងនោះ?

**ឆ៖** ចាស លោកស្រី នៅក្នុងក្រុមនាងខ្ញុំ មានផ្នែករបស់វា។ ដូចថា ផ្នែកនិពន្ធចម្រៀងអីចឹង មានអ្នកពិការភ្នែក មើលអីមិនឃើញ តែគាត់និពន្ធ។ និពន្ធដោយការនិយាយចូលក្នុងខ្សែអាត់ហើយ ហើយឲ្យយើងភ្នែកភ្លឺហ្នឹង ចម្លង និយាយម៉ាត់ៗអីចឹង ចម្លងបានមួយឃ្លា ពីរឃ្លាអីចឹង ចាស។ ហើយយកមកកែលម្អទៅ បើថាសមស្របនឹងសភាពការណ៍ហើយ យកចម្រៀងហ្នឹងទៅប្រើការ ថតតែម្តង។ មិនមែនមានតែអ្នកពិការទេ អ្នកអត់ពិការក៏គេអាចជួយសរសេរបានដែរ ក្នុងហ្នឹងមានផ្នែកនិពន្ធចម្រៀង និពន្ធបទភ្លេង ហើយនិងសរសេររឿងអីខ្លះអីចឹងទៅ។ តែគ្នាឯងជុំវិញក្នុងក្រុមហ្នឹង ប៉ុន្តែដោយសារចែករំលែកផ្នែកម្ចាស់ការមួយៗ រៀងៗខ្លួន។ ចាស សូមអស់យោបល់។

**ស៖** ផ្នែកនិពន្ធនោះ គឺក្រោមក្រសួងឃោសនាការដែរ ឬក៏នៅក្រោមក្រសួងផ្សេង?

[១៤:២០:០២]

**ឆ៖** ចាស អ្នកស្រី ក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនាការ។

**ស៖** សូមអរគុណ។ លោកស្រីបានបញ្ជាក់ថា ត្រូវថតចម្រៀងនោះនៅក្នុងកាសែត។ តើគេយកទៅចាក់ផ្សាយតាមវិទ្យុដែរឬទេ?

**ឆ៖** ចាស ចាក់ផ្សាយលោកស្រី។

**ស៖** លោកស្រីដឹងទេ ហេតុអ្វីបានជាគេចាក់ផ្សាយចម្រៀងដូច្នេះតាមវិទ្យុ គេមានគោលបំណងអ្វីដែរ?

**ឆ៖** ចាស ខ្ញុំមិនសូវយល់ដែលត្រង់ហ្នឹង។ ចង់និយាយថា ស្រុកឯករាជ្យហើយត្រូវការជំរុញ

និងកសាងលើកទឹកចិត្តប្រជាជនអីអ៊ីចឹង។ យល់បានត្រឹមហ្នឹងលោកស្រី។

[១៤:២១:១០]

**ស៖** តើក្រសួងឃោសនាការ គឺជាក្រសួងតែមួយគត់ដែលមានភារកិច្ចថតទុកនៅចម្រៀងទាំងអស់នោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងម៉េច?

**ផ៖** ចាស ពិតមែនលោកស្រី គឺមានតែក្រសួងហ្នឹងមួយដែលអាចថត ហើយនិងបម្រើការងារនៅក្នុងវិទ្យុ ថាវិទ្យុជាតិចុះ ដូចនុ៎ង។

**ស៖** តើលោកស្រីដឹងទេ គេមានផ្សាយចម្រៀងផ្សេងទៀតដែរឬទេ ដែលមិនថតដោយក្រសួងឃោសនាការ តែថតដោយក្រសួង ឬក៏ស្ថាប័នផ្សេងនោះ គេមានចាក់ផ្សាយចម្រៀងហ្នឹងដែរ ចម្រៀងទាំងអស់នោះដែរឬទេ?

**ផ៖** អត់មានទេ លោកស្រី។

**ស៖** តើលោកស្រីដឹងទេ ហេតុផលអ្វីដែរ ដែលគេមិនចាក់ចម្រៀងផ្សេងនោះ?

**ផ៖** ចាស តាមនាងខ្ញុំយល់ដូចថា វាខុសពីសភាពការណ៍ ហើយក៏វាខុសពីរបប។

[១៤:២២:៣២]

**ស៖** តើលោកស្រីអាចពន្យល់បន្ថែមទេ មិនត្រូវ មិនស្របនឹងសហភាពការណ៍នោះ ចង់បានន័យយ៉ាងម៉េចដែរនៅពេលនុ៎ង?

**ផ៖** ចាស លោកស្រីព្រោះថា សភាពការណ៍ដោយស្រុកយើងឯករាជ្យហើយ ហើយមិនមែនជាសភាពនៅពីសង្គមចាស់ទៀត។

**ស៖** ដូច្នេះ ចម្រៀងនៅក្នុងរបបមុននោះត្រូវបានគេចាត់ទុកថា មិនសមទៅនឹងសភាពការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើអ៊ីចឹងមែនដែរឬទេ?

**ផ៖** ចាស លោកស្រីក្នុងន័យហ្នឹង នាងខ្ញុំមិនបានយល់ទេ គ្រាន់តែថាជាក់ស្ដែងគេអត់យកមកប្រើ។

[១៤:២៣:២៦]

**ស៖** លោកស្រីដឹងទេ ថាតើមានអ្វីកើតឡើងដែរ ចំពោះចម្រៀងចាស់ៗនោះ?

**ផ៖** ចាស នាងខ្ញុំមិនបានយល់ មិនបានដឹងទេលោកស្រី។

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមចូលទៅដល់ប្រធានបទផ្សេងមួយទៀត លោកស្រីបានលើក

ឡើងថា ក្រោយបាត់ខ្លួន ហ៊ូ នឹម ចេញពីក្រសួង។ ការងារក្រសួងនោះក៏គេដកចេញផងដែរ ដូច្នេះខ្ញុំសួរលោកស្រី ឲ្យជម្រាបខ្ញុំថា តើលោកស្រីស្គាល់បុគ្គលខ្លះៗដែរឬទេ ដែលខ្ញុំនឹងហៅឈ្មោះ ជូនលោកស្រីឲ្យស្តាប់ ខ្ញុំចាប់ផ្តើមដោយឈ្មោះ ឆយ។ តើលោកស្រីស្គាល់បុគ្គលមួយរូបឈ្មោះ ឆយ ដែរឬទេ?

**ឆ៖** ចាស ខ្ញុំស្គាល់។ ឆយ ហ្នឹងមកទទួលខុសត្រូវក្រោយពីលោក ហ៊ូ នឹម ផ្លាស់ចេញពីក្រសួងនាងខ្ញុំ។

**ស៖** តើលោកស្រីស្គាល់ឈ្មោះពេញរបស់គាត់ដែរឬទេ?

**ឆ៖** ចាស គ្រកូលគាត់ នាងខ្ញុំមិនបានស្គាល់ទេ គេហៅតែ អ៊ំឆយៗ នាងខ្ញុំស្គាល់ត្រឹមហ្នឹង។

[១៤:២៥:០០]

**ស៖** តើលោកស្រីប្រាប់ដែរឬទេ គាត់មានភារៈ តួនាទីអ្វីដែរនៅក្រសួងឃោសនាការនោះ នៅពេលដែលគាត់ទៅទទួលបន្ទុកនោះ?

**ឆ៖** ចាស បន្ទាប់ពីគាត់មកជំនួសមុខលោក ហ៊ូ នឹម គាត់ទទួលរួមនៅហ្នឹង ទាំងគ្រប់ផ្នែក។

**ស៖** តើ ឆយ នៅមានពេលណាមួយនោះ គឺគាត់ចាកចេញឈប់ធ្វើការនៅក្រសួងឃោសនាការនេះដែរឬទេ?

**ឆ៖** ចាស ពិតមែនលោកស្រី។ ខ្ញុំលែងឃើញ ហើយក្រោយមកក៏ខ្ញុំចេញពីហ្នឹងដែរ លែងដឹងអីទាំងអស់ នៅកន្លែងឃោសនាការ នាងខ្ញុំលែងដឹងឮ។

[១៤:២៦:០៣]

**ស៖** ក៏ប៉ុន្តែគាត់ហ្នឹងចេញទៅមុនលោកស្រីចេញពីក្រសួងហ្នឹង តើអ៊ីចឹងដែរឬទេ ត្រឹមត្រូវទេ?

**ឆ៖** ចាស ខ្ញុំចេញមុន។ ខ្ញុំចេញមកមន្ទីរពេទ្យពុម្ពមុនគាត់ ចាស។

**លោកស្រី បេនី យេះ**

លោកប្រធាន សូមការអនុញ្ញាតអានចេញពីចម្លើយរបស់សហចៅក្រមស៊ើបអង្កេត។ ឯកសារ E3/379 អង់គ្លេសគឺ 00323334, ខ្មែរគឺ 00294810, បារាំងគឺ 00385207។ សូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមអាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** នៅក្នុងចម្លើយរបស់ចៅក្រមស៊ើបអង្កេតនោះ លោកស្រីបានឆ្លើយថា "ឆយ ត្រូវបានគេចាប់ខ្លួនប្រហែលជាក្នុងឆ្នាំ៧៧។ ឆយ នេះមកពីក្រសួងអប់រំ"។ តើលោកស្រីនៅតែរក្សាសម្ដីដែលបានឆ្លើយអ៊ីចឹងដដែល ឬក៏យ៉ាងម៉េច?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នៅក្នុងចំណុចនេះអាចនាងខ្ញុំភ័ន្តភាំងបន្តិច។ មែនទែន ខ្ញុំ -- លោក ឆយ ហ្នឹងហើយដែលបញ្ជូននាងខ្ញុំទៅមន្ទីរពេទ្យពុម្ព។ តែក្រោយមកនាងខ្ញុំដឹងថា ពូឆយ ហ្នឹងគាត់ត្រូវបាត់ខ្លួនចេញពីឃោសនាការហ្នឹង។ នាងខ្ញុំគ្រាន់តែបានដឹងថា គាត់មិនអាចនៅទទួលខុសត្រូវនៅកន្លែងឃោសនាការទៀតទេ។ តែ ពូឆយ ហ្នឹងដែលឲ្យនាងខ្ញុំនៅមន្ទីរពេទ្យពុម្ព។ ខ្ញុំជួបគាត់រយៈពេលខ្លីដែរ។

[១៤:២៨:១៣]

**ស៖** តើលោកស្រី ក្រោយពីចេញក្រសួងឃោសនាការទៅក្រសួងពេទ្យពុម្ពនោះ ទៅផ្នែកពេទ្យពុម្ពនោះ លោកស្រីដឹងថាគាត់បាត់ខ្លួនដោយរបៀបណាដែរ?

**ឆ៖** ចាស នាងខ្ញុំមិនបានដឹងទេ មិនដឹងគេផ្លាស់ប្ដូរការងារគាត់ ឬមួយក៏យ៉ាងម៉េច? ប៉ុនដឹងថាគាត់ចេញពីហ្នឹងបាត់។

**លោកស្រី បេនី យេ៖**

ដើម្បីជាប្រតិចារឹកលោកប្រធាន ខ្ញុំសូមលើកឡើងថា ឯកសារ E3/342 ដែលជាបញ្ជីកែប្រែអ្នកទោសស-២១ ឈ្មោះ ឆយ ហៅ សៅ ឆាន់ នោះឃើញមាននៅលេខ ERN 00329972 គឺជាលេខ ERN ទាំងភាសាខ្មែរ និងភាសាអង់គ្លេស គឺលេខតែមួយទេ។

**សួរដោយ លោកស្រី បេនី យេ៖**

**ស៖** ខ្ញុំចូលទៅដល់ សួរឈ្មោះបុគ្គលម្នាក់ទៀត។ តើលោកស្រីស្គាល់បុគ្គលឈ្មោះ ហាន ដែរឬទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកស្រី! ហាន់ ឬមួយក៏ ហាន?

**ស៖** ខ្ញុំនិយាយអំពី ហាន។

**ឆ៖** ចាស លោកស្រី ខ្ញុំស្គាល់ ហាន។

**ស៖** តើអាចបញ្ជាក់ទេ គាត់មានតួនាទីអ្វីដែរ?

**ឆ៖** ចាស លោក ហាន គាត់ជាអ្នកនិពន្ធ ជួយនិពន្ធកែអត្ថបទខាងវិទ្យុតិចតួច ដែលថាជាដំណឹងអីលោកស្រី។

**ស៖** តើស្គាល់ឈ្មោះពេញរបស់គាត់ដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំអត់បានស្គាល់ទេ។

[១៤:៣០:៣១]

**ស៖** តើលោកស្រីអាចជម្រាបបានដែរទេ ថា ហាន់ មួយទៀតនុ៎ង គាត់មានតួនាទី ឬក៏ទទួលខុសត្រូវអ្វីដែរ?

**ឆ៖** ចាស មួយទៀតឈ្មោះ ហាន់។ ហាន់ គាត់ខាងភ្លេង ហើយគាត់ជួយនិពន្ធនូវបទចម្រៀងខ្លះៗហ្នឹង ឈ្មោះ ហាន់ ហើយមួយនេះឈ្មោះ ហាន ចាស។

**ស៖** ខ្ញុំចង់សួរលោកស្រីបន្ថែមអំពីអ្នកនៅខាងភ្លេងហ្នឹង គឺឈ្មោះ ហាន់ នោះ។ តើលោកស្រីអាចជម្រាបបានដែរឬទេថា លោក ហាន់ ហ្នឹងៗ គាត់បានបានចាកចេញពីក្រសួងឃោសនាការនៅពេលមួយ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ពិតមែន គាត់ចេញមុននាងខ្ញុំចេញពីមន្ទីរឃោសនាការទៅរោងពុម្ពទៀត។

**ស៖** តើគាត់ចាកចេញហ្នឹង ដោយសារតែគេបញ្ជូនគាត់ទៅអង្គភាព ឬក៏ទៅកន្លែងផ្សេង ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** ចាស នាងខ្ញុំមិនបានដឹងទេ ដឹងពីគាត់ទៅបំពេញការងារនៅកន្លែងណា អត់ដឹងទាល់ថ្ងៃណោះ។

**ស៖** តើលោកស្រីស្គាល់ពីប្រវត្តិរបស់គាត់ដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំបានស្គាល់តាមការសំណេះសំណាល និយាយប្រាប់ព្រោកតាមប្រវត្តិគាត់។ គាត់ជាបញ្ញាជនមកពីប្រទេសសូវៀត។ គាត់ទៅរៀនសូត្រនៅស្រុកគេ តែក្រោយមកក៏អាចគាត់មាតុភូមិនិវត្តន៍ចូលស្រុក តែមិនដឹងឆ្នាំណាទេ តែខ្ញុំជួបគាត់តាំងពីឆ្នាំ៧៣ នៅជាមួយគ្នារហូតទល់មកឃោសនាការ។

[១៤:៣៣:០២]

**ស៖** សម្រាប់កំណត់ត្រា ខ្ញុំសូមដកស្រង់ នូវឯកសារដដែល ដែលខ្ញុំបានបង្ហាញគឺ E3/342 គឺ

និយាយអំពីឈ្មោះ ហាន ហៅ ងន ឆេងលី ដែលមកពីក្រសួងឃោសនាការ ហើយមានលេខ ERN គឺ 00329863។ លោកសាក្សី ខ្ញុំចង់សួរលោកស្រីម្នាក់ទៀត អំពីមនុស្សម្នាក់ ឈ្មោះ ម៉ន តើលោកស្រីស្គាល់ទេ?

**ឆ៖** ចាស នាងខ្ញុំស្គាល់ឈ្មោះ ម៉ន។

**ស៖** តើលោកស្រីអាចជម្រាបបានដែរទេ ថា ម៉ន នោះធ្វើការងារអីដែរនៅក្រសួង?

**ឆ៖** ចាស គាត់ជាអ្នកជំនួយការដូច ហាន ដែរ ក្រុមគាត់នៅជាមួយគ្នា។ តែគ្រាន់ថា មិនដឹងថា ពីណាប្រធាន ឬមួយក៏អីទេចាស។

**ស៖** ដូច្នេះ ខ្ញុំចង់សួរលោកស្រី ថាតើនៅពេលណាមួយនោះ ម៉ន គាត់បានចេញពីក្រសួងដែរឬទេ?

**ឆ៖** ចាស ពិតមែនលោកស្រី គាត់ចេញពីក្រសួងខ្ញុំ។

[១៤:៣៤:៤២]

**ស៖** តើលោកស្រីដឹងដែរឬទេ ថាគាត់ទៅទីណាដែរ ក្រោយពេលចេញពីក្រសួង?

**ឆ៖** ខ្ញុំអត់បានដឹងទេលោកស្រី។

**ស៖** លោកប្រធាន ខ្ញុំចង់និយាយយោងទៅលើឯកសារ E3/342 ដែលដាក់បញ្ជីថា ម៉ន ហៅ ម៉ៅ គឹមស្រ៊ា ជាក្រុមអ្នកសម្តែងក-៣៣ ហើយវាមាននៅក្នុង ERN ភាសាអង់គ្លេស និងខ្មែរគឺលេខ 00329829។ លោកស្រី ស សៀក ឥឡូវនេះខ្ញុំសូមនិយាយពីបុគ្គលដែលលោកស្រីនិយាយជាញឹកញាប់ គឺ សៅ។ តើ សៅ គាត់មានតួនាទីទទួលខុសត្រូវអ្វីដែរ?

**ឆ៖** ចាស សៅ គាត់ទទួលខុសត្រូវផ្នែកសិល្បៈជារួម នៅក្នុងផ្នែក។

**ស៖** តើលោកស្រីស្គាល់ឈ្មោះពេញរបស់គាត់ដែរឬទេ?

**ឆ៖** អត់ទេលោកស្រី។

**ស៖** តើ សៅ គាត់ចាកចេញពីក្រសួង ឬក៏គាត់ត្រូវបានគេដកចេញពីក្រសួងនៅពេលណាមួយនោះទេ?

**ឆ៖** ចាស នាងខ្ញុំអត់បានចាំថាថ្ងៃណា ខែណាទេ ប៉ុន្តែគាត់ត្រូវផ្លាស់ចេញ អត់មានត្រូវនៅហ្នឹងទៀតទេ។

[១៤:៣៧:០៦]

**លោកស្រី បេនី យេ ៖**

លោកប្រធាន ខ្ញុំសូមដកស្រង់នូវឯកសារ E3/342 គឺជាបញ្ជីអ្នកទោសស-២១ ដែលចុះបញ្ជីសៅ ហៅ ឈិត តិចស៊ាង ដែលជាបុគ្គលិកក្រសួងឃោសនាការ គឺមានលេខ ERN គឺ 00329647។

**សួរដោយលោកស្រី បេនី យេ ៖**

**ស៖** សូមអរគុណលោកស្រីសាក្សី។ សំណួរ ឥឡូវខ្ញុំចង់សួរលោកស្រីទៅលើសំណួរមួយចំនួនទាក់ទងទៅនឹងអ្វីដែលកើតឡើងនៅក្នុងដើមឆ្នាំ៧៨។ ខ្ញុំដឹងថាសំណួរនេះវាពិបាកដល់លោកស្រី ប៉ុន្តែវាគឺជាសំណួរមួយដ៏សំខាន់ចំពោះអង្គជំនុំជម្រះក៏ដូចជាចំពោះសាក្សីនិងជនរងគ្រោះ។ ដូច្នេះកាលពីសប្តាហ៍មុនលោកស្រីបានបញ្ជាក់ថា គេដកលោកស្រីចេញពីក្រសួងឃោសនាការនៅឆ្នាំ៧៨ តើលោកស្រីចាំដែរឬទេថាគេដកលោកស្រីចេញនោះនៅខែណា?

**លោស្រី ស សៀក៖**

**ឆ៖** ចាស នាងខ្ញុំសូមមានមតិឆ្លើយនឹងសំណួរនេះ។ ការពិតនាងខ្ញុំសូមរាយរ៉ាប់បន្តិចចុះ ពីព្រោះអីមិនមែនទាក់ទិនអីចំពោះបុគ្គលនាងខ្ញុំទេ គឺទាក់ទិនដល់ក្រុមគ្រួសារតូចនាងខ្ញុំតែម្តង។

[១៤:៣៧:៤៥]

*(សម្រាករយៈពេលខ្លីដោយសារសាក្សីមានការរំជួលចិត្ត)*

[១៤:៣៨:២២]

**ស៖** លោកស្រី តើលោកស្រីចង់ជម្រាបយើងអំពីអ្វីដែលកើតឡើងចំពោះលោកស្រី និងក្រុមគ្រួសារដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំចង់ជម្រាបពីក្រុមគ្រួសារតូចនាងខ្ញុំ។ ខ្ញុំធ្លាប់មានគ្រួសារនៅឆ្នាំ១៩៧៦ ម្តងហើយ ខ្ញុំមានកូនស្រីមួយ។ តែគ្រួសារនាងខ្ញុំគេដកហូតចេញពីទីនុ៎ងដែរ តែមិនដឹងទៅណារហូតទាល់សព្វថ្ងៃ នាងខ្ញុំមិនបានដឹងថាស្លាប់ ឬរស់។ ហើយឆ្នាំ៧៨ ខែ៤ គឺនាងខ្ញុំគេបានដកឲ្យទៅរៀន ប៉ុន្តែការពិតនាងខ្ញុំអត់បានទៅរៀនទេ។ នាងគេយកនាងខ្ញុំទៅវត្តបទុម ចូលទៅវត្តបទុម៣ថ្ងៃ សម្រាកនៅវត្តបទុម ហើយនាងខ្ញុំមានកូនស្រីមួយ ចេះតែដើរទៅក្រៅរបង។ អ៊ីចឹងខ្ញុំចេះតែទៅចាប់កូនមកវិញ ហើយមានបងប្អូននៅហ្នឹងប្រុសៗ គាត់ទៅហាមខ្ញុំថាអ្នកបងកុំទៅក្រៅ។ ខ្ញុំថាម៉េច! ចុះបើខ្ញុំចេញមកក្រៅ ខ្ញុំកូនខ្ញុំដើរលេង។ ថាអត់ទេខ្លាចភ្ញៀវឃើញ។ អ៊ីចឹងខ្ញុំក៏តបសម្តីទៅវិញថា ភ្ញៀវឃើញឯណា បើផ្លូវមួយៗបាំងស័ង្កសីជិតហើយ។ អ៊ីចឹងនាងខ្ញុំទៅនៅនោះបាន៣យប់ ប្រហែលជាម៉ោងបី ឮសូរសំឡេង

គោះទ្វារ ប្រាប់នាងខ្ញុំថាឲ្យរៀបចំអីវ៉ាន់ធ្វើដំណើរទៅទៀត។ អ៊ីចឹងខ្ញុំក៏រៀបចំអីវ៉ាន់មក ស្រាប់តែងឹតឡើងនាងខ្ញុំមកដល់នៅកន្លែងមន្ទីរមួយគេធ្វើបាយ ធ្វើទឹក ហើយមានកាណូតមួយគ្រឿងចាំយកនាងខ្ញុំទៅដីក្រហម។ តែគ្រាន់តែថាធ្វើដំណើរមកហ្នឹង មានអ្នកជូនមកហ្នឹង គាត់ប្រាប់ "បងស្គាល់ដីក្រហមទេ?" អ៊ីចឹង នាងខ្ញុំថាស្គាល់។ "អ៊ីចឹងបងអត់អីទេ បងទៅកសាងខ្លួនសាថ្មី។ បងកសាងខ្លួនហើយល្អ បងនឹងបានចូលភ្នំពេញវិញ"។ ពេលនោះបានខ្ញុំដឹងថាខ្លួនខ្ញុំខុសអី។ ការពិតមកដល់សព្វថ្ងៃខ្ញុំមិនដឹងថា ខ្ញុំខុសអីទេ។ ខ្ញុំព្រាត់ប្រាស់កូន ព្រាត់ប្រាស់ប្ដីម្ដងហើយ ហើយគ្រួសារខ្ញុំក្រោយនេះ ទើបនឹងបានគ្នានៅឆ្នាំ៨៣នេះទេ លោកស្រី។

[១៤:៤០:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មម សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី បន្តកិច្ចដំណើរការសវនាការតទៅទៀត។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សី និងបុគ្គលិកជំនួយការអមសាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញពួកគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៣:០១នាទី)*

[១៥:០១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិ សុំ -- អង្គជំនុំជម្រះសូមរំឭកលោកស្រីមេធាវីថា សំណួរដែលសួរដេញដោលចំពោះសាក្សីរូបនេះ គប្បីកម្រិតកំណត់ត្រឹមវិសាលភាពនៃអង្គហេតុដែល

អង្គជំនុំជម្រះកំណត់មកធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ គឺដំណាក់កាលជម្លៀសលើកទី១ និង លើកទី២ នៅឆ្នាំ១៩៧៥-៧៦ អាចមានរឿងករណីតិចតួច អាចចូលនឹងដើមឆ្នាំ១៩៧៧ បានហើយ។

[១៥:០២:៥៨]

**លោកស្រី បេនី យេ៖**

សូមអរគុណ លោកប្រធាន។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** សូមអរគុណលោកស្រី ស សៀក ចំពោះការក្លាហាន និងកម្លាំងដែលព្យាយាមឆ្លើយ។ មុននេះយើងនិយាយអំពីវត្តបទុម ហើយខ្ញុំចង់ត្រឡប់ទៅវិញ។ ថ្ងៃដែលគេប្តូរបញ្ជូនលោកស្រីចេញពីក្រសួងនោះ តើគេបញ្ជូនចេញនៅក្នុងខែណាដែរ? នៅពេលដែលវាកើតឡើងនោះ?

**លោក ស សៀក:**

**ឆ៖** ចាស លោកស្រីនាងខ្ញុំបានផ្លាស់ចេញពីមន្ទីររោងពុម្ពនៅឆ្នាំ១៩៧៨ ក្នុងខែ៤។ នាងខ្ញុំទៅដល់ -- ចេញពីវត្តបទុម ទៅដល់ដីក្រហមឈ្មោះថា ប-២០ នាងខ្ញុំទៅដល់មុនចូលឆ្នាំ ៣ថ្ងៃ។

**ស៖** សូមអរគុណ។ នរណាគេប្រាប់លោកស្រីថា លោកស្រីត្រូវចាកចេញពីក្រសួងនោះ?

**ឆ៖** ចាស លោកស្រី ប្រធានមន្ទីរនាងខ្ញុំនៅរោងពុម្ពហ្នឹងឈ្មោះ១មិត្ត ហួន –ប្រុស– បានឲ្យនាងខ្ញុំរៀបចំអីវ៉ាន់ថាទៅរៀន។ អស់មតិហើយ។

**ស៖** តើលោកស្រីដឹងទេ នៅពេលនោះថាទៅអប់រំនោះមានន័យយ៉ាងម៉េចដែរ?

**ឆ៖** ចាស លោកស្រី គេឲ្យនាងខ្ញុំថាទៅរៀនហ្នឹង ការពិតមិនមែនទៅរៀនទេ គឺឲ្យនាងខ្ញុំទៅកសាងខ្លួនជាថ្មី។ ពីព្រោះអីខ្ញុំដឹងតាមតែកុងឡាន អាអូនមួយហ្នឹង តែខ្ញុំមិនបានចាំឈ្មោះប្រាប់ថា បងឯងទៅដីក្រហម បងឯងទៅកសាងខ្លួនជាថ្មីណ៎ា កសាងខ្លួនល្អហើយ បងនឹងបានចូលមកធ្វើការងារនៅភ្នំពេញនេះវិញ។ ចាស នាងខ្ញុំដឹងប៉ុណ្ណឹង។

[១៥:០៥:០២]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ត្រឡប់ចូលមកអង្គហេតុ ដែលបានជម្រាបអម្បាញ់មិញ គឺអង្គហេតុនៅក្នុងសំណុំរឿង០០២/០១។ នៅក្នុងវិសាលភាព នៃកាលវេលាជម្លៀសលើកទី១ -- ដំណាក់កាលទី១ និង ដំណាក់កាលទី២។

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។

ការដកចេញពីក្រសួងឃោសនាការនេះ គឺវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធក្រសួង។ ដូច្នេះហើយវាក៏ជាប់ពាក់ព័ន្ធទៅនឹងគោលនយោបាយនៃការដកចេញ និងការបាត់ខ្លួន នៅក្នុងសំណុំរឿង០០២/០១។ លោកប្រធាន។

[១៥:០៥:៥០]

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** លោកស្រី ស សៀក ខ្ញុំសូមបន្តការតាំងសំណួរបន្តទៀត។ លោកស្រីបាននិយាយអំពីថាអ្នកបើកបរ។ តើមានអ្នកណាគេបើកឡានមកដឹកលោកស្រីដែរឬទេ? តើវាជាឡានយ៉ាងម៉េចដែរ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ដំបូងឡើយ មិត្តហ្នួន បានប្រាប់ខ្ញុំថា រៀបចំអីវ៉ាន់ទៅរៀនណ៎ា បង ពីរបីថ្ងៃទេមកវិញហើយ ហើយឡានដែលគេមកយកខ្ញុំហ្នឹង ឡានអាឡង់ប៉ាតា។ ឡាននៅមន្ទីរឃោសនាអប់រំ។ ឡានហ្នឹង ឡានកងការពារ ធ្លាប់តែដឹកអ្នកស្រី យុន យ៉ាត។ អ្នកបើកឡានហ្នឹង ឈ្មោះ ថា។

**ស៖** ដូច្នេះហើយលោកស្រី ឡានរបស់លោកស្រី យុន យ៉ាត នេះ គឺទៅយកលោកស្រីពីក្រសួងទៅវត្តបទុម។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស ពិតមែនលោកស្រី។

**ស៖** នៅនេះពេលនេះ លោកស្រីនិយាយថា គេយកលោកស្រីទៅអប់រំ។ តើគេយកទៅអប់រំនៅវត្តបទុមនោះ មានអ្វីកើតឡើងដែរ នៅពេលដែលគេថា យកទៅអប់រំនៅវត្តបទុមនោះ?

**ឆ៖** ចាស ខ្ញុំគ្រាន់តែទៅស្នាក់នៅតែបីយប់ទេ។ ប៉ុន្តែគ្រាន់តែថាសកម្មភាពនៅទីនុំង មានតែបងប្អូនប្រុសៗ។ ហើយថ្ងៃមួយ នាងខ្ញុំបានដើរជួយស្រោចខ្ទឹម ស្រោចអីហ្នឹង ហើយដល់ពេលប្រឡាក់ជើងប្រឡាក់ដៃ នាងខ្ញុំបានចូលទៅកន្លែងមួយ ផ្ទះធំដែរ ផ្ទះល្វែង ទៅលាងដៃនៅនោះ ហើយខ្ញុំឃើញមានជាសម្ភារៈ ដូចជា សំពត់ ខោអាវ ប៉ាឡូច្រើន នៅទីនោះ ប៉ុន្តែគ្រាន់ថា មិនដឹងជារបស់បងប្អូនរស់នៅកន្លែងហ្នឹង ឬមួយក៏គេប្រមូលយកមកពីណា យកមកទុកដាក់កន្លែងហ្នឹងទេ លោកស្រី។

[១៥:០៨:០៧]

**ស៖** តើមានបុរសផ្សេងដែរឬទេ នៅ ដែលគេដាក់នៅវត្តបទុមនោះដែរ តើមានដែរឬទេ?

**ឆ៖** ចាស អត់មានទេ អ្នកធ្វើដំណើរមកជាមួយខ្ញុំ អត់មានទេ។ មានតែខ្ញុំ និងកូនខ្ញុំ តែពីរនាក់។ ក្រៅពីហ្នឹង គេអ្នកនៅផ្ទះហ្នឹងចាស់ នៅហ្នឹង។ អស់យោបល់។

**ស៖** តើបុរសៗដែលនៅវត្តបទុមនោះ តើលោកស្រីធ្លាប់ស្គាល់ពួកគេដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំមិនដែលស្គាល់ផង។

**ស៖** ដូច្នេះ ក្នុងពេលដែលលោកស្រីស្នាក់នៅវត្តបទុមបីថ្ងៃ តើលោកស្រីត្រូវបានគេឲ្យទៅចូលវគ្គអប់រំអីដែរឬទេ?

**ឆ៖** ចាស អត់មានទេ សូម្បីតែសាកសួរអី ក៏អត់និយាយស្ដីធម្មតា គ្រាន់តែថា ហាមមិនឲ្យចេញក្រៅតែប៉ុណ្ណឹង។

[១៥:០៩:២៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី សូមរំឭកជាចុងក្រោយ។ សូមលោកស្រីរៀបចំនូវសំណួរដែលពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយ ដែលបានអនុវត្តក្នុងកម្រិតត្រឹមផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី១ និងទី២ ដែលពាក់ព័ន្ធនឹងកាលបរច្ឆេទមិនលើសពីឆ្នាំ១៩៧៦ -- ៧៥-៧៦។ បើសិនជាអាចបង្ហាញបាន គឺបើមានពាក់ព័ន្ធ គឺក្រោយចិតសិប -- ចុងដើមឆ្នាំ៧៧ ខែ១ ឬខែ២ ប៉ុណ្ណោះ។ នេះ ការតាំងសំណួរសាក្សីរូបនេះ គឺក្នុងវិសាលភាពសំណុំរឿង០០២/០១។ ដូចយើងរំឭក ដូចបីដងទៅហើយ។

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** ដូច្នេះ ខ្ញុំនឹងសួរសំណួរចុងក្រោយលើប្រធានបទនេះ។ តើលោកស្រីដឹងទេ ហេតុអ្វីបានគេឲ្យលោកស្រីស្នាក់នៅវត្តបទុមរយៈពេល៣ថ្ងៃ មុនគេបញ្ជូនលោកស្រីទៅប-២០នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរក្រៅអង្គហេតុដែលកំណត់ឲ្យធ្វើសវនាការ។

[១៥:១០:៤៨]

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** ខ្ញុំនឹងបន្តចូលទៅដល់ប្រធានបទមួយទៀត។ លោកស្រីបានបញ្ជាក់ថាៗ លោកស្រីបានរៀបការម្តងហើយនៅក្នុងឆ្នាំ១៩៧៦ ហើយស្វាមីរបស់លោកស្រី ពីមុននោះគឺមិនមែនជាស្វាមីបច្ចុប្បន្ននេះទេ តើអ៊ីចឹងដែរឬទេ?

**លោក ស សៀក៖**

**ឆ៖** ចាស ត្រឹមត្រូវហើយលោកស្រី។

**ស៖** នៅពេលនោះ គឺលោកស្រីបានធ្វើការងារនៅក្រសួងឃោសនាការរួចទៅហើយនៅក្នុងឆ្នាំ៧៦នោះ អ៊ីចឹងនៅពេលនោះ នៅពេលរៀបការហ្នឹងតើមានការសុំការអនុញ្ញាតពីមេរបស់លោកស្រីដែរឬទេ?

**ឆ៖** ចាស លោកស្រីពេលនោះ មានការស្នើ -- ចង់និយាយថា បើសិនបុរសណាស្រលាញ់នារីណាមួយស្នើសួរ ស្តីដណ្តឹងហ្នឹងជាពាក្យសម្តីតាមប្រធាន ដូចថាប្រធានខ្ញុំស្រីអ៊ីចឹងសួរមក ហើយប្រធានស្រីហ្នឹងយកយោបល់ហ្នឹងមក ដើម្បីមកសាកសួរដល់សាមីខ្លួននាងខ្ញុំ។ ចាស បើនាងខ្ញុំព្រមហ្នឹងបានន័យថា សម្រេចទៅតាមគោលបំណងសេចក្តីស្នើរបស់បុរសហ្នឹងហើយ។ តែក្នុងការអឹក៏សមរម្យប៉ុន្តែគ្រាន់ថា សម័យនោះនាងខ្ញុំការប្រាំមួយគូ។ ចង់ភ្លេចឈ្មោះអត់ទៅហើយលោកស្រីចាស។ ព្រោះអង្គការជាម៉ែ ជាឪ លើកនុំង ចាស មិនបានម្តាយឪពុកយើងពីស្រុកទេសអីណាមកជួយរៀបចំឲ្យទេ។

[១៥:១២:៤២]

**ស៖** ដូច្នេះ ប្តីប្រពន្ធនោះស្គាល់គ្នាមុនពេលរៀបការដែរឬទេ?

**ឆ៖** ចាស ស្គាល់ ប៉ុន្តែគ្រាន់ថា ផ្នែកការងារផ្សេងគ្នា គាត់អ្នកចាក់ផ្សាយ ខ្ញុំនៅខាងសិល្បៈ។ អស់យោបល់ហើយចាស។

**ស៖** តើមានបុគ្គលណាមួយ ដែលគាត់ប៉ានបដិសេធមិនរៀបការដែរឬទេ ពេលដែលអង្គការស្នើឲ្យរៀបការនោះ?

**ឆ៖** ចាស ទាំងប្រាំមួយគូហ្នឹង អត់មានបងប្អូនណាបដិសេធផង។

**លោកស្រី បេនី យេ៖**

សូមអរគុណលោកស្រី ស សៀក ខ្ញុំពុំមានសំណួរផ្សេងទៀតនោះទេ។ ដូច្នេះហើយខ្ញុំសូមផ្តល់បន្តវេទិកានេះជូនលោក ពេជ អង្គ ដើម្បីសួរសំណួរបន្ត។ សូមអរគុណលោកស្រី។

[១៥:១៣:៥១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំនឹងមិនចំណាយពេលច្រើនលើសពី២០នាទីទេ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរអ្នកបង ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅអ្នកបង ដើម្បីឲ្យអ្នកបងជួយបំភ្លឺពាក់ព័ន្ធទៅនឹងចំណុចបន្តិចបន្តួច។ នៅពេលដែលអ្នកបងបានមកដល់ភ្នំពេញ អ្នកបងបានមានប្រសាសន៍ថា ទៅស្នាក់នៅស្ពានមួយយប់ ហើយបន្ទាប់មកអ្នកបងទៅៗក្រសួងឃោសនាការ ហើយតើអ្នកបងអាចនិយាយបានទេ ស្ថានភាពបន្ទាប់ពីមានការជម្លៀសនៅភ្នំពេញហ្នឹង ថាតើស្ថានភាពទីក្រុងភ្នំពេញហ្នឹងមានមនុស្សរស់នៅដែរឬទេ? ហើយបើមានថា តើអ្នកណាខ្លះដែលរស់នៅទីក្រុងភ្នំពេញនោះ?

[១៥:១៥:០១]

**ឆ៖** ចាស លោក នាងខ្ញុំមកដល់ទីក្រុងភ្នំពេញ ក្រៅពីប្រជាជនដែលជម្លៀសទៅហើយហ្នឹងមិនមានឃើញប្រជាជនសាមញ្ញរស់នៅទីហ្នឹងទេ មានតែកងទ័ពនារី ហើយទ័ពប្រុសៗ ហើយនិងពួកនាងខ្ញុំប៉ុណ្ណឹង។ តែត្រង់វាធំ នាងខ្ញុំមិនដែលបានដើរផង មកនៅតែហ្នឹងស្ពានហើយជិះឡានមកក្រសួងឃោសនាការតែម្តង។

**ស៖** តើនៅពេលបន្ទាប់ -- ពេលនោះ ថាតើបន្ទាប់ពីផ្តើមមកដល់ភ្នំពេញដំបូងរហូតទៅដល់ឆ្នាំ៧៦ហ្នឹង ថាតើអ្នកបងមានសិទ្ធិនៅក្នុងការដើរនៅក្នុងទីក្រុងភ្នំពេញ ឬក៏ចេញពីទីក្រុងភ្នំពេញដោយខ្លួនឯងដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំមិនដែលបានដើរហើរទៅណាផង នៅតែកន្លែង។ ប៉ុន្តែសិទ្ធិសេរីភាពត្រង់ថាយើងចង់ដើរហើរទៅណា សុំ ស្នើសុំពីប្រធានបាន មិនមានការតឹងតែងទេ។

**ស៖** តើនៅពេលដែលអ្នកបងមានប្រសាសន៍ថា ចង់ដើរទៅណា ស្នើសុំថាតើអ្នកបងធ្លាប់ស្នើសុំដើម្បីទៅលេងសាច់ញាតិ បងប្អូនដែរឬទេ នៅពេលនោះ ហើយប្រធានមានធ្លាប់អនុញ្ញាតដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំមិនដែលបានសុំទៅលេងស្រុកកំណើតផង នៅតែកន្លែង។

**ស៖** ខ្ញុំចូលទៅដល់ចំណុចមួយទៀត អ្នកបងមានគ្រួសារក្រោយដែលអ្នកបងបានរស់នៅ

ជាមួយគាត់ តើអ្នកបងអាចបញ្ជាក់បានទេ ថាតើគ្រួសារក្រោយរបស់អ្នកបងឈ្មោះអីដែរ?

**ឆ៖** ចាស គ្រួសារខ្ញុំ នៅក្នុងអត្តសញ្ញាណប័ណ្ណស៊ីវិល គាត់ដាក់ថា សុត ថា នាមត្រកូលគាត់ តែក្នុងទាហាន គាត់ដាក់ ថា សុត នេះបានន័យថា គាត់ច្រឡំ។ ការពិត គាត់ឈ្មោះ ថា សុត។ យកត្រឹមត្រូវតាមអត្តសញ្ញាណប័ណ្ណទាហាន។

[១៥:១៧:៥៤]

**ស៖** តើអ្នកបងអាចជម្រាបបានទេថា នៅពេលសម័យខ្មែរក្រហម តើគ្រួសារក្រោយរបស់អ្នកបងគាត់ធ្វើការងារអ្វីខ្លះ? ហើយធ្វើការជាមួយអ្នកណា តើអ្នកបងអាចជម្រាបជាលម្អិតបានទេ?

**ឆ៖** ចាស ពីសម័យមុនមក ខ្ញុំមិនដែលស្គាល់គាត់ផង។ ទើបនឹងស្គាល់ឆ្នាំ៨៥ អឺ! អឺចឹងហើយ ៨៣។ ចាស ខ្ញុំស្គាល់គាត់ ៨៣។

**ស៖** នៅពេលដែលអ្នកបងរស់នៅជាមួយគាត់ បន្ទាប់ពីឆ្នាំ៨៣ ថាតើគាត់មានធ្លាប់និយាយអំពីអ្វីដែលគាត់ធ្វើ ឬក៏ជួបប្រទះនៅក្នុងពេលដែលគាត់ធ្វើការនៅឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ដែរឬទេ?

**ឆ៖** ចាស ខ្ញុំធ្លាប់ឮគាត់ប្រាជ្ញព្រោកពីរឿងការចូលប្រយុទ្ធនៅតាមសមរភូមិ នៅឆ្នាំ៧១ មក ៧២, ៧៣ ហ្នឹងដែលឮគាត់ប្រាជ្ញព្រោកជាមួយគ្នាគាត់ មួយស្របាល១គ្នាគាត់។

**ស៖** ចុះគាត់មានធ្លាប់និយាយអំពីជីវិតផងគាត់ ដែលគាត់ធ្វើនៅក្នុងឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ខ្ញុំចង់និយាយអំពី ពីពេលហ្នឹងថាតើនៅពេលណាមួយដែលគាត់រស់នៅជាមួយអ្នកបង បន្ទាប់ពីឆ្នាំ៨៣ រហូតដល់គាត់ សូមទោស គាត់លាចាកទៅ ថាតើគាត់មានធ្លាប់និយាយពីការងាររបស់គាត់ ដែលគាត់ធ្វើនៅពេលចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៨ ហ្នឹងដែរឬទេ? បើគាត់ធ្វើ តើគាត់ធ្វើការងារឲ្យអ្នកណា?

[១៥:១៩:៥២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក ម៉ែខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអធ្យាស្រ័យដែលខ្ញុំស្កាត់នៅពេលនេះ។ វាហាក់ដូចជាបង្ហាញថា នៅពេលនេះ យើងហាក់ដូចជាចូលទៅដល់ព័ត៌មានដែលជាព័ត៌មានចចាមអារ៉ាម។ ហើយយើងដឹងហើយថា មេធាវីហាក់បីដូចជាព្យាយាមចង់យកព័ត៌មានពាក់ព័ន្ធទៅនឹងប្ដីរបស់លោកស្រី។ យើងដឹងហើយថាយើងនៅសល់តែរយៈពេល ៤៥នាទីតែប៉ុណ្ណោះ ដើម្បីឲ្យយើងប្រើប្រាស់ពេលនេះឲ្យមាន

ប្រសិទ្ធភាព។ បើមិនដូច្នេះទេ យើងមិនអាចបញ្ចប់សាក្សីនៅក្នុងថ្ងៃនេះនោះទេ។ ដូច្នេះខ្ញុំសូមឲ្យមេធាវីសូមបញ្ជាក់ និងសួរសំណួរឲ្យបានជាក់លាក់។ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមលោកប្រធាន ខ្ញុំសូមអនុញ្ញាតខ្ញុំឆ្លើយតបករណីពាក្យចចាមអារ៉ាម ឬករណីដែលធ្លាប់ដែលឮការនិយាយពីអ្នកដទៃនេះ ធ្លាប់ត្រូវបានអង្គជំនុំជម្រះសម្រេចអំពីករណីនេះ ហើយវាវិធីសាស្ត្រនៃ -- បែបបទនៃភស្តុតាងនេះមិនត្រូវបានបដិសេធនៅក្នុងអង្គសវ -- នៅក្នុងអង្គជំនុំជម្រះនេះទេ។ អ៊ីចឹងនេះជាវិធីមួយដែលអាចធ្វើទៅបាន ហើយដោយសារគាត់បានរស់នៅជាមួយប្ដីរបស់គាត់ ហើយគាត់អាចនឹងមានលទ្ធភាពនៅក្នុងផ្ដល់ព័ត៌មានដែលគាត់អាចទទួលបានពីប្ដីរបស់គាត់។

[១៥:២១:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៣:១៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចពន្យល់ដល់អង្គជំនុំជម្រះ ដល់អង្គសវនាការបានទេសំណួរដែលលោកសួរទៅសាក្សីចុងក្រោយអំមិញនេះ សំណួរចុងក្រោយរបស់លោកហ្នឹង តើវាមានភាពពាក់ព័ន្ធយ៉ាងម៉េចដែរនៃគោលបំណងនៃការតាំងសំណួររបស់លោក សំណួរនេះចំពោះសាក្សី? បង្ហាញអំពីភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ប្ដីរបស់លោកស្រីឈ្មោះ សុត ថា គាត់ជានីរសារម្នាក់របស់ជនជាប់ចោទមួយរូប ហើយគាត់អាចដឹងពីសកម្មភាពរបស់ជនជាប់ចោទ ហើយជាពិសេសគាត់អាចដឹងពីទំនាក់ទំនងរបស់ជនជាប់ចោទជាមួយនឹងមន្ទីរស-២១ អំពីទំនាក់ទំនងរវាងជនជាប់ចោទហើយនិងមន្ទីរស-២១។

[១៥:២៤:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ! ហើយសូមសាក្សី -- ហើយជម្រាបថាសាក្សីគឺអាចឆ្លើយបានតែអ្វីដែលខ្លួនបានដឹង បានឮ បានឃើញ ចងចាំដោយច្បាស់លាស់តែប៉ុណ្ណោះ មិនអាច

ឆ្លើយដោយស្មានៗទេ។

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកក្នុងសំណួរនេះគាត់ជាគ្រួសារខ្ញុំមែន ប៉ុន្តែកិច្ចការពីមុនមក ឬក៏ការងាររបស់ផងគាត់ ខ្ញុំក្លាប់មិនបានទេ។ ដូច្នេះ នាងខ្ញុំឆ្លើយថាមិនដឹង ជារឿងរបស់ផងគាត់។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ចំណុចចុងក្រោយពាក់ព័ន្ធនឹងសំណួរ ចំណុច -- សំណួរចុងក្រោយសម្រាប់ចំណុចនេះចង់សួរ ជម្រាបសួរអ្នកបង ថាតើគាត់មានដែលនិយាយអំពីជីវិតរបស់គាត់នៅក្នុងពេលនោះជម្រាបដល់អ្នកបងដែរឬទេ?

[១៥:២៥:៣៧]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នាងខ្ញុំមិនដែលសាកសួរអំពីប្រវត្តិរបស់ផងគាត់ផង។

**ស៖** បាទ អ្នកបងមានប្រសាសន៍ថា អ្នកបងមិនដែលសាកសួរ ក៏ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើអ្នកបងធ្លាប់ឮគាត់និយាយដែរឬទេ?

**ឆ៖** មិនដែលលោក។

**ស៖** បាទ អរគុណចំពោះចម្លើយរបស់អ្នកបង។ ខ្ញុំមានចំណុចមួយចុងក្រោយដើម្បីសួរទៅអ្នកបង។ អ្នកបងបាននិយាយថា ប្រពន្ធរបស់លោក ខៀវ សំផន បានទៅជួបអ្នកបង។ តើអ្នកបងអាចបញ្ជាក់ឡើងវិញទេថា តើគាត់ទៅជួបអ្នកបង សួរគ្រួសាររបស់អ្នកបង ដើម្បីសួរពីបញ្ហាអ្វីខ្លះ?

[១៥:២៦:៤៥]

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេសំណួរនេះ! សាក្សីបានឆ្លើយរួចហើយ ជាសំណួរច្រំដែលទេ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** អ្នកបងអាចបញ្ជាក់បានទេ ហេតុអ្វីបានជាគ្រួសាររបស់លោក ខៀវ សំផន ទៅសួរបញ្ជាក់អំពីអ្វីដែលលោក ខៀវ សំផន ធ្វើ ទៅសួរទៅដល់ប្តីរបស់អ្នកបង ដើម្បីឲ្យអ្នកបង -- ប្តីរបស់អ្នកបងជម្រាបទៅគាត់?

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះជា -- ឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋានហើយ។ គាត់ជាសាក្សី មិនអាចតាំងសំណួរដើម្បីឲ្យគាត់ឆ្លើយជាសេចក្ដីសន្និដ្ឋានដោយស្មានៗបានទេ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សំណួរនេះ សំណួរចុងក្រោយរបស់ខ្ញុំ។ ថាតើអ្នកបងធ្វើការនៅក្រសួងឃោសនាការ តើប្រព័ន្ធផ្សព្វផ្សាយនៃក្រសួងឃោសនាការមាននិយាយអំពីការលំបាករបស់ប្រជាពលរដ្ឋ នៅក្នុងពេលនោះដែរឬទេ ដែលការលំបាក --ដែលប្រជាពលរដ្ឋគាត់នៅតាមជនបទផ្សេងៗនោះ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស និយាយដល់ការផ្សព្វផ្សាយ កាលពីមុនរំដោះយើងលំបាក ខ្វះស្បៀង ខ្វះអី ហើយក្រោយរំដោះហើយនិងក៏ខ្វះទឹក ខ្វះអីធ្វើស្រែ។ ដូច្នេះគឺចង់បង្កើនឲ្យបងប្អូនប្រជាជនយើងលើកទំនប់ជីកប្រឡាយទៅតាមលទ្ធភាពនៅកន្លែងមួយៗ ដើម្បីយកទឹកមកប្រើប្រាស់។ ហ្នឹងមាន តាមនាងខ្ញុំចាំ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណអ្នកបងចំពោះការឆ្លើយសំណួររបស់អ្នកបង។ ខ្ញុំសូមអរគុណច្រើន។

[១៥:២៨:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់ជូនវេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលចាប់មុនដំបូងគេ គឺក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រសិនបើមានសំណួរអីត្រូវសួរដេញដោលចំពោះសាក្សីរូបនេះ សូមអញ្ជើញ។

បាទៗ សូមអធ្យាស្រ័យដោយលោកមេធាវីការពារក្ដីលោក នួន ជា លោកចៅក្រមចង់មានបំណងចង់សួរសាក្សីរូបនេះ។ សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកស្រីខ្ញុំមានសំណួរមួយចំនួន គឺជាសំណួរបន្ត។ លោកស្រីសាក្សី លោកបានឆ្លើយថា

លោកស្រីបានជួបលោក ខៀវ សំផន ជាច្រើនលើកច្រើនសានៅមុនឆ្នាំ៧៥។ ហើយជាពិសេសលោកស្រីបានឆ្លើយថា លោកស្រីដឹងថាគាត់ជាមេដឹកនាំមួយរូបនៃកម្ពុជាប្រជាធិបតេយ្យ។ លោកស្រីក៏បានឆ្លើយផងដែរនៅមុនឆ្នាំ -- ក្រោយឆ្នាំ ក្រោយថ្ងៃទី១៧ មេសា ១៩៧៥ នោះ គឺលោកស្រីបានជួបគាត់ជាច្រើនដងដែរ គឺនៅកំពង់ស្ពឺ ឬក៏ជួបនៅភ្នំអង្គរស្ស ហើយបន្ទាប់មកលោកស្រីក៏បានជួបលោក ខៀវ សំផន នៅក្រសួងឃោសនាការ និងព័ត៌មាន។ ខ្ញុំចង់ដឹងថាតើលោកស្រីនៅចាំច្បាស់ទេ អំពីការជួបលោក ខៀវសំផន ទាំងអស់នេះនោះ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ខ្ញុំបានជួបគាត់ដំបូងឡើយនៅម្តុំស្ពឺស្រែវាល។ ចាស ដូចខ្ញុំបានឆ្លើយនូវសំណួរពីមុនមកអ៊ីចឹង។ ហើយក្រោយមកទៀត ក៏បានជួបគាត់នៅម្តុំអង្គរស្សហ្នឹងមួយភ្លែតទេ មិនមែនជាយូរទេ ក៏គាត់ ពួកគាត់មិនដឹងទៅណាវិញ ហើយមកជួបនៅឃោសនាការហ្នឹងរយៈ១ថ្ងៃ ឬ២ថ្ងៃ ហើយក៏គាត់ចេញពីហ្នឹងទៅរហូត។ ចាស ការពិតលោកខ្ញុំស្គាល់លោកច្បាស់ណាស់។

[១៥:៣១:២៤]

**ស៖** លោកបាន -- លោកស្រីបានឆ្លើយថាលោកមិនធ្លាប់ -- លោកស្រីមិនធ្លាប់បានពិភាក្សាជាមួយលោក ខៀវ សំផន ទេ។ តើលោកស្រីអាចមើលឃើញគាត់ច្បាស់ទេ? ហើយបើតាមការចងចាំរបស់លោកស្រីនោះ តើលោក ខៀវ សំផន នោះ គាត់មានឥរិយាបទជាក់លាក់យ៉ាងម៉េចដែរ ពេលដែលលោកស្រីជួបគាត់នោះ? តើលោកស្រីឃើញគាត់ថាដូចជាមានការពេញចិត្តនៅពេលដែលឃើញរំដោះភ្នំពេញបាន ឬមួយក៏គាត់មានសភាពដូចជាក្រៀមក្រំ អស់សង្ឃឹម ខូចខកចិត្ត។ តើលោកអាចបញ្ជាក់អំពីអារម្មណ៍របស់គាត់នៅពេលនោះទេ នៅពេលដែលលោកស្រីឃើញគាត់នោះ?

**ឆ៖** ចាស លោកប្រធាន តាមនាងខ្ញុំសង្កេតអាកប្បកិរិយារបស់លោក មើលទៅ គាត់ថានឹងនរគាត់មិនល្អល្អាច ឬមួយក៏ក្រេវក្រោធនឹងជ័យជម្នះអីតែឯងនោះបានទេ ព្រោះអីឃើញគាត់សភាពចាស់ទុំនឹងនរធម្មតា។ អស់យោបល់។

**ស៖** តើនៅឆ្នាំ៧៥ ហ្នឹង លោកស្រីឃើញគាត់ ថាគាត់ហ្នឹងដូចជាចាស់ទេ នៅពេលនុ៎ង?

**ឆ៖** ចាស គាត់ក្មេងជាងនេះ។

**ស៖** នៅក្នុងសំណុំរឿងគឺមានសៀវភៅមួយរបស់លោក ខៀវ សំផន គឺសៀវភៅប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់។ ឯកសារ E3/18 ERN ជាភាសាអង់គ្លេស

00103750, ERN ជាភាសាបារាំង 00595427 ទៅដល់ 28។ លោក ខៀវ សំផន បានសរសេរថា "គាត់មានការភ្ញាក់ផ្អើលក្នុងការមើលឃើញថាទីក្រុងភ្នំពេញត្រូវបានគេជម្លៀសប្រជាជនចេញ ហើយគាត់ក៏មានការងឿងឆ្ងល់ផងដែរ។ គាត់ថែមទាំងបានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ថា "គាត់ក្រៀមក្រំ តឹងទ្រូង រន្ធត់ចិត្តក្នុងការនឹកស្រមៃឃើញថាមានមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ កូនក្មេងតូចៗ អ្នកជំងឺត្រូវដើរទៅគ្រប់ទិសទី ក្រោមកម្តៅថ្ងៃក្តៅហែង ហើយក្នុងចម្ងាយផ្លូវដ៏ឆ្ងាយៗ។ ដូច្នេះគាត់សួរខ្លួនគាត់ថា តើពួកគាត់អាចយកអ្វីទៅជាប់ខ្លួនបានខ្លះ? តើពួកគាត់ដឹងថាត្រូវទៅណាទេ? តើប៉ុន្មាននាក់អាចទៅដល់ទិសដៅ? គាត់សួរខ្លួនឯងថា តើបងប្អូនជាទីស្រលាញ់របស់គាត់ មិត្តភក្តិរបស់គាត់នឹងទៅជាយ៉ាងណា? ហើយក៏គាត់សួរខ្លួនឯងផងដែរថា ហេតុអ្វីបានជាចំពេលដែលគាត់កំពុងតែសង្ឃឹមក្នុងចិត្តថានឹងបានជួបគ្នាឡើងវិញនោះ ឥឡូវនោះបែរជាឃ្លាតឆ្ងាយពីពួកគេអស់ទាំងនោះទៅវិញ? ហើយក៏គាត់សួរខ្លួនឯងទៀតថា តើពួកគេនឹងជួបការលំបាកយ៉ាងណាទៅនៅពេលជម្លៀសនោះ? ហើយពួកគេអាចទ្រំទ្របានដែរឬទេ? ហើយតើអ្នកណាខ្លះនឹងត្រូវស្លាប់នោះ? ហើយជាចុងក្រោយគាត់បានសរសេរថា ទាំងអស់នេះសុទ្ធតែជាសំណួរដែលធ្វើឱ្យខ្ញុំខ្វល់ចិត្ត"។ តើលោកស្រីមាននឹកឃើញទេ ថាឃើញលោក ខៀវ សំផន ពេលនោះ ហាក់ដូចជាគាត់មនុស្សដែលមានខ្វល់ចិត្តក្រៀមក្រំនោះ?

**ឆ៖** ចាស ក្នុងចំណុចនេះ នាងខ្ញុំមិនបានតាមដានរូបភាពលោកទេ អានោះ ជាសន្តានចិត្ត និងមនោសញ្ចេតនារបស់ផងគាត់ ផ្ទាល់ខ្លួនគាត់ នាងខ្ញុំមិនបានយល់ទេ។

**ស៖** នៅក្នុងប៉ុន្មានថ្ងៃមុនពេលបែកភ្នំពេញ ហើយនិងក្រោយបែកភ្នំពេញនោះ លោកស្រីមិនមានចាំទេថា ស្តាប់ឮសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ឬក៏សេចក្តីថ្លែងការណ៍ដែលធ្វើឡើងតាំងនាមឱ្យលោក ខៀវ សំផន នៅតាមវិទ្យុនោះ។ លោកស្រីមិនចាំទេ ថាមានការផ្សាយតាមវិទ្យុពីសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន នោះ?

**ឆ៖** ចាស នាងខ្ញុំមិនបានស្តាប់ ហើយក៏មិនបានតាមដានដែរ លោក។

[១៥:៣៦:២៨]

**ស៖** សម្រាប់ជាប្រតិចារឹកសវនាការ យើងមានឯកសារ សេចក្តីថ្លែងការណ៍ប្រាំមួយនៅក្នុងសំណុំរឿង ដែលជាសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន។ ហើយសេចក្តីថ្លែងការណ៍ជាច្រើននោះ គឺមាននៅឯកសារលេខ E3/118 ដែលជាកម្រងព័ត៌មានរបស់សេវាផ្សព្វផ្សាយព័ត៌មានបរទេស *ហ្វរិនប្រ៊ែតខេស អ៊ិនហ្វ៊មេសិន សឺវីស*។ កាលទី១ ហ្នឹង គឺនៅថ្ងៃទី១ ខែមេសា ឆ្នាំ៧៥ គឺសេចក្តី

ថ្លែងការណ៍ ដែលមានចំណងជើងថា “ខៀវ សំផន ចេញផ្សាយសេចក្តីថ្លែងការណ៍ស្តីពីភាពការណ៍បច្ចុប្បន្ន”។ ដោយមានបញ្ជាក់ថា ជាការថតសំឡេងចេញពីអត្ថបទអានដោយ ខៀវ សំផន ផ្ទាល់។ ERN ជាភាសាបារាំង គឺ 00700256 ទៅដល់ 57, ERN ជាភាសាអង់គ្លេស 00166897 ទៅដល់ 98, ERN ជាភាសាខ្មែរ 00700267 ទៅដល់ 88។

ឯកសារទី២ គឺចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ៧៥ ដោយមានចំណងជើងថា “ខៀវ សំផន អបអរសាទរកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ចំពោះជ័យជម្នះនៅអ្នកលឿង”។ ដោយមានការបញ្ជាក់ថា អត្ថបទអានដោយអ្នកផ្សាយវិទ្យុ មិនមែនអានដោយលោក ខៀវ សំផន ទេ។ ERN ជាភាសាអង់គ្លេស គឺ 00166923 ទៅដល់ 25, ERN ជាភាសាខ្មែរ ខ្ញុំបានផ្តល់ជូនពីខាងលើរួចមកហើយ។ សារទី៣ គឺផ្សាយនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៥ មានចំណងជើងថា “សេចក្តីបដិសេធន៍របស់លោក ខៀវ សំផន” គឺការបដិសេធអំពីការចរចាជាមួយសាធារណរដ្ឋខ្មែរ។ ERN ជាភាសាអង់គ្លេស 00166927, ERN ជាភាសាខ្មែរ 00700267 ទៅដល់ 88។

[១៥:៣៨:៣៩]

សារទី៤ គឺផ្សាយនៅថ្ងៃទីម្តែ -- នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ៧៥ គឺមុនពេលវាយយកទីក្រុងភ្នំពេញបាន។ នេះគឺជាសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ៧៥ មានចំណងជើងថា “ខៀវ សំផន អំពាវនាវប្រជាជនពីក្រុងភ្នំពេញ ឲ្យចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា”។ ERN ជាភាសាអង់គ្លេស 00166948 ទៅដល់ 49, ERN ជាភាសាខ្មែរ 00700267 ទៅដល់ 88។ សារទី៥ គឺជាសារដែលដកស្រង់សហព្រះរាជអាជ្ញារួចមកហើយ គឺផ្សាយនៅថ្ងៃទី២២ ខែមេសា ឆ្នាំ៧៥ អំពីសុន្ទរកថារបស់ ខៀវ សំផន ដែលមានចំណងជើងថា “សារអបអរសាទរលោក ខៀវ សំផន”។ ERN ជាភាសាអង់គ្លេស 00166994 ទៅដល់ 96, ERN ជាភាសាខ្មែរ 00700267 ទៅដល់ 88។

ខ្ញុំសូមបញ្ជាក់ថា អត្ថបទនៃសារនេះ មានជាភាសាបារាំងផងដែរ គឺយើងអាចរកបាន នៅក្នុងបណ្ណសារដ្ឋានរបស់អតីតសាធារណរដ្ឋប្រជាមានិតអាល្លឺម៉ង់ គឺឯកសារលេខ D359/1/1.1.37។ ERN ជាភាសាបារាំង គឺ 00537478 ទៅដល់ 00537481។ ហើយជាចុងក្រោយ គឺសារទី៦ដែលជាការផ្សាយសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន មានចំណងជើងថា “សេចក្តីប្រកាសព័ត៌មានរបស់សមាជជាតិពិសេសនៃកម្ពុជា” ដែលបានប្រជុំពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ៧៥ ERN

ជាភាសាបារាំង 00700264 ទៅដល់ 66, ERN ជាភាសាអង់គ្លេស 00167012 ទៅដល់ 13, ERN ជាភាសាខ្មែរ គឺដូចទៅនឹង ERN ពីមុនៗមក។

លោកស្រី ស សៀក អ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ តើលោកស្រីមានចាំទេ អំពីសារណាមួយដែលបានផ្សាយនៅក្នុងវិទ្យុដែលពីសម័យនោះ យើងហៅថា ជាវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជានោះ?

[១៥:៤០:៥៥]

**ឆ៖** ចាស លោក នាងខ្ញុំមិនបានចាំទេ ចំពោះនាងខ្ញុំផ្ទាល់ ពីព្រោះអី បន្ទប់អាន ហើយចម្ងាយពីផ្ទះនាងខ្ញុំវាឆ្ងាយ ប្រហែលជាមួយរយម៉ែត្រជាង ដូច្នេះចង់លោក អញ្ជើញមកថ្លែងការណ៍ ឬមួយក៏អានផ្ទាល់អីនាងខ្ញុំមិនបានឃើញ ហើយមិនបានចាំទេ លោក។ ម្យ៉ាងវាយូរឆ្នាំពេក ឲ្យនាងខ្ញុំចងចាំដូចមិនបាន។

**សៈ** លោកស្រី ស សៀក តើលោកស្រីស្ដាប់ឮ ឬក៏លោកស្រីដឹងថា វិទ្យុនុំងបានផ្សាយអំពីសារណាមួយដែលផ្សាយទៅដល់ប្រជាជន ដើម្បីប្រាប់ថា ប្រជាជនត្រូវបានគេជម្លៀស ហើយនិងប្រាប់ពីមូលហេតុនៃការជម្លៀសប្រជាជននេះ? តើលោកស្រីមានស្ដាប់ឮទេ អំពីការពន្យល់របស់មេដឹកនាំនោះចំពោះប្រជាជនថា ហេតុអីបានជាគេត្រូវជម្លៀសប្រជាជនអីអ៊ីចឹង លោកស្រីមានបានឮសារហ្នឹងទេ?

[១៥:៤២:០៦]

**ឆ៖** ចាស ក្នុងសំណួរ នាងខ្ញុំត្រិះរិះរកមើលដូចថា នាងខ្ញុំមិនបានស្ដាប់ផង តែគ្រាន់ថាជាក់លាក់នាងខ្ញុំឃើញនឹងភ្នែកខ្លួនឯង អានុំងឃើញ។ ប៉ុន្តែដូចថា សាររបស់លោក ខៀវ សំផន អីខ្ញុំអត់បានស្ដាប់ អ៊ីចឹងចោទថា នាងខ្ញុំនៅក្មេងចុះ។ មិនសូវគិត មិនសូវគូរឿងអ៊ីចឹងៗ។

**សៈ** លោកស្រីសាក្សី នៅក្នុងសវនាការថ្ងៃទី១៦ ខែសីហា នៅវេលាម៉ោង ១៥:០៣ លោកស្រីបានឆ្លើយថា "មុនពេលរំដោះ ពេលមានសុន្ទរកថា របស់លោក ខៀវ សំផន ម្ដងៗនោះគេប្រាប់ឲ្យទៅស្ដាប់ -- នៅក្នុងភាសាបារាំងអាចមានបញ្ហាបន្តិច គឺថាមិនមែន *ដាតតាំងជ្រ័* ទេ គឺ *អាស៊ីស្តេ* -- ក៏ប៉ុន្តែក្រោយពេលរំដោះនោះ ខ្ញុំមិនបានទទួលការណែនាំឲ្យទៅស្ដាប់នោះទេ។ ប្រសិនបើខ្ញុំបានទទួលការណែនាំ ខ្ញុំនឹងទៅស្ដាប់"។ តើលោកស្រីអាចបញ្ជាក់បានទេ មុនពេលរំដោះទីក្រុងភ្នំពេញនៅពេលដែលខៀវ សំផន ធ្វើសេចក្ដីថ្លែងការណ៍អ្វីមួយនោះ គេបានស្នើឲ្យអ្នកនៅធ្វើនៅវិទ្យុរបស់លោកស្រីហ្នឹង គឺថាទៅជួបជុំគ្នាដើម្បីស្ដាប់ តើវាគ្រាន់តែជាការទៅស្ដាប់ប៉ុណ្ណឹង ទៅស្ដាប់លោក ខៀវ សំផន ថ្លែងការណ៍

ឬទៅគ្រាន់តែទៅស្ដាប់វិទ្យុទេ?

[១៥:៤៣:៣៣]

**ឆ៖** ចាស ការពិត នេះជាមតិនាងខ្ញុំ សំណួរពីមុនមកខាងលោកខាងនេះសួរ។ នាងខ្ញុំអត់បានចងចាំទេ តែបើសិនថា នេះ នាងខ្ញុំឧទាហរណ៍ថា បើសិនថា ផ្នែក ឬក៏ប្រធាននាងខ្ញុំសុំឱ្យបងប្អូនមកជួបជុំគ្នាដើម្បីស្ដាប់សេចក្ដីថ្លែងការណ៍ របស់ផងលោកប្រហែលជានាងខ្ញុំចងចាំ ប្រហែលជាស្ដាប់ស្ដាប់ៗសេចក្ដីថ្លែងការណ៍របស់ផងលោកហ្នឹង ប៉ុន្តែអត់មាន នាងខ្ញុំមិនបានចាំ។

**ស៖** លោកស្រី ទៅស្ដាប់លោក ខៀវ សំផន ដោយផ្ទាល់មែនទេ បានន័យថា លោក ខៀវ សំផន មកធ្វើសុន្ទរកថានៅចំពោះមុខលោកស្រីតែម្ដង? មានន័យថា អ៊ីចឹងមែនទេ? ឬមួយលោកស្រីគ្រាន់តែទៅស្ដាប់ហ្នឹង តើស្ដាប់តាមវិទ្យុទេ មិនមែនស្ដាប់គាត់ថ្លែងការណ៍ដោយផ្ទាល់នៅចំពោះមុខលោកស្រីទេ?

[១៥:៤៤:៣៤]

**ឆ៖** ចាស នាងខ្ញុំអត់បានស្ដាប់អីទាំងអស់។ អត់បានស្ដាប់ផង។

**ស៖** បាទ ដោយសារតែពេលវេលាទៅមុខហើយ។ អ៊ីចឹងខ្ញុំសូមចូលទៅចំណុចផ្សេងទៀតនៃសក្ខីកម្មរបស់លោកស្រី។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីឯកសារផ្សេងទៀតនៅក្នុងសំណុំរឿង យើងមានឯកសារបី ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយឯកសារទាំងបីនេះ គឺជាកំណត់ហេតុអង្គប្រជុំ ជាពិសេសគឺ អង្គប្រជុំគណៈអចិន្ត្រៃយ៍ ដែលពាក់ព័ន្ធទៅនឹងកិច្ចការងារឃោសនា និងព័ត៌មាន។ ឯកសារទី១ គឺឯកសារដែលមានលេខ E3/228 ដែលមានចំណងជើងថា “កំណត់ហេតុអង្គប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៦ របៀបវារៈ ទិសដៅឃោសនាអប់រំរបស់បក្ស ក្នុងឆ្នាំ១៩៧៦ និងតទៅមុខ។ កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងដោយមានវត្តមានរបស់បុគ្គលដូចខាងក្រោម៖ សមមិត្តលេខា គឺយើងអាចសន្និដ្ឋានបានថាជា ប៉ុល ពត, សមមិត្តអនុលេខា ដែលយើងអាចសន្និដ្ឋានបានជា នួន ជា, សមមិត្ត ឌឿន, សមមិត្ត អាត, សមមិត្ត ភាស់ ដែលយើងអាចយល់បានថា សមមិត្ត ភាស់ នេះគឺជា សមមិត្ត ហ៊ូ នឹម និងសមមិត្ត ទូច។ ERN ជាភាសាខ្មែរ 00017105 ទៅដល់ 13, ERN ជាភាសាអង់គ្លេស 00182614 ទៅដល់ 19, ERN ជាភាសាបារាំង 00301321 ទៅដល់ 29។

[១៥:៤៦:៤៩]

ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងឯកសារមួយនេះ។ ឯកសារនេះ គឺគេកំណត់អំពីសារៈ

សំខាន់នៃការងារឃោសនា សម្រាប់សមាជិកបក្ស -- សមាជិកគណៈអចិន្ត្រៃយ៍បក្ស។ ពេលដែលខ្ញុំអានឯកសារហ្នឹងទៅ គឺថាខ្ញុំមើលទៅឃើញថា គេនិយាយអំពីគុណភាព -- សូមទោស គុណសម្បត្តិ និងការខ្វះខាតមួយចំនួន គឺមាននិយាយថា ការខ្វះខាតនៅមិនទាន់ជាក់ស្ដែង ហើយយើងនៅវាយ -- ឲ្យតម្លៃទាបទៅលើអត្តចរិត នៅលើមនោគមន៍វិជ្ជា ភាសាអង់គ្លេសបកថា ជាមនោគមន៍វិជ្ជា។ គឺយើងមានពាក់ព័ន្ធទៅនឹងការតស៊ូវណ្ណៈនោះគឺថា មិនទាន់មានជាលក្ខណៈជាប្រព័ន្ធនៅឡើយទេ។ តើកង្វល់ប្រភេទនេះ គឺជាកង្វល់ ដែលលោកស្រីធ្លាប់ស្ដាប់ឮទេ នៅពេលដែលលោកស្រីធ្វើការនៅផ្នែកឃោសនាការនោះ? តើវាជាកម្មវត្ថុ នៃការឃោសនាក្នុងការផ្សព្វផ្សាយសារ ដែលមាននិយាយអំពីមនោគមន៍វិជ្ជា ហើយដែលឆ្លុះបញ្ចាំងអំពីទស្សនៈតស៊ូវណ្ណៈនេះ? ហើយតើចំពោះលោកស្រីនោះមានន័យយ៉ាងម៉េចដែរថាគោលជំហរតស៊ូវណ្ណៈនោះ?

**ឆ៖** ចាស នៅក្នុងសំណួរនេះ នាងខ្ញុំដូចអត់យល់។ តស៊ូវណ្ណៈ ខ្ញុំមិនយល់ទេលោក។

[១៥:៤៨:៣៤]

**ស៖** តើគេមាននិយាយប្រាប់លោកស្រីថា ការផ្សាយនោះត្រូវតែមានខ្លឹមសារមនោគមន៍វិជ្ជាផ្នែកសតិអារម្មណ៍ ឬក៏មានពាក់ព័ន្ធនឹងផ្នែកនយោបាយអ្វីទេ?

**ឆ៖** ចាស ក្នុងការផ្សាយវិទ្យុហ្នឹងមានការអប់រំ ជំរុញ និងលើកទឹកចិត្តដល់ប្រជាជន ជំរុញប្រជាជន ហ្នឹងមាន។ មិនអត់ទេលោក។

**ស៖** អ៊ីចឹង ខ្ញុំសូមចូលទៅនឹងឯកសារមួយទៀត ដែលមានលេខ E3/231។ នេះគឺជាឯកសារកំណត់ហេតុកិច្ចប្រជុំមួយទៀត ដែលមានចំណងជើងថា "កំណត់ហេតុអង្គប្រជុំការងារឃោសនាការថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ របៀបវារៈ ការផ្សាយអំពីការបោះឆ្នោត ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ភារកិច្ចតាមដានដំណឹង។ ភាសាអង់គ្លេសនិយាយថា *យូធី ធូ មូនីធ័រ ឌឺ ញូវ* ដែលមានន័យថា ភារកិច្ចតាមដានដំណឹង ឬក៏ព័ត៍មាន។

[១៥:៤៩:៥៨]

កិច្ចប្រជុំនេះត្រូវបានធ្វើឡើងដោយមានវត្តមានរបស់បុគ្គលដូចខាងក្រោម៖

សមមិត្ត លេខា ដែលយើងអាចសន្មតបានថាជា ប៉ុល ពត។ សមមិត្តអនុលេខា ដែលយើងអាចសន្មតបានថាជា នួន ជា។ សមមិត្ត វ៉ាន់ ដែលយើងអាចសន្មតបានថាជា អៀង សារី។ សមមិត្ត ហែម ដែលយើងសន្មតបានថាជា ខៀវ សំផន។ សមមិត្ត ឌឿន។ សមមិត្ត ភាស់ គឺយើងអាចសន្មតថាជា ហ៊ូ

នឹម និងសមមិត្ត ទូច។ ERN ជាភាសាខ្មែរ 00017124 ទៅ 27, ERN ជាភាសាអង់គ្លេស 00528385 ទៅដល់ 87, ERN ជាភាសាបារាំង 00323930 ទៅដល់ 31។ នេះគឺជាកិច្ចប្រជុំមួយដែលកើតឡើងនៅមុនពេលបោះឆ្នោតជាលើកទី១ នៅកម្ពុជាប្រជាធិបតេយ្យ។ ហើយនៅក្នុងនោះមានការបញ្ជាក់ថា យើងត្រូវផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ប៉ុន្តែយើងមិនផ្សព្វផ្សាយច្បាប់ស្តីពីការបោះឆ្នោតទេ។ យើងផ្សព្វផ្សាយអំពីរដ្ឋធម្មនុញ្ញដើម្បីអបអរសាទរដល់ការបោះឆ្នោត យើងធ្វើការអត្ថាធិប្បាយពាក់ព័ន្ធទៅនឹងរដ្ឋធម្មនុញ្ញ ដើម្បីជំរុញឲ្យមានការ -- មានចលនាអប់រំ។

[១៥:៥១:៣៩]

ប្រសិនយើងមិនផ្សព្វផ្សាយនោះ ចូនកាលទៅយើង -- យើងមិនផ្សព្វផ្សាយអំពីខ្លឹមសាររដ្ឋធម្មនុញ្ញទេ គឺមិនចាំបាច់ផ្សព្វផ្សាយអីឲ្យខ្លាំងពេកទេ។ តើលោកស្រីមានចាំទេថាលោកស្រីធ្លាប់បានដឹងអំពីការអប់រំដែលមានគោលដៅកម្រិត ឬក៏រឹតត្បិតព័ត៌មានពាក់ព័ន្ធទៅនឹងការបោះឆ្នោតដែលប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ១៩៧៦ នោះ? តើមានគេនិយាយថា យើងមិនត្រូវនិយាយអំពីព័ត៌មានបោះឆ្នោតនេះទេ? ឬក៏មានគេប្រាប់លោកស្រីថា មានប្រធានបទណាមួយដែលមិនត្រូវនិយាយនៅក្នុងពេលផ្សាយវិទ្យុនោះ?

**ធ៖** ចាស លោកសំណួរនេះ នាងខ្ញុំមិនបានចងចាំអីទេ។ ឯការប្រជុំការអីនោះជារឿងអ៊ំៗនៅខាងលើ ខ្ញុំអត់ដឹង។

[១៥:៥២:៥៨]

**ស៖** តើលោកស្រីគិតថា អ៊ំៗទាំងអស់នោះព្រួយបារម្ភថាមានព័ត៌មានដែលអាចឲ្យមានការរិះគន់ ទិតៀន ហើយត្រូវជៀសវាងការទិតៀន ដោយមាន -- ដូច្នេះមិនត្រូវផ្តល់ព័ត៌មាននោះទៅផ្សព្វផ្សាយព័ត៌មាននោះ ដើម្បីកុំឲ្យមានការទិតៀននោះ តើអ៊ីចឹងមែនទេ?

**ធ៖** ខ្ញុំអត់យល់ទេលោក។

**ស៖** មិនអីទេអ៊ីចឹង បើលោកស្រីមិនយល់ ខ្ញុំចូលទៅឯកសារទី៣។ ឯកសារនេះគឺពាក់ព័ន្ធទៅនឹងការងារឃោសនានិងព័ត៌មាន។ គឺឯកសារ E3/225 មានចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការថ្ងៃទី១ ខែមិថុនា ឆ្នាំ៧៦" របៀបវារៈផ្នែកបច្ចេកទេសផ្សេងៗ, ផ្នែកផ្ទៃក្នុងបក្ស, អង្គការស្លូលនិងមហាជន"។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងដោយមានវត្តមានរបស់បុគ្គលដូចខាងក្រោម៖

[១៥:៥៤:០៥]

សមមិត្តលេខា ជា ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, សមមិត្ត ភាស់។ ក្នុងឯកសារនេះដាក់សមមិត្ត កាស់ ប៉ុន្តែខុសទេ តាមពិត គឺ ភាស់ និងក្រុមវិទ្យុ។ សមមិត្ត គួយ, សមមិត្ត សុង និងក្រុមភាពយន្ត, សមមិត្ត ទូច ទទួលបន្ទុកកត់កំណត់ហេតុ។ ERN ជាភាសាខ្មែរ 00000837 ទៅដល់ 851, ERN ភាសាអង់គ្លេស 00182715 ទៅដល់ 24, ERN ជាភាសាបារាំង 00323903 ទៅដល់ 13។ ចំពោះភាសាបារាំងគឺមានឯកសារមួយទៀតគឺ D200/6.4។ ERN 00538890 ទៅដល់ 99។ ខ្ញុំសូមអានចំណុចមួយចំនួនដកស្រង់ចេញពីកំណត់ហេតុមួយនេះ ជាពិសេសនៅក្នុង ERN ជាភាសាបារាំង 00--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកចៅក្រមអានលេខ ERN ម្តងទៀត អ្នកបកប្រែចាប់អត់ទាន់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

*(គ្មានការបកប្រែ)*

[១៥:៥៥:៣៨]

**ប្រធានអង្គជំនុំ៖**

លោក១! លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ចាប់ផ្តើមសាជាថ្មីឡើងវិញ ព្រោះអ្នកបកប្រែតាមអត់ទេ មិនអាចបកប្រែបាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** គឺ ERN នៅទំព័រចុងក្រោយដែលខ្ញុំបានផ្តល់ជូនរួចហើយ គឺERN ជាភាសាបារាំង 00538898។ មានការនិយាយដូចជា -- ដូចតទៅពាក់ព័ន្ធទៅនឹងវ៉ាដ្យូ "យើងត្រូវតែបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ឲ្យបានខ្លាំងក្លាថែមទៀត។ ជាពិសេសធៀបទៅនឹងខ្មាំង ដែលកំពុងបង្កប់ខ្លាំង ខ្លាចវាដាក់គ្រាប់បែកផ្ទុះ។ ដូច្នេះត្រូវយាមកាម ត្រូវមានរបបចេញចូល កុំឲ្យរហេតរហូត។ ខ្មាំងជាមូលដ្ឋានវាខ្ទេចខ្ទីហើយ តែវានៅមានគោលបំណងបំផ្លាញយើង។ ជាទស្សនៈ ជាគោលជំហរ យើងត្រូវប្រុងប្រយ័ត្នថែមទៀត"។ លោកស្រី ស សៀក តើលោកស្រីមាននៅចាំអំពីកិច្ចប្រជុំមួយ ដែលគេបានណែនាំពាក់ព័ន្ធទៅនឹងភាពចាំបាច់ ក្នុងការឲ្យមានការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់នេះ? ហើយប្រសិនបើលោកស្រីនៅចាំនោះ តើខ្លឹមសារនេះមានន័យយ៉ាងមេចចំពោះលោកស្រី?

[១៥:៥៧:២៥]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន នាងខ្ញុំមិនបានចាំទេ។ ពីព្រោះអីជាការងារបែងចែកច្បាស់ ថាការងារបងៗ អ៊ំៗខាងលើ នាងខ្ញុំមិនបានដឹងផង។

**ស៖** នៅក្នុងឯកសារនេះដដែល គឺខាងលើបន្តិចមក គឺៗលេខ 00538894 គឺពាក់ព័ន្ធទៅនឹងនិពន្ធនាយកវិទ្យុ។ "និពន្ធនាយក ជាទូទៅគឺថាមានលក្ខណៈវិជ្ជមាន គឺមានបីនាក់ ក៏ប៉ុន្តែវាតិចពេក ដូច្នេះយើងត្រូវបង្កើនចំនួននេះ។ អ្នកតាក់តែងនេះគឺសុទ្ធតែជាបញ្ញវន្ត ហើយមានពាក់ព័ន្ធទៅនឹងគោលមាគ៌ារបស់បក្ស។ ដូច្នេះត្រូវតែអប់រំមនោគមន៍វិជ្ជាពួកនេះប្រាំទៅប្រាំមួយឆ្នាំ ដើម្បីឲ្យមានការជ្រួតជ្រាបច្បាស់។ យើងត្រូវតែនាំពួកគេទៅបណ្តុះបណ្តាល"។ នៅពេលដែលលោកស្រីធ្វើការនៅក្រសួងឃោសនាការនោះ តើលោកស្រីមានឃើញថាគេដកយកបញ្ញវន្ត ឬក៏បញ្ញាជនដែលធ្វើការនោះ ហើយដាក់ជំនួសដោយប្រជាជនមូលដ្ឋានដែរឬទេ?

[១៥:៥៨:៥៣]

**ឆ៖** ចាសលោក ការដកហូតហ្នឹងដូចនាងខ្ញុំបានរាយរាប់សំណួរពីលើមកហើយ មានតែឈ្មោះហាន់ មួយគាត់បញ្ញាជន។ ប៉ុន្តែហ្នឹងគាត់ខាងនិពន្ធបទភ្លេងហើយនិងចម្រៀងទេ អត់មានទាក់ទងនឹងអ្នកនិពន្ធផង។

**ស៖** លោកស្រីបាននិយាយអំពីមនុស្សមួយចំនួន ដែលគេបញ្ជូនទៅធ្វើការនៅស្រុកស្រែ ហើយចាកចេញពីក្រសួងឃោសនាការ និងការចាប់ខ្លួន ហ៊ូ នឹម និងការចាប់ខ្លួនប្រពន្ធរបស់គាត់ផងដែរ។ តើ ហ៊ូ នឹម មានកូនធ្វើការនៅក្រសួងឃោសនាការទេ? ហើយគេចាប់កូនៗរបស់គាត់ទេ?

**ឆ៖** ចាសលោក លោក ហ៊ូ នឹម គាត់អត់មានកូននៅក្រសួងឃោសនាការទេ មាននៅពេទ្យ។ កូនស្រីមួយក្រមុំនៅពេទ្យ ហើយមួយទៀតនោះ នៅរៀនភាសា។ ហើយមួយនោះនៅតាមម្តាយតូច ហើយមួយទៀតខ្ញុំភ្លាប់មិនបានដែរ គ្រាន់តែឃើញគាត់ទៅលេងម្តងម្កាល។

**ស៖** បើតាមលោកស្រីដឹង តើមានអ្នក -- មនុស្សដែលធ្វើអត្តឃាតដែរឬទេនៅក្រសួងឃោសនាការ? ហើយលោកស្រីធ្លាប់ឮអំពីការធ្វើអត្តឃាតរបស់ ព្រុំ សំអរ ដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចហើយលោក។

**ស៖** លោកស្រីភ្លេច ឬក៏លោកស្រីពិបាកនៅក្នុងការចងចាំ?

**ឆ៖** មិនបាននឹកឃើញ ភ្លេច។

**ស៖** តើលោកស្រីមាននៅនឹកឃើញទេថា នៅក្នុងកិច្ចប្រជុំណាមួយនោះ គេអានចម្លើយសារភាពរបស់បុគ្គលដែលគេហៅថាជាជនក្បត់នោះ? តើធ្លាប់មានទេ?

[១៦:០១:៣៧]

**ផ៖** ចាស នាងខ្ញុំបានស្ដាប់ក្រោយពីនេះមានលោក កុយ ធួន។ ហ្នឹង គេបានមកអាន ហើយផ្សព្វផ្សាយ ថាគាត់ជាគំរូមិនល្អអី។ តែក្រោយមកក៏នាងខ្ញុំមិនបានយកចិត្តទុកដាក់អី គ្រាន់តែដឹងឮប៉ុណ្ណឹងគ្រប់គ្នា មិនមែនតែនាងខ្ញុំទេ គ្រាប់តែគ្នានៅក្នុងក្មេងៗសិល្បៈហ្នឹង។

**ស៖** សំណួរចុងក្រោយ។ ក្នុងឋានៈជា -- លោកស្រីជាៗសិល្បៈករខាងផ្នែកល្ខោនមែនទេ? ក្រៅពីច្រៀងនោះ? តើលោកធ្លាប់សម្ដែងសិល្បៈល្ខោនអីទេ?

**ផ៖** ចាស នាងខ្ញុំផ្នែកអាយ៉ៃ។ ហើយសម្ដែងជារូបភាព ចាសនាងខ្ញុំសម្ដែងជាកាយវិការ ហើយក៏នាងខ្ញុំជំនាងខាងអាយ៉ៃ ចូលចិត្តខាងអាយ៉ៃ។ គឺថាសម័យអីនាងខ្ញុំអត់ស្ទូវចិត្ត ចូលចិត្តខាងប្រពៃណី។

**ស៖** តើលោកស្រីមានចាំរឿងល្ខោនមួយដែលមានចំណងជើងថា "រឿងផ្លូវរំដោះ គឺផ្លូវភ្លឺស្វាង"។ លោកស្រីធ្លាប់ឮរឿងល្ខោនហ្នឹងទេ?

**ផ៖** អត់ចាំចំណងជើងទេ។

[១៦:០៣:៤១]

**ស៖** សម្រាប់ជាប្រតិចារឹកសវនាការ ខ្ញុំសូមបញ្ជាក់ថារឿងល្ខោននេះ គឺមាននៅក្នុងសំណុំរឿងឯកសារ E3/637។ ERN ជាភាសាខ្មែរ 00442352 ទៅដល់ 58, ERN ជាភាសាបារាំង 00752195 ទៅដល់ 00752204, ERN ជាភាសាអង់គ្លេស 00740963 ទៅដល់70។

ខ្ញុំសូមអរគុណលោកស្រី ស សៀក។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម អរគុណលោកស្រីសាក្សី។ សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកដៃសង្ខេបទេ ប៉ុន្តែដើម្បីជាកំណត់ត្រាប្រតិចារឹកនៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ ស្ទួរអំពីឯកសារ D200/6.4 ប្រហែលជាមានបញ្ហាបកប្រែ ប៉ុន្តែចៅក្រម ឡាវ៉ែន៍ បាននិយាយអំពីសមមិត្ត លេខា នួន ជា។ អានេះជាអ្វីដែលខ្ញុំស្ដាប់ឮតាមការបកប្រែជា

ភាសាអង់គ្លេស។ ការពិតទៅនៅក្នុងឯកសារនេះមិនមានបញ្ហានោះទេ។ ដូច្នេះគ្រាន់តែថា តាមឯកសារពិតប្រាកដ គឺនិយាយថា សមមិត្តលេខា ដោយមិនមានបញ្ជាក់ឈ្មោះអ្វីទាំងអស់។ នេះគឺជាឯកសារជាភាសាខ្មែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនបានកត់លេខឯកសារអម្បាញ់មិញនេះទេ។ សូមលោកបញ្ជាក់ម្តងទៀត លោកមេធាវី។

[១៦:០៥:២៧]

**លោក ហ្សាស្តើ ប៉ោ៖**

គឺឯកសារចុងក្រោយ ដែលលោកបាននិយាយអំពីការប្រជុំនៅខែ៦ ឆ្នាំ៧៦ ប្រហែលជាមានការបកប្រែ គឺលោកនិយាយថា “អនុលេខា នួន ជា” ប៉ុន្តែការពិត អត់មានបញ្ជាក់ឈ្មោះទេ នៅក្នុងឯកសារ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ គឺជាភាសាបារាំង គឺមានបញ្ជាក់ថា “សមមិត្តលេខា, សមមិត្តអនុលេខា, សមមិត្ត ភាស់ និងក្រុមវិទ្យុសមមិត្ត គួយ, សមមិត្ត សុង និងក្រុមភាពយន្ត”។ ហើយឯកសារនេះ គឺមាននៅលេខ D200/6.4 ខ្ញុំគិតថា ប្រហែលមានបញ្ហាបកប្រែហើយ ព្រោះថានៅក្នុងភាសាបារាំងនោះ គឺថាបញ្ជាក់ច្បាស់ណាស់ សមមិត្តលេខា នោះ អនុលេខា នុ៎ង ហើយយើងមាននៅក្នុងឯកសារ E3/225 ផងដែរ ដែលមាន សមមិត្តអនុលេខា។ អង់គ្លេសថា *ឌីសញ្ជូតធី សែកក្រិតធីរី*។ ខ្ញុំមិនដឹងថា ហេតុអីបានលោកមើលមិនឃើញថាមាន អនុលេខា នៅទីនេះទេ។

[១៦:០៦:៤១]

**លោក ហ្សាស្តើ ប៉ោ៖**

ចំណុចដែលខ្ញុំយល់ គឺខ្ញុំយល់ហើយ។ ប៉ុន្តែឯកសារដែលលោកប្រធាន -- ដែលលោកចៅក្រមបានលើកឡើង គឺនិយាយថា “អនុលេខា គឺ នួន ជា” ប៉ុន្តែក្នុងការបកប្រែ គឺលោក -- លោកលេខា គឺ នួន ជា។ ដូច្នេះ អានេះគឺអ្វីដែលខ្ញុំចង់ឲ្យមានការកែប្រែ នៅក្នុងកំណត់ត្រាប្រតិចារឹក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះត្រូវប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការ

លើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២១ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

[១៦:០៧:២២]

ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី ស សៀក ដែលនឹងបន្តតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមពីក្រុមមេធាវីការពារក្តីលោក នួន ជា មុនមេធាវីពីរក្រុមទៀត សូមភាគី និងសាធារណជនជ្រាប។

លោកស្រី ស សៀក ការស្តាប់សក្ខីកម្មរបស់លោកស្រី នៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយលោកស្រីបុគ្គលិកមកពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដូចគ្នា គឺសូមអញ្ជើញមកបន្តអង្គុយអមសាក្សី នៅក្នុងការសម្របសម្រួលអារម្មណ៍របស់គាត់ ដើម្បីឲ្យ -- នៅក្នុងអំឡុងពេលដែលគាត់ផ្តល់សក្ខីកម្ម ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានល្អដូចថ្ងៃនេះ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

[១៦:០៨:២៨]

ហើយបង្គាប់ឲ្យរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន៕

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៩ នាទី)*